00751098 E51/15


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens


អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

| ឯកសារដើម |
| --- |
| ORIGINAL DOCUMENT/DOCUMENT ORIGINAL |
| ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 03 / 11 / 2011 |
| ម៉ោង (Time/Heure): 13:45 |
| មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak |

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ

**Case File/Dossier No. 002/19-09-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម ធូ មណី

កាលបរិច្ឆេទ: ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ២០១១

ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង

ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

# សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់ អៀង សារី តាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* និង ការលើកលែងទោស និងការអនុគ្រោះទោស)

**<u>សហព្រះរាជអាជ្ញា</u>**
ជា លាង
Andrew CAYLEY

**<u>ជនជាប់ចោទ</u>**
នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**<u>មេធាវីជនជាប់ចោទ</u>**
សុន អរុណ
Michiel PESTMAN
Victor KOPPE
អាង ឧត្តម
Michael G. KARNAVAS

00751099

E51/15

ផាត់ ពៅស៊ាង

Diana ELLIS

ស ស្វវ៉ាន

Jacques VERGES

## ១. សេចក្តីផ្តើម

១. អង្គជំនុំជម្រះបានទទួលអញ្ញត្រកម្មចំនួនពីរដែលបានដាក់ដោយមេធាវីការពារក្តី អៀង សារី ("ជនជាប់ចោទ") នៅថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១។ មេធាវីការពារក្តីលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមិនមានយុត្តាធិការទៅលើជនជាប់ចោទនោះទេ ពីព្រោះ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៩៦ ("ព្រះរាជក្រឹត្យ") បានផ្តល់ឱ្យជនជាប់ចោទនូវការលើកលែងទោស និងអនុគ្រោះទោសដែលមានសុពលភាព និងដោយសារមាន*គោលការណ៍គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ* (*ne bis in idem*) បានរារាំងមិនឱ្យមានការកាត់ទោសជាថ្មីលើអំពើដែលដែលជនជាប់ចោទត្រូវបានជំនុំជម្រះ *ដោយកំបាំងមុខ* នៅឆ្នាំ ១៩៧៩ ដោយ តុលាការប្រជាជនបដិវត្តន៍ ("PRT")[១]។

## ២. ប្រវត្តិនីតិវិធី

២. នៅខែ សីហា ឆ្នាំ ១៩៧៩ ជនជាប់ចោទត្រូវបានជំនុំជម្រះដោយតុលាការប្រជាជនបដិវត្តន៍ ហើយត្រូវបានផ្តន្ទាទោស *ដោយកំបាំងមុខ* ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មមួយចំនួនទៀត។ ជនជាប់ចោទត្រូវបានផ្តន្ទាទោសប្រហារជីវិត និងត្រូវរឹបអូសទ្រព្យសម្បត្តិរបស់ គាត់[២]។ នៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៩៦ ព្រះមហាក្សត្រនរោត្តម សីហនុ បានចេញព្រះរាជក្រឹត្យមួយដោយផ្តល់ដល់ជនជាប់ចោទនូវការលើកលែងទោស/អនុគ្រោះទោស ចំពោះការសម្រេចផ្តន្ទាទោសប្រហារជីវិត និងការរឹបអូសទ្រព្យសម្បត្តិដោយតុលាការប្រជាជនបដិវត្តន៍ និង ចំពោះទោសដែលបានកំណត់ដោយច្បាប់ឆ្នាំ ១៩៩៤ ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ ("ច្បាប់ឆ្នាំ ១៩៩៤")[៣]។ ជាការឆ្លើយតប ជនជាប់ចោទលើកឡើងថា រូបគាត់ រួមទាំងអ្នកផ្តាច់ខ្លួនតាមគាត់ជាច្រើនពាន់នាក់ បានធ្វើសមាហរណកម្មចូលក្នុងសង្គមកម្ពុជា ដែលការនេះបាន

---

[១] "សេចក្តីសង្ខេបអញ្ញត្រកម្មតាមវិធាន ៨៩ របស់លោក អៀង សារី និងការជូនដំណឹងនៃការមិនគោរពតាមអនុស្សរណៈក្រៅផ្លូវការនានានាពេលអនាគត ដែលត្រូវបានចេញជំនួសឱ្យសេចក្តីសម្រេចមានសំអាងហេតុរបស់តុលាការដែលជាកម្មវត្ថុបណ្តឹងឧទ្ធរណ៍" ឯកសារ E51/4ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១១ ("អញ្ញត្រកម្មរបស់ អៀង សារី") កថាខណ្ឌ ២២ និង ២៣។

[២] "សាលក្រមរបស់តុលាការប្រជាជនបដិវត្តន៍ដែលបានធ្វើឡើងនៅទីក្រុងភ្នំពេញ ពីថ្ងៃទី ១៥ ដល់ថ្ងៃទី ១៩ ខែ សីហា" ការបកប្រែជាភាសាអង់គ្លេសដែលត្រូវបានបោះពុម្ពផ្សាយនៅក្នុងឯកសារ "អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា ឯកសារនានាពីសវនាការប៉ុល ពត និង អៀង សារី" ឯកសារ C22/I/32 ទំព័រ ៥៤៩។

[៣] "ព្រះរាជក្រឹត្យ" ឯកសារ E51/8.1 ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៩៦ (សំណៅជាភាសាខ្មែរច្បាប់ដើមនៅក្នុងឯកសារ D366/7.1.191)។ ការរឹបអូសទ្រព្យសម្បត្តិរបស់ អៀង សារី ដែលជាការដាក់ទោស មិនត្រូវបានអនុវត្តទេ។

បញ្ចប់ជម្លោះរវាងកងកម្លាំងរាជរដ្ឋាភិបាល និងកងកម្លាំងរបស់គាត់[៤]។

៣. នៅគ្រាដំបូង អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថាបញ្ហានៃការលើកលែងទោស/អនុគ្រោះទោស និងគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* (*ne bis in idem*) ត្រូវបានជជែកតវ៉ាគ្នាយ៉ាងច្រើននៅចំពោះមុខ អ.វ.ត.ក។ នៅក្នុងដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២ មកទល់នឹងពេលនេះ សហចៅក្រមស៊ើបអង្កេត ("ក.ស.ច") និងអង្គបុរេជំនុំជម្រះ ("អ.ប.ជ") បានពិនិត្យឬនដងរួចមកហើយលើបញ្ហានានាពាក់ព័ន្ធនឹងព្រះរាជក្រឹត្យខាងលើ និងការផ្តន្ទាទោសឆ្នាំ ១៩៧៩ ដោយតុលាការប្រជាជនបដិវត្តន៍។ សហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ សុទ្ធតែបានសម្រេចដូចគ្នាថាបញ្ហាទាំងអស់នេះមិនរាំងរាំងដល់យុត្តាធិការរបស់ អ.វ.ត.ក ទៅលើជនជាប់ចោទ អៀង សារី ឡើយ។

៤. នៅថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ សហចៅក្រមស៊ើបអង្កេតបានចេញដីកាឃុំខ្លួនបណ្តោះអាសន្ន ដែលក្នុងនោះសហចៅក្រមស៊ើបអង្កេតបានយល់ឃើញថា ការផ្តន្ទាទោសឆ្នាំ ១៩៧៩ និងព្រះរាជ-ក្រឹត្យ មិនរាំងរាំងដល់ការចោទប្រកាន់ និងការឃុំខ្លួនជនជាប់ចោទនៅចំពោះមុខ អ.វ.ត.ក ឡើយ[៥]។ នៅពេលទទួលបានបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹងដីកានេះ អង្គបុរេជំនុំជម្រះបានបញ្ជាក់អះអាងអំពីការយល់ឃើញទាំងអស់នេះជាមួយនឹងសំអាងហេតុ នៅថ្ងៃ ទី ១៧ ខែ តុលា ឆ្នាំ ២០០៨[៦]។ ជាថ្មីម្តងទៀត សហចៅក្រមស៊ើបអង្កេតបានធ្វើការពិចារណាលើបញ្ហាទាំងអស់នេះនៅក្នុងដីកាដំណោះស្រាយ[៧] ដែលក្រោយមកអង្គបុរេជំនុំជម្រះក៏បានពិនិត្យយ៉ាងហ្មត់ចត់នៅ

---

[៤] ប្រតិចារិក ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១ (មេធាវីការពារក្តី អៀង សារី) ទំព័រ ២៤, ៨២។ ភ្ជាប់ទៅនឹង "សេចក្តីថ្លែងការណ៍របស់ អៀង សារី ទាក់ទងទៅនឹងវិសាលភាព ចេតនានៅពីក្រោយ និងសារៈតារនៃព្រះរាជទានទោស និងអនុគ្រោះទោស" ឯកសារ E84.1 ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១១។ រឿងរ៉ាវនេះត្រូវបានបញ្ជាក់តាមរយៈរឿងរ៉ាវតាមសារព័ត៌មាននៅពេលនោះ (*សូមមើល ឧទាហរណ៍* អត្ថបទកាសែត Bangkok Post ដែលមានចំណងជើងថា "សីហនុ លើក លែងទោស អៀង សារី" ឯកសារ D427/1/6.1.85 ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៦។ ភ្ជាប់ទៅនឹង "សេចក្តីថ្លែងការណ៍របស់ អៀង សារី ទាក់ទងទៅនឹងវិសាលភាព ចេតនានៅពីក្រោយ និងសារៈតារនៃព្រះរាជទានទោស និង អនុគ្រោះទោស" ឯកសារ E84.1 ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១១។

[៥] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ឯកសារ C22 ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ កថាខណ្ឌ ៥ ដល់ ១៤។

[៦] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនជនត្រូវចោទ អៀង សារី បណ្តោះអាសន្ន ឯកសារ C22/I/73 ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៨ កថាខណ្ឌ ៤១ ដល់ ៦៣។ ដីកាដំណោះស្រាយ ឯកសារ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ១៣២៩ ដល់ ១៣៣៤។

[៧] ដីកាដំណោះស្រាយ ឯកសារ D427 ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ១៣២៩ ដល់ ១៣៣៤។

ក្នុងសាលដីការបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ[៨]។

៥. នៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះបានច្រានចោលមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ដែលបានធ្វើឡើងដោយផ្អែកលើព្រះរាជក្រឹត្យឆ្នាំ ១៩៩៦[៩]។ អង្គបុរេជំនុំជម្រះបានពិចារណាឃើញថា វិសាលភាពនៃ "ការអនុគ្រោះទោសដល់ អៀង សារី ឱ្យរួចផុតពីការផ្តន្ទាទោសឆ្នាំ ១៩៧៩" ត្រូវបានកំណត់ត្រឹមទោសដែលត្រូវបានប្រកាសនៅឆ្នាំ ១៩៧៩។ ហេតុដូច្នេះ ប្រសិទ្ធភាពនៃការអនុគ្រោះទោសគឺគ្រាន់តែ "លុបចោល" ឬ "បំភ្លេចចោល" ទោសឆ្នាំ ១៩៧៩ តែប៉ុណ្ណោះ ហើយមិនរារាំងដល់ការចោទប្រកាន់នាពេលអនាគតពាក់ព័ន្ធនឹងអំពើទាំងឡាយដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តដោយ អៀង សារី នោះឡើយ។ អង្គបុរេជំនុំជម្រះបានលើកឡើងថែមទៀតថា ការអនុគ្រោះទោសឱ្យរួចផុតពីការចោទប្រកាន់នាថ្ងៃអនាគតនៅក្នុងព្រះរាជក្រឹត្យ ត្រូវបានកម្រិតត្រឹមការចោទប្រកាន់ចំពោះបទល្មើសដែលមានចែងនៅក្នុងច្បាប់ឆ្នាំ ១៩៩៤ ហើយមិនគ្របដណ្តប់ដល់បទល្មើសដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ឡើយ។ ច្បាប់ឆ្នាំ ១៩៩៤ បានបង្កើតបទល្មើសថ្មីៗ និងទណ្ឌកម្មថ្មីៗ ប៉ុន្តែគោលបំណងនៃច្បាប់នេះ គឺមិនមែនដើម្បីជំនួសការអនុវត្តច្បាប់ព្រហ្មទណ្ឌជាតិ និងអន្តរជាតិ ដែលមានជាធរមាននោះទេ។ ចំណុចចុងក្រោយ ការបកស្រាយព្រះរាជក្រឹត្យ ថាជាការផ្តល់ឱ្យ អៀង សារី នូវការអនុគ្រោះទោសចំពោះបទឧក្រិដ្ឋនានាដូចជាអំពើប្រល័យពូជសាសន៍ ការធ្វើទារុណកម្ម ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺមិនស្របជាមួយកាតព្វកិច្ចតាមសន្ធិសញ្ញាអន្តរជាតិរបស់ប្រទេសកម្ពុជាក្នុងការកាត់ទោស និងដាក់ទោសចារីនៃបទឧក្រិដ្ឋបែបនេះ និងកាតព្វកិច្ចរបស់ប្រទេសនេះក្នុងការផ្តល់ដំណោះស្រាយប្រកបដោយប្រសិទ្ធភាពដល់ជនរងគ្រោះឡើយ។ ដោយមិនមានការបង្ហាញណាមួយដែលថា ព្រះមហាក្សត្រមានចេតនាមិនអើពើទៅលើកាតព្វកិច្ចជាអន្តរ-

---

[៨] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/1/30 ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ("សាលដីការបស់អង្គបុរេជំនុំជម្រះ") កថាខណ្ឌ ១១៨ ដល់ ១៧៦, ១៨៤ ដល់ ២០២ ("សាលដីការបស់អង្គបុរេជំនុំជម្រះ")។

[៩] សាលដីការបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ១៨៤ ដល់ ២០២។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញថា ពាក្យខ្មែរសម្រាប់ការអនុគ្រោះទោសត្រូវបានប្រើប្រាស់មិនស៊ីសង្វាក់គ្នាទេ ហើយអង្គបុរេបានផ្តល់នូវការបកប្រែព្រះរាជក្រឹត្យដោយផ្ទាល់ ដោយបុរេជំនុំជម្រះ យល់ឃើញថា ព្រះរាជក្រឹត្យបានផ្តល់នូវ "ការអនុគ្រោះ" ពីរយ៉ាង ដល់ អៀង សារី: "ការលើកលែងទោស [...] ដែលត្រូវបានផ្តន្ទាទោសប្រហារជីវិតបង់ និងរឹបអូសទ្រព្យសម្បត្តិទាំងអស់តាមអំណាចសាលក្រមរបស់តុលាការប្រជាជនបដិវត្តន៍ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៧៩ និងចំពោះទោសដែលបានកំណត់ដោយច្បាប់ឆ្នាំ ១៩៩៤" (ការបញ្ជាក់បន្ថែម)។

ជាតិរបស់ប្រទេសកម្ពុជានោះ គេមិនអាចធ្វើការបកស្រាយថា ព្រះរាជក្រឹត្យ បានផ្តល់នូវការអនុគ្រោះទោសចំពោះឧក្រិដ្ឋកម្មអន្តរជាតិទាំងអស់នេះបានឡើយ[១០]។

៦. អង្គបុរេជំនុំជម្រះក៏បានលើកឡើងផងដែរថា ការកាត់ទោស អៀង សារី នាពេលក្រោយមកទៀតដោយ អ.វ.ត.ក មិនត្រូវបានរារាំងដោយ *គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* (*ne bis in idem*) នោះទេ[១១]។ មាត្រា ១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("CPC") ត្រូវ តែមានន័យថាអាចអនុវត្តចំពោះតែអ្នកដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរតែប៉ុណ្ណោះ[១២]។ អង្គបុរេជំនុំជម្រះក៏បានប្រកាសថាមាត្រា ១៤(៧) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR") មិនអាចយកមកអនុវត្តបានទេ ពីព្រោះបទបញ្ញត្តិនេះមានអានុភាពអនុវត្តត្រឹមកម្រិតជាតិតែមួយប៉ុណ្ណោះ មិនអាចអនុវត្តជាអន្តរជាតិឬមិនអនុវត្តចំពោះកិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការដែលមានចរិតអន្តរជាតិដូចជា អ.វ.ត.ក នេះឡើយ[១៣]។

៧. ក្នុងការវាយតម្លៃអំពីវិធាននីតិវិធីដែលត្រូវបានបង្កើតឡើងនៅកម្រិតអន្តរជាតិ អង្គបុរេជំនុំជម្រះបានលើកឡើងថា មានវិធានស្របគ្នាគ្រប់គ្រាន់ក្នុងការសម្រេចបានថា នៅពេលមានកំហុសជាមូលដ្ឋាននៅក្នុងកិច្ចដំណើរការនីតិវិធីជាតិ គោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* (*ne bis in idem*) មិនយកមកអនុវត្តបានទេ[១៤]។ បន្ទាប់ពីពិនិត្យទៅលើការជំនុំជម្រះឆ្នាំ ១៩៧៩ អង្គបុរេជំនុំជម្រះបានយល់ឃើញថា ទោះបីជាមានចេតនាក្នុងការចោទប្រកាន់ និងផ្តន្ទាទោសជនជាប់ចោទក៏ដោយ ក៏ការជំនុំជម្រះក្តីឆ្នាំ ១៩៧៩ មិនត្រូវបានធ្វើឡើងដោយតុលាការ

---

[១០] សាលដីការបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ១៩១ ដល់ ២០១។

[១១] សាលដីការបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ១១៨ ដល់ ១៧៦។

[១២] មាត្រា ១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៧ ចែងថា "ដោយអនុវត្តតាមគោលការណ៍អាជ្ញាអស់ជំនុំ ជនណាដែលត្រូវបាន តុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេចំពោះអំពើដែលទោះបីក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ"។

[១៣] មាត្រា ១៤(៧) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៦៦ 999 U.N.T.S. 171 ដែលត្រូវបានផ្តល់សច្ចាប័នដោយប្រទេសកម្ពុជា នៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៩២ ("ICCPR") ចែងថា "គ្មានជនណាម្នាក់ត្រូវយកមកចោទប្រកាន់ ឬយកមកផ្តន្ទាទោសសារជាថ្មីឡើយ ចំពោះបទល្មើសដែលបានផ្តន្ទាទោសជាស្ថាពរ ឬបានលើកលែងទោសស្របតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋនីមួយៗរួចហើយ"។ សាលដីការបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ១៣០ ដល់ ១៣១។

[១៤] សាលដីការបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ១២២ ដល់ ១៥៨។

មួយដែលប្រកបដោយអនាគតិ និងឯករាជ្យសមស្របទៅតាមលក្ខខណ្ឌច្បាប់តម្រូវនោះទេ។ ដូច្នេះ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថាការចោទប្រកាន់ និង ការផ្តន្ទាទោសដោយតុលាការប្រជាជនបដិវត្តន៍លើជនជាប់ចោទមិនរារាំងដល់យុត្តាធិការរបស់ អ.វ.ត.ក លើជនជាប់ចោទឡើយ។ មូលដ្ឋាននៃការសម្រេចរបស់អង្គបុរេជំនុំជម្រះរួមមាន៖

- មូលដ្ឋានគតិយុត្តដែលជាចំណោទបញ្ហាសម្រាប់ការបង្កើតតុលាការប្រជាជនបដិវត្តន៍។
- គ្មានការធានាគ្រប់គ្រាន់នៅចំពោះមុខតុលាការប្រជាជនបដិវត្តន៍អំពីការបែងចែកអំណាចដាច់ពីគ្នា ដើម្បីធានាថា ចៅក្រមមិនរងការដាក់សម្ពាធ និងការជ្រៀតជ្រែកពីខាងក្រៅ (ក្រឹត្យ-ច្បាប់ដែលបង្កើតតុលាការប្រជាជនបដិវត្តន៍ មានសរសេរអំពីទស្សនៈយល់ឃើញអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ ហើយសមាជិកជាច្រើនក្នុងចំណោមសមាជិករបស់តុលាការប្រជាជនបដិវត្តន៍ សុទ្ធតែជាប់ពាក់ព័ន្ធទៅនឹងអង្គនីតិប្រតិបត្តិរបស់រដ្ឋាភិបាល)។
- សមាជិកជាច្រើនរូបរបស់តុលាការប្រជាជនបដិវត្តន៍មិនមានភាពអនាគតិ។
- មេធាវីការពារក្តីដែលត្រូវបានតែងតាំងឱ្យការពារជនជាប់ចោទ *នៅក្នុងសវនាការកំបាំងមុខនេះ* បានបង្ហាញនូវភាពលម្អៀង និងបានបំពេញតួនាទីប្រឆាំងនឹងជនជាប់ចោទ។
- មានភាពខ្វះខាតផ្សេងៗនៅក្នុងចម្លើយសាក្សីដែលតុលាការប្រជាជនបដិវត្តន៍ បានយកមកធ្វើជាសំអាង។
- កិច្ចដំណើរការនីតិវិធីមានរយៈពេលខ្លី រីឯកាលវិភាគសម្រាប់ការងាររបស់តុលាការប្រជា-ជនបដិវត្តន៍បានបង្ហាញឲ្យឃើញថា ពិរុទ្ធភាពត្រូវបានសម្រេចទុកជាមុនរួចហើយ [១៥]។

៨. នៅថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១១ អៀង សារី បានដាក់សេចក្តីថ្លែងការណ៍មួយទាក់ទិនទៅនឹងវិសាលភាព ចេតនានៅពីក្រោយ និងប្រវត្តិសាវតារនៃព្រះរាជក្រឹត្យឆ្នាំ ១៩៩៦[១៦]។ យោងតាមសេចក្តីថ្លែងការណ៍នេះ៖

នៅមុនពេលធ្វើកិច្ចពិភាក្សាទៅលើបញ្ហាសមាហរណកម្មនេះ [អៀង សារី និងក្រុមយោធាមួយចំនួនទៀតដែលបានបំបែកខ្លួនចេញពី ប៉ុល ពត] បានពិភាក្សាជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជាអំពី

---

[១៥] សាលដីការបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ១៦៥, ១៦៧, ១៦៩ ដល់ ១៧៤។

[១៦] "សេចក្តីថ្លែងការណ៍របស់លោក អៀង សារី ទាក់ទងទៅនឹងវិសាលភាព ចេតនានៅពីក្រោយ និងសាវតារនៃព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស" ឯកសារ E84 ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១១ និងឧបសម្ព័ន្ធ (ឯកសារ E84.1)។

ភាពចាំបាច់ឱ្យមានការធានាមួយថា [អៀង សារី] នឹងត្រូវបានការពារប្រឆាំងនឹងការចោទប្រកាន់គ្រប់រូបភាពចំពោះអំពើនានាដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលដែល [គាត់]ជាសមាជិករបស់ខ្មែរក្រហម។ គេបានសង្កត់ធ្ងន់ថា [គាត់] ដាច់ខាតត្រូវតែមានការលើកលែងទោស ពីការផ្តន្ទាទោសឆ្នាំ ១៩៧៩ ហើយត្រូវតែមានការអនុគ្រោះទោស ចំពោះរាល់ការចោទប្រកាន់ណាដែលអាចមាននាពេលអនាគតទៅលើអំពើដែល[គាត់] បានប្រព្រឹត្ត រួមទាំងអំពើនានាដែលត្រូវបានយកមកកាត់សេចក្តីនៅក្នុងសវនាការឆ្នាំ ១៩៧៩។ ចំណុចនេះគឺជាលក្ខខណ្ឌមួយដែលមិនអាចចរចាបានឡើយសម្រាប់ការធ្វើសមាហរណកម្ម[១៧]។

៩. នៅថ្ងៃដែល មេធាវីការពារក្តី អៀង សារី បានស្នើសុំឱ្យអង្គជំនុំជម្រះកោះអញ្ជើញសម្តេចព្រះវររាជបិតា នរោត្តម សីហនុ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ និង សម្តេច ជា ស៊ីម ដើម្បីមកផ្តល់សក្ខីកម្មក្នុងអំឡុងពេលសវនាការបឋមពាក់ព័ន្ធនឹង "សារតារ វិសាលភាព និងគោលបំណងដែលនៅពីក្រោយព្រះរាជក្រឹត្យឆ្នាំ ១៩៩៦"[១៨]។ សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងសំណើនេះ ដោយហេតុថា អត្ថន័យនៃព្រះរាជក្រឹត្យមានភាពច្បាស់លាស់គ្រប់គ្រាន់ ដែលមិនចាំបាច់មានការសាកសួរដេញដោលសាក្សីណាមួយលើបញ្ហានេះទេ និងដោយហេតុថា សំណើនេះបានធ្វើឡើងមុនពេលមានការសម្រេចរបស់អង្គជំនុំជម្រះពាក់ព័ន្ធនឹងបញ្ហាថាតើការអនុគ្រោះទោសអាចគ្របដណ្តប់ដោយស្របច្បាប់លើអំពើប្រល័យពូជសាសន៍ និងបទឧក្រិដ្ឋផ្សេងៗទៀត ដែលមាននៅក្នុងដីកាដំណោះស្រាយដែរ ឬយ៉ាងណា[១៩]។

---

[១៧] ឧបសម្ព័ន្ធភ្ជាប់ទៅនឹងសេចក្តីថ្លែងការណ៍របស់លោក អៀង សារី ទាក់ទងទៅនឹងវិសាលភាពចេតនានៅពីក្រោយ និងសារតារនៃ ព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស ឯកសារ E84.1 ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១១។ *សូមមើលផងដែរ* ប្រតិចារិក ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១ (មេធាវីការពារក្តី អៀង សារី) ទំព័រ ១៧។

[១៨] "ញត្តិរបស់លោក អៀង សារី សុំយាង និងកោះអញ្ជើញសម្តេចព្រះវររាជបិតា នរោត្តម សីហនុ, សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន, ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ និងសម្តេច ជា ស៊ីម" ឯកសារ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១១ ("ញត្តិរបស់ អៀង សារី សុំយាង និងកោះអញ្ជើញសាក្សី")។ "សេចក្តីបន្ថែមចំពោះញត្តិរបស់ អៀង សារី សុំយាង និងកោះអញ្ជើញសាក្សីនានា" ឯកសារ E85/2 ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១១។ *សូមមើលផងដែរ* ប្រតិចារិក ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១ (មេធាវីការពារក្តី អៀង សារី) ទំព័រ ២៦ ដល់ ២៨, ៧៦ ដល់ ៧៧។

[១៩] ប្រតិចារិក ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១ (មេធាវីការពារក្តី អៀង សារី) ទំព័រ ៣៨ ដល់ ៣៩, ៥១។ ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងញត្តិរបស់ អៀង សារី សុំយាង និងកោះអញ្ជើញសាក្សីនានា ឯកសារ E85/4 ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១១។ សូមមើលផងដែរ របៀបវារៈសម្រាប់សវនាការបឋម ឯកសារ E86/1 ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១១ កថាខណ្ឌ ៣ (កត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមិនមានចេតនាធ្វើការសួរដេញដោលសាក្សីនានាដែលត្រូវបានស្នើសុំដោយមេធាវីការពារក្តី អៀង សារី ដើម្បីគាំទ្រអញ្ញត្រកម្មរបស់ខ្លួននៅក្នុងពេលសវនាការបឋមនោះទេ)។

១០. នៅថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១១ អង្គជំនុំជម្រះបានអញ្ជើញមេធាវីការពារក្តី អៀង សារី ឱ្យដាក់សារណាពាក់ព័ន្ធតែចំពោះទឡ្ហីករណ៍ថ្មីៗកើតចេញមកពីសាលដីការបស់អង្គបុរេជំនុំជម្រះ បន្ថែមពីលើ "បញ្ហាថាតើព្រះរាជក្រឹត្យដែលមានបំណងផ្តល់ការអនុគ្រោះទោសដែលបានចេញដោយព្រះមហាក្សត្រ ត្រូវបានអនុម័តនៅពេលបន្ទាប់ដោយសម្លេងគាំទ្រដូចមានចែងដោយច្បាប់រដ្ឋធម្មនុញ្ញ (នៅក្នុងមាត្រា ៩០ ថ្មី) ដែរ ឬទេ" [២០]។

១១. ដោយសារមានសំណៅបកប្រែក្រៅផ្លូវការខុសគ្នាមួយចំនួននៃព្រះរាជក្រឹត្យដែលមាននៅក្នុងសំណុំរឿង អង្គជំនុំជម្រះសាលាដំបូងបានដាក់សំណៅបកប្រែថ្មីមួយនៃព្រះរាជក្រឹត្យដែលអង្គភាពបកប្រែភាសាបានបកប្រែតាមសំណើរបស់អង្គជំនុំជម្រះសាលាដំបូង។ ការបកប្រែនេះមានខ្លឹមសារថា:

> ត្រូវបានលើកលែងទោសឲ្យលោក អៀង សារី [...] ដែលត្រូវបានផ្តន្ទាទោសប្រហារជីវិត និងរឹបអូសទ្រព្យសម្បត្តិទាំងអស់តាមអំណាចសាលក្រមរបស់ [តុលាការប្រជាជនបដិវត្តន៍] ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៧៩ និងចំពោះទោសដែលបានកំណត់ដោយ [ច្បាប់ឆ្នាំ ១៩៩៤] [២១]។

---

[២០] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងមានចំណងជើងថា "ការដាក់អញ្ញត្រកម្មបន្ថែម (ការលើកលែងទោស និងការអនុគ្រោះទោស)" ឯកសារ E51/8 ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១១។ *សូមមើលផងដែរ* អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា "សេចក្តីណែនាំដល់ភាគីពាក់ព័ន្ធនឹងអញ្ញត្រកម្ម និងបញ្ហាពាក់ព័ន្ធ" ឯកសារ E51/7 ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១។ មានការផ្តល់ឱកាសបន្ថែមដើម្បីលើកឡើងនូវបញ្ហាទាំងអស់នេះនៅពេលសវនាការបឋម (*សូមមើល* របៀបវារៈសម្រាប់សវនាការបឋម ឯកសារ E86/1 ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១១។ ប្រតិចារឹក ចុះថ្ងៃទី ២៧ ដល់ ២៨ ខែ មិថុនា ឆ្នាំ ២០១១)។

[២១] "ព្រះរាជក្រឹត្យរបស់ព្រះមហាក្សត្រ នរោត្តម សីហនុ ពាក់ព័ន្ធនឹង "ការលើកលែងទោសដែលបានផ្តល់ឲ្យលោក អៀង សារី"" ឯកសារ E51/8.1។ ដោយមានភាពមិនច្បាស់លាស់នៅក្នុងន័យពាក្យខ្មែរ "លើកលែងទោស" (ដែលមានន័យថា "លើកលែងទោស") និងភាពមិនស៊ីសង្វាក់គ្នានៅក្នុងការបកប្រែ មេធាវីការពារក្តី អៀង សារី បានជម្រុញឲ្យអង្គជំនុំជម្រះធ្វើការបកស្រាយព្រះរាជក្រឹត្យដោយគិតពីការអនុគ្រោះបំផុតដល់ជនជាប់ចោទ ឬធ្វើការពិចារណាអំពីចេតនារបស់អ្នកធ្វើសេចក្តីព្រាងព្រះរាជក្រឹត្យ និងអ្នកធ្វើការចចារ រួមទាំង អៀង សារី (សូមមើល "សារណាបន្ថែមរបស់ លោក អៀង សារី លើអញ្ញត្រកម្មរបស់គាត់ដែលធ្វើតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (ការលើកលែងទោស និងការអនុគ្រោះទោស)" ឯកសារ E51/10 ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១១ ("សារណាបន្ថែមរបស់លោក អៀង សារី ស្តីពីការលើកលែងទោស និងការអនុគ្រោះទោស") កថាខណ្ឌ ៣ ដល់ ៨, ២៥, ៣៥ ដល់ ៣៩។ "សេចក្តីថ្លែងការណ៍របស់លោក អៀង សារី ពាក់ព័ន្ធនឹងវិសាលភាព ចេតនានៅពីក្រោយ និងសារតារ នៃព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស" ចុះថ្ងៃទី០៥ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារ E84.1។ សហ-ព្រះរាជអាជ្ញាលើកឡើងថា បរិបទនៃព្រះរាជក្រឹត្យមិនផ្លាស់ប្តូរទេ ផ្អែកតាមឯកសារបកប្រែដែលត្រូវបានប្រើប្រាស់ ពីព្រោះពាក្យខ្មែរ "លើកលែងទោស" មានន័យថាការអនុគ្រោះទោសផង និងការលើកលែងទោសផង។ ការប្រើពាក្យការលើកលែងទោស

## ៣. សារណារបស់ភាគី

### ៣.១. ការអនុគ្រោះទោស និងការលើកលែងទោស

#### ៣.១.១. មេធាវីការពារក្តី អៀង សារី

១២. មេធាវីការពារក្តី អៀង សារី លើកឡើងថា អ.វ.ត.ក មិនមានយុត្តាធិការលើជនជាប់ចោទនោះទេ ដោយសារតែព្រះរាជក្រឹត្យ ឆ្នាំ ១៩៩៦ របស់ព្រះមហាក្សត្រ បានផ្តល់ឲ្យគាត់នូវការលើកលែងទោសផង និងការអនុគ្រោះទោសផង[២២]។ អង្គជំនុំជម្រះសាលាដំបូងមានយុត្តាធិការក្នុងការពិចារណាតែលើវិសាលភាពនៃការអនុគ្រោះទោស និងការលើកលែងទោសប៉ុណ្ណោះ ប៉ុន្តែមិនត្រូវពិចារណាលើសុពលភាពនៃការអនុគ្រោះទោស និងការលើកលែងទោសនោះទេ។ ព្រះមហាក្សត្របានផ្តល់នូវការអនុគ្រោះទោស និងការលើកលែងទោសទាំងនេះ ដោយស្របច្បាប់ អនុលោមតាមមាត្រា ២៧ នៃច្បាប់រដ្ឋធម្មនុញ្ញ[២៣]។ មាត្រា ៩០ នៃច្បាប់រដ្ឋធម្មនុញ្ញ អនុវត្តតែនៅក្នុងករណីនៃច្បាប់អនុគ្រោះទោសទូទៅប៉ុណ្ណោះ មានន័យថា សម្លេងគាំទ្រជាផ្លូវការដោយរដ្ឋសភាជាតិ មិនចាំបាច់មានទេនៅក្នុងករណីរបស់ អៀង សារី[២៤]។ យ៉ាងណាក៏ដោយ មតិភាគច្រើនពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូលបានអនុម័តលើការអនុគ្រោះទោស និងការលើកលែងទោស

---

នៅក្នុងផ្នែកទីមួយនៃព្រះរាជក្រឹត្យ និងពាក្យការអនុគ្រោះទោសនៅក្នុងផ្នែកបន្ទាប់ គឺជាការបកប្រែដែលត្រឹមត្រូវតាមបរិការណ៍បំផុត ប៉ុន្តែពាក្យដែលប្រើមានអានុភាពគតិយុត្តដូចគ្នានៅក្នុងបរិបទរបស់វា ("ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងអញ្ញត្រកម្ម បន្ថែមរបស់ អៀង សារី តាមវិធាន ៨៩ (*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* និងការលើកលែងទោស និងការអនុគ្រោះទោសរបស់ព្រះមហាក្សត្រ") ឯកសារ E51/13 ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១១ ("ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងអញ្ញត្រកម្មបន្ថែមរបស់ អៀង សារី") កថាខណ្ឌ ២១ ដល់ ២៨។ ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១ (សហព្រះរាជអាជ្ញា) ទំព័រ ៣៥ ដល់ ៣៨)។

[២២] សារណាបន្ថែមរបស់លោក អៀង សារី ស្តីពីការលើកលែងទោស និងការអនុគ្រោះទោស។ *សូមមើលផងដែរ* អញ្ញត្រកម្មរបស់ អៀង សារី កថាខណ្ឌ ២២។

[២៣] សារណាបន្ថែមរបស់លោក អៀង សារី ស្តីពីការលើកលែងទោស និងការអនុគ្រោះទោស កថាខណ្ឌ ៩ ដល់ ១០ (ដែលលើកឡើងបន្ថែមទៀតថា សុពលភាពនៃព្រះរាជក្រឹត្យអាចត្រូវបានពិនិត្យមើលឡើងវិញដោយក្រុមប្រឹក្សាធម្មនុញ្ញតែមួយប៉ុណ្ណោះ)។ សូមមើលផងដែរ ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១ (មេធាវីការពារក្តី អៀង សារី) ទំព័រ ១៨ ដល់ ១៩។

[២៤] មាត្រា ៩០ នៃរដ្ឋធម្មនុញ្ញ ១៩៩៣ ចែងថា "រដ្ឋសភាអនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ" (សំណៅបកប្រែក្រៅផ្លូវការ ខែ មីនា ឆ្នាំ ២០១០ ដែលត្រូវបានត្រួតពិនិត្យដោយក្រុមប្រឹក្សាធម្មនុញ្ញ)។

ហេតុដូច្នេះការផ្ដល់នេះស្របតាមរដ្ឋធម្មនុញ្ញ[២៥]។

១៣. ជាលទ្ធផលនៃការលើកលែងទោសរបស់ខ្លួន អៀង សារី លើកឡើងថា គាត់មិនត្រូវទទួលទោសណាមួយចំពោះអំពើនានាដែលត្រូវចោទប្រកាន់នៅក្នុងការកាត់សេចក្ដីឆ្នាំ ១៩៧៩ ឡើយ[២៦]។ គាត់ថែមទាំងបានលើកឡើងទៀតថា រូបគាត់ត្រូវបានការពារឲ្យរួចផុតពីកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ដោយសារតែមានការលើកលែងមិនឲ្យចោទប្រកាន់នូវបទល្មើសនានាតាមច្បាប់ឆ្នាំ ១៩៩៤។ មេធាវីការពារក្ដី បានធ្វើការវិភាគលម្អិតលើច្បាប់ឆ្នាំ ១៩៩៤ និងបុព្វកថានៃច្បាប់នេះ ដើម្បីបង្ហាញថា ច្បាប់នេះគ្របដណ្ដប់លើរាល់បទឧក្រិដ្ឋទាំងអស់ដែលមាននៅក្នុងដីកាដំណោះស្រាយ[២៧]។ ការអនុគ្រោះទោសឆ្នាំ ១៩៩៦ ក៏បាន បង្កើតជាករណីលើកលែងមួយផងដែរ ដែលបានអនុញ្ញាតឲ្យ អៀង សារី ទទួលបានផលប្រយោជន៍ពីការអនុគ្រោះទោស ដែលមាននៅក្នុងច្បាប់ឆ្នាំ ១៩៩៤ ទោះបីជាគាត់មានតួនាទីជាថ្នាក់ដឹកនាំ និងទោះជាបទប្បញ្ញត្តិស្ដីពីការអនុគ្រោះទោសនៃច្បាប់មួយនេះបានផុតរលត់ហើយក៏ដោយ[២៨]។

១៤. លើសពីនេះទៀត អ.វ.ត.ក ក្នុងនាមជាតុលាការជាតិមួយ ត្រូវគោរពច្បាប់កម្ពុជា[២៩]។ ការអនុគ្រោះទោសអាចអនុវត្តបានចំពោះ "*ឧក្រិដ្ឋកម្ម អាជ្ញាបញ្ញា (jus cogens crimes)*" ពីព្រោះពុំមានការហាមឃាត់នៅក្នុងច្បាប់ អ.វ.ត.ក រដ្ឋធម្មនុញ្ញ ឬច្បាប់អន្តរជាតិ ដែលរារាំងការអនុវត្តការអនុគ្រោះទោសទាំងនោះទេ[៣០]។ ខ្លឹមសារនៃបទដ្ឋានទាំងអស់នេះគួរតែត្រូវបានធ្វើការវាយតម្លៃនៅ

---

[២៥] សារណាបន្ថែមរបស់លោក អៀង សារី ស្ដីពីការលើកលែងទោស និងការអនុគ្រោះទោស កថាខណ្ឌ ១០-១២។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១ (មេធាវីការពារក្ដី អៀង សារី) ទំព័រ ១៧ ដល់ ១៨។

[២៦] សារណាបន្ថែមរបស់លោក អៀង សារី ស្ដីពីការលើកលែងទោស និងការអនុគ្រោះទោស កថាខណ្ឌ ២៥។

[២៧] សារណាបន្ថែមរបស់លោក អៀង សារី ស្ដីពីការលើកលែងទោស និងការអនុគ្រោះទោស កថាខណ្ឌ ២៦ ដល់ ៣៤។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១ (មេធាវីការពារក្ដី អៀង សារី) ទំព័រ ១៩។

[២៨] ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១ (មេធាវីការពារក្ដី អៀង សារី) ទំព័រ ២៩។

[២៩] សារណាបន្ថែមរបស់លោក អៀង សារី ស្ដីពីការលើកលែងទោស និងការអនុគ្រោះទោស កថាខណ្ឌ ១៦ ដល់ ១៨ (ដោយលើកឡើងថា ក្នុងករណីណាក៏ដោយ ភាពមិនស្របគ្នាជាមួយនឹងកាតព្វកិច្ចជាអន្តរជាតិនឹងមិនធ្វើឲ្យការលើកលែងទោសគ្មានសុពលភាពនោះឡើយ)។

[៣០] សារណាបន្ថែមរបស់លោក អៀង សារី ស្ដីពីការលើកលែងទោស និងការអនុគ្រោះទោស កថាខណ្ឌ ១៣ ដល់ ១៤, ១៦ ដល់ ២៣។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១ (មេធាវីការពារក្ដី អៀង សារី) ទំព័រ ២៥ ដល់២៦, ៣១, ៧៩ ដល់ ៨១ (ដោយលើកឡើងថា ទោះបីជាមិនបានអើពើនឹងកាតព្វកិច្ចក្នុងការកាត់ទោសក៏ដោយ តែរដ្ឋនានាមានអំណាចឆន្ទានុសិទ្ធិក្នុងការផ្ដល់នូវការអនុគ្រោះទោស)។

00751109



ពេលដែលការអនុគ្រោះទោស ត្រូវបានផ្តល់ ឱ្យនៅឆ្នាំ ១៩៩៦ នោះ[៣១]។ ការអនុគ្រោះទោស ដែលត្រូវបានផ្តល់ឱ្យតែចំពោះបុគ្គលម្នាក់នោះ ក៏មានវិសាលភាពតូចចង្អៀតណាស់ដែរ ហេតុដូច្នេះហើយការអនុគ្រោះទោសនេះមិនបំពានលើនិយាមអន្តរជាតិទេ[៣២]។ អង្គការសហប្រជាជាតិ កាលពីអតីតកាល ក៏ធ្លាប់បានទទួលស្គាល់ ការអនុគ្រោះទោសកម្រិតជាតិមួយចំនួនផងដែរ ដោយបានចាត់ទុកថាអាចជួយបំពេញមុខងារនៃការបង្កើតសន្តិភាព និងការបង្រួបបង្រួមជាតិ[៣៣]។ បន្ថែមពីលើនេះទៀត ការកាត់សេចក្តីមិនមែនជាមធ្យោបាយតែមួយគត់ក្នុងការផ្តល់ដំណោះស្រាយដ៏មានប្រសិទ្ធភាពសម្រាប់ជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរនោះឡើយ[៣៤]។

១៥. ជាចុងក្រោយ មេធាវីការពារក្តីអះអាងថា បើទោះជាព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស ត្រូវបានផ្តល់ឱ្យក្នុងអំឡុងពេលស្ថានភាពមានជម្លោះមែន ប៉ុន្តែ ព្រះរាជក្រឹត្យបាននាំមកនូវការបញ្ចប់ការបង្ហូរឈាម ដែល "ប្រជាជនកម្ពុជាភាគច្រើនបានគាំទ្រ" ហេតុដូច្នេះហើយ ការផ្តល់ការអនុគ្រោះទោស និងការលើកលែងទោសនេះ គឺជាការចាំបាច់ និងសមស្រប[៣៥]។

*__៣.១.២. សហព្រះរាជអាជ្ញា__*

១៦. សហព្រះរាជអាជ្ញាលើកឡើងថា អនុលោមតាមមាត្រា ៤០ ថ្មី នៃច្បាប់ អ.វ.ត.ក អង្គជំនុំជម្រះមានសមត្ថកិច្ចសម្រេចលើសុពលភាពផង និងលើវិសាលភាពនៃព្រះរាជក្រឹត្យអនុគ្រោះទោស និងលើកលែងទោសផង[៣៦]។ សហព្រះរាជអាជ្ញាអះអាងថា ការលើកលែងទោសនៅក្នុងព្រះរាជក្រឹត្យត្រូវបានកម្រិតយ៉ាងច្បាស់លាស់ចំពោះទោសប្រហារជីវិត និងការរឹបអូសទ្រព្យសម្បត្តិដែលបង្គាប់ដោយតុលាការប្រជាជនបដិវត្តន៍ នៅឆ្នាំ ១៩៧៩។ ការអនុគ្រោះទោសអនុវត្តតែចំពោះការចោទប្រកាន់ណាមួយលើអំពើរំលោភបំពានច្បាប់ឆ្នាំ ១៩៩៤ នាថ្ងៃអនាគតប៉ុណ្ណោះ ពោលគឺអំពើដែល

---

[៣១] ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១ (មេធាវីការពារក្តី អៀង សារី) ទំព័រ ៨០ ដល់ ៨១។

[៣២] ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១ (មេធាវីការពារក្តី អៀង សារី) ទំព័រ ២៣។

[៣៣] ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១ (មេធាវីការពារក្តី អៀង សារី) ទំព័រ ២៥, ៨១-៨២។ សារណាបន្ថែមរបស់លោក អៀង សារី ស្តីពីការលើកលែងទោស និងការអនុគ្រោះទោស កថាខណ្ឌ ១៥។

[៣៤] សារណាបន្ថែមរបស់លោក អៀង សារី ស្តីពីការលើកលែងទោស និងការអនុគ្រោះទោស កថាខណ្ឌ ១៤។

[៣៥] ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១ (មេធាវីការពារក្តី អៀង សារី) ទំព័រ ២២, ៨១ ដល់ ៨២។

[៣៦] "ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ" ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១ ដោយបូកជាមួយច្បាប់វិសោធនកម្មដែលបានប្រកាសឱ្យប្រើ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ (នស/រកម/១០០៤/០០៦) ("ច្បាប់ អ.វ.ត.ក")។

ត្រូវបានកំណត់ថា ជាបទឧក្រិដ្ឋមួយដោយសារធ្លាប់ជាសមាជិកនៃ "ក្រុមកម្ពុជាប្រជាធិបតេយ្យ" ។ ច្បាប់នេះមិនរារាំងដល់ការកាត់សេចក្តីលើបទឧក្រិដ្ឋទាំងឡាយដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយនោះទេ[៣៧]។

១៧. លើសពីនេះទៀត ការលើកលែងទោស និងការអនុគ្រោះទោសសម្រាប់ *ឧក្រិដ្ឋកម្មអាជ្ញាបញ្ញា (jus cogens crimes)* ដូចជា អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ពុំមានសុពលភាពឡើយក្នុងច្បាប់អន្តរជាតិ និងមិនចងកាតព្វកិច្ច អ.វ.ត.ក នេះឡើយ។ តុលាការនេះ ដែលជាតុលាការមានចរិតលក្ខណៈជាតុលាការអន្តរជាតូបនីយកម្ម ដែលមានលទ្ធភាពអនុវត្តច្បាប់អន្តរជាតិដោយផ្ទាល់នោះ មានកាតព្វកិច្ច ឬឆន្ទានុសិទ្ធិតាមច្បាប់អន្តរជាតិ ក្នុងការមិនទទួលស្គាល់ការលើកលែងទោសចំពោះ *ឧក្រិដ្ឋកម្មអាជ្ញាបញ្ញា (jus cogens crimes)* ដោយមិនចាំបាច់គិតពីសុពលភាព ឬរដ្ឋធម្មនុញ្ញភាពនៃការលើកលែងនោះទេ[៣៨]។ និយាមអន្តរជាតិជាធរមាន ហាមឃាត់នូវការអនុគ្រោះទោសចំពោះឧក្រិដ្ឋកម្មទាំងឡាយ ដូចជា អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មធ្ងន់ធ្ងរផ្សេងទៀត ហើយ អ.វ.ត.ក មានកាតព្វកិច្ចគាំទ្រការប្តេជ្ញារបស់អង្គការសហប្រជាជាតិ ក្នុងការប្រយុទ្ធប្រឆាំងនឹងនិទ្ទណ្ឌភាពចំពោះឧក្រិដ្ឋកម្មទាំងអស់នេះ[៣៩]។

### <u>៣.១.៣.</u> <u>*ដើមបណ្តឹងរដ្ឋប្បវេណី*</u>

១៨. ដើមបណ្តឹងរដ្ឋប្បវេណីអះអាងថាព្រះរាជក្រឹត្យនេះខុសច្បាប់ ពីព្រោះយោងតាមរដ្ឋធម្មនុញ្ញព្រះមហាក្សត្រមានតែអំណាចក្នុងការផ្តល់ការលើកលែងទោសប៉ុណ្ណោះ មិនមែនផ្តល់ការអនុគ្រោះទោសចំពោះការចោទប្រកាន់នាពេលអនាគតឡើយ។ វិសាលភាពនៃការលើកលែងទោសត្រូវបានកម្រិតចំពោះទោសរបស់ អៀង សារី នៅចំពោះមុខតុលាការប្រជាជនបដិវត្តន៍។ ការអនុគ្រោះទោសចំពោះឧក្រិដ្ឋកម្មអន្តរជាតិនានា ដែលមានឋានៈជា *អាជ្ញាបញ្ញារ (jus cogens)* គឺមិនស្របជាមួយនឹងកាតព្វកិច្ចជាអន្តរជាតិក្នុងការកាត់សេចក្តីឧក្រិដ្ឋកម្មទាំងអស់នេះឡើយ។ លើសពីនេះទៀត អៀង សារី មិនអាចទទួលបានផលប្រយោជន៍ពីការអនុគ្រោះទោសនោះទេ ពីព្រោះមាត្រា ៦ នៃច្បាប់ឆ្នាំ១៩៩៤ មិនបញ្ចូលមេដឹកនាំជាន់ខ្ពស់ឱ្យស្ថិតនៅក្រោមបទបញ្ញត្តិស្តីពីការអនុគ្រោះទោស

---

[៣៧] ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១ (សហព្រះរាជអាជ្ញា) ទំព័រ ៣៤, ៣៩ ដល់ ៤០, ៤២ ដល់ ៤៣, ៤៦។

[៣៨] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបន្ថែមរបស់ អៀង សារី កថាខណ្ឌ ៣០។ ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១ (សហព្រះរាជអាជ្ញា) ទំព័រ ៤៧ ដល់ ៤៩, ៥៥។

[៣៩] ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១ (សហព្រះរាជអាជ្ញា) ទំព័រ ៥០ ដល់ ៥៦។

នៃច្បាប់នោះទេ[៤០]។ ព្រះរាជទានទោស និងអនុគ្រោះទោស ក៏ត្រូវបានទទួលនៅក្នុងបរិយាកាសមានជម្លោះប្រដាប់អាវុធ អំពើហិង្សា និងការគំរាមកំហែង ហើយគួរត្រូវបានចាត់ទុកជាមោឃៈ។ នៅរដ្ឋសភាជាតិ ពុំមានការបោះឆ្នោតគាំទ្រ ឬពិភាក្សាណាមួយនោះទេ ហើយមានការពិគ្រោះយោបល់តែជាមួយសមាជិកសភាតែក្នុងលក្ខណៈឯកជនប៉ុណ្ណោះ[៤១]។ ការលើកលែងទោស និងការអនុគ្រោះទោស ក៏នឹងអនុញ្ញាតឱ្យ អៀង សារី គេចផុតពីការទទួលខុសត្រូវ។ ការធ្វើដូច្នេះ គឺផ្ទុយទៅនឹងសិទ្ធិដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិសម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរក្នុងការទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព ហើយក៏ធ្វើឱ្យផ្នែកសំខាន់ៗនៃកំណត់ ហេតុជាប្រវត្តិសាស្ត្រពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវផ្ទាល់ខ្លួនរបស់ អៀង សារី ក៏ដូចជាសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបាននូវការពិតទាំងស្រុង ត្រូវបាត់បង់[៤២]។

## ៣.២. *<u>គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ</u>* (*Ne bis in idem*)

### *<u>៣.២.១.</u>* *<u>មេធាវីការពារក្តី អៀង សារី</u>*

១៩. មេធាវីការពារក្តី អៀង សារី លើកឡើងថា អ.វ.ត.ក គ្មានយុត្តាធិការទៅលើជនជាប់ចោទនោះទេ ដោយផ្អែកតាមគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ (Ne bis in idem)* និងថា រឿងក្តីនេះ គឺជា*អាជ្ញាអស់ជំនុំ* អនុលោមតាមមាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា[៤៣]។ ប្រសិនបើធ្វើការបកស្រាយសមស្របនោះ មាត្រា ១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌមិនគ្រាន់តែត្រូវអនុវត្តចំពោះជនដែលត្រូវបានសម្រេចឱ្យរួចខ្លួនជាស្ថាពរប៉ុណ្ណោះទេ ថែមទាំងអនុវត្តចំពោះពិរុទ្ធជនផងដែរ ពីព្រោះគោលបំណងនៃគោលការណ៍ *គ្មានការកាត់ទោសពីរដង*

---

[៤០] "ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំពោះសារណាបន្ថែមរបស់លោក អៀង សារី លើអញ្ញត្រកម្មតាមវិធាន ៨៩ (ការអនុគ្រោះទោស និងការលើកលែងទោស") ឯកសារ E51/10/3 ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១១ កថាខណ្ឌ ៩ ដល់ ១៣។

[៤១] ប្រតិចារិក ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១ (សហមេធាវីនាំមុខ) ទំព័រ ៥៩ ដល់ ៦៣។

[៤២] ប្រតិចារិក ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១ (សហមេធាវីនាំមុខ) ទំព័រ ៥៩ ដល់ ៦៣។

[៤៣] មាត្រា ៧ ("ការរលត់នៃបណ្តឹងអាជ្ញា") ចែងថា "មូលហេតុនៃការរលត់បណ្តឹងអាជ្ញាមានដូចតទៅគឺ: ... ៥. *អាជ្ញាអស់ជំនុំ*។ កាលណាបណ្តឹងអាជ្ញាត្រូវផុតរលត់ហើយ ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌមិនអាចចាប់ផ្តើមបានទៀតទេ ឬត្រូវតែបញ្ឈប់"។ *សូមមើលផងដែរ* ប្រតិចារិក ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១ ទំព័រ ៤ ដល់ ៥ (ដោយលើកឡើងថា មាត្រា ៧ អនុវត្តចំពោះជនដែលត្រូវបានសម្រេចឱ្យរួចខ្លួនជាស្ថាពរផង និងពិរុទ្ធជនផង) និង ទំព័រ ៤៦។ "សារណាបន្ថែមរបស់លោក អៀង សារី លើអញ្ញត្រកម្មអនុលោមតាមវិធាន ៨៩ (*គោលការណ៍គ្មានការ កាត់ទោសពីរដងចំពោះបទល្មើសតែមួយ*)" ឯកសារ E51/11 ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១១ ("សារណាបន្ថែមរបស់ អៀង សារី លើអញ្ញត្រកម្មបន្ថែមស្តីពី*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*") កថាខណ្ឌ ៥ ដល់ ៦។

*ចំពោះបទល្មើសតែមួយ* *(Ne bis in idem)* គឺដើម្បីការពារមិនឲ្យបុគ្គលណាម្នាក់ទទួលនូវការកាត់ទោសពីរដង[៤៤]។ ឯកសារសំអាងផ្លូវច្បាប់ជាច្រើនគាំទ្រដល់ការអះអាងថា មាត្រា ១៤(៧) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អនុវត្តជាអន្តរជាតិ និងអាចអនុវត្តបាននៅក្នុងបរិបទនេះ ពីព្រោះសាលក្រមរបស់តុលាការប្រជាជនបដិវត្តន៍ត្រូវបានចាត់ទុកថាជា សាលក្រមស្ថាពរ និងមានសុពលភាពនៅពេលនោះ[៤៥]។ ការកាត់សេចក្តីឡើងវិញនៅក្នុងករណីនៃការកាត់សេចក្តី *ដោយកំបាំងមុខ* មិនមែនជាការកាត់សេចក្តីជាកាតព្វកិច្ចនោះទេ ប៉ុន្តែ "វាអាស្រ័យទៅលើជនជាប់ចោទជាអ្នកសម្រេចថាតើគាត់ចង់ឲ្យមានការកាត់សេចក្តីឡើងវិញដែរ ឬទេ"[៤៦]។ ទោះបីជាយល់ស្របថា តុលាការប្រជាជនបដិវត្តន៍មិនមែនជាតុលាការ "ជំនុំជម្រះក្តីគំរូ" ក៏ដោយ ក៏ចំណុចនេះមិនមានការពាក់ព័ន្ធនោះទេ ពីព្រោះពុំមានករណីលើកលែងចំពោះគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* *(Ne bis in idem)* ផ្អែកតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនោះឡើយ[៤៧]។

២០. ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងធ្វើការពិចារណាទៅលើបទដ្ឋាននីតិវិធី ដែលត្រូវបានបង្កើតឡើងនៅកម្រិតអន្តរជាតិ អង្គជំនុំជម្រះសាលាដំបូងគួរអនុវត្តមាត្រា ២០(៣)(ខ) នៃច្បាប់លក្ខន្តិកៈរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ដែលហាមឃាត់មិនឲ្យមានការជំនុំជម្រះជាថ្មីទៀតឡើយ នៅពេលដែលការជំនុំជម្រះទោសកាលពីមុនមិនមានភាពឯករាជ្យ ឬមិនមានភាពអនាគតិទេនោះ លើកលែងតែការជំនុំជម្រះពីមុននោះមិនមានចេតនាក្នុងការនាំខ្លួនជនសង្ស័យមកទទួលការកាត់សេចក្តី[៤៨]។ ដោយសារតែការជំនុំជម្រះនៅឆ្នាំ ១៩៧៩ មិនមែនជាការជំនុំជម្រះក្លែងក្លាយ ដែលត្រូវបានរៀបចំឡើងដើម្បីឲ្យ អៀង សារី រួចផុតពីការទទួលខុសត្រូវ ហេតុដូច្នេះហើយ គោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* *(Ne bis in idem)* នៅបន្តអនុវត្ត បើទោះបីជា

---

[៤៤] ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ (មេធាវីការពារក្តី អៀង សារី) ទំព័រ ៤៧ ដល់ ៤៨។ សារណាបន្ថែមរបស់ អៀង សារី លើអញ្ញត្រកម្មបន្ថែមស្តីពី *គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* កថាខណ្ឌ ៧ ដល់១០។

[៤៥] សារណាបន្ថែមរបស់ អៀង សារី លើអញ្ញត្រកម្មបន្ថែមស្តីពី *គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* កថាខណ្ឌ ១១ ដល់២៤។

[៤៦] ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ (មេធាវីការពារក្តី អៀង សារី) ទំព័រ ៥៣។

[៤៧] សារណាបន្ថែមរបស់ អៀង សារី លើអញ្ញត្រកម្មបន្ថែមស្តីពី *គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* កថាខណ្ឌ ២៩ ដល់៣០។ ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ (មេធាវីការពារក្តី អៀង សារី) ទំព័រ ៥១។

[៤៨] សារណាបន្ថែមរបស់ អៀង សារី លើអញ្ញត្រកម្មបន្ថែមស្តីពី *គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* កថាខណ្ឌ ២៥ ដល់ ២៨។ ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ (មេធាវីការពារក្តី អៀង សារី) ទំព័រ ៤៩ ដល់ ៥០។

មានភាពខ្វះចន្លោះនៅក្នុងការជំនុំជម្រះនា ឆ្នាំ ១៩៧៩ នោះមែនក៏ដោយ[៤៩]។

### ៣.២.២. *សហព្រះរាជអាជ្ញា*

២១. សហព្រះរាជអាជ្ញាលើកឡើងថា ការកាត់សេចក្តីលើជនជាប់ចោទមិនត្រូវបានហាមឃាត់នៅតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិឡើយ[៥០]។ មាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌគួរត្រូវបានពិនិត្យមើលជាមួយមាត្រា ១២ ដែលកម្រិតការអនុវត្តគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ (Ne bis in idem)* ចំពោះករណីទាំងឡាយដែលជនជាប់ចោទត្រូវបានសម្រេចឲ្យរួចខ្លួនជាស្ថាពរ[៥១]។ មាត្រា ១៤(៧) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក៏មិនអនុវត្តចំពោះកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក នោះដែរ[៥២]។ ទោះបីជាអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាមាត្រា ១៤(៧)អាចអនុវត្តបានក៏ដោយ ក៏លក្ខខណ្ឌកំណត់នៃមាត្រានេះមិនត្រូវបានបំពេញនោះទេ។ ជនជាប់ចោទត្រូវបានជំនុំជម្រះ *ដោយកំបាំងមុខ* ដែលជាការរារាំងសាលក្រមឆ្នាំ ១៩៧៩ មិនឲ្យក្លាយជាសាលក្រម "ស្ថាពរ" តាមច្បាប់ និងនីតិវិធីកម្ពុជា ដែលច្បាប់ និងនីតិវិធីកម្ពុជាទាំងនេះ មិនបានចែងពីគោលការណ៍គ្មានការកាត់ទោសពីរដងនោះទេ[៥៣]។ ជាងនេះទៀត គោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ (Ne bis in idem)* រារាំងការអនុវត្តនៃយុត្តាធិការ តែក្នុងករណីកិច្ចដំណើរការនីតិវិធីជាតិលើកទីមួយ ត្រូវបានធ្វើឡើងប្រកបដោយភាពអនាគតិ ដោយឯករាជ្យភាព និងដោយស្របតាមបទដ្ឋាននៃដំណើរការត្រឹមត្រូវ

---

[៤៩] ប្រតិចារិក ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១ (មេធាវីការពារក្តី អៀង សារី) ទំព័រ ១២ ដល់១៣។ សារណាបន្ថែមរបស់ អៀង សារី លើអញ្ញត្រកម្មបន្ថែមស្តីពី *គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* កថាខណ្ឌ ២៩។

[៥០] "ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងអញ្ញត្រកម្មបឋមរបស់មេធាវីការពារក្តី អនុលោមតាមវិធាន ៨៩" ឯកសារ E51/5/3/1 ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១១ ("ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងអញ្ញត្រកម្ម") កថាខណ្ឌ ៤៥ ដល់ ៤៦។

[៥១] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងអញ្ញត្រកម្ម កថាខណ្ឌ ៤៥។ ប្រតិចារិក ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ (សហព្រះរាជអាជ្ញា) ទំព័រ ៩០, ៩៣-៩៦។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបន្ថែមរបស់ អៀង សារី កថាខណ្ឌ ១១ ដល់ ១៤។

[៥២] ប្រតិចារិក ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ (សហព្រះរាជអាជ្ញា) ទំព័រ ៩៣, ៩៦ ដល់ ៩៧។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបន្ថែមរបស់ អៀង សារី កថាខណ្ឌ ១៦ ដល់ ១៧។

[៥៣] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងអញ្ញត្រកម្ម កថាខណ្ឌ ៤៥។ ប្រតិចារិក ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ (សហព្រះរាជអាជ្ញា) ទំព័រ ៩៤, ១០១-១០៤។

ដែលត្រូវបានទទួលស្គាល់ដោយច្បាប់អន្តរជាតិប៉ុណ្ណោះ[៥៤]។ សវនាការ ឆ្នាំ ១៩៧៩ មិនមែនជា "សវនាការ" ត្រឹមត្រូវតាមច្បាប់តម្រូវនោះទេ ពីព្រោះការជំនុំជម្រះក្តីនោះមិនមានភាពឯករាជ្យ និងគ្មានភាពអនាគតិ[៥៥]។ លើសពីនេះទៀត គោលបំណងនៃគោលការណ៍នេះគឺដើម្បីការពារជនជាប់ចោទមិនឱ្យទទួលរងនូវការជំនុំជម្រះក្តី និងផ្តន្ទាទោសច្រើនដង ហើយ អៀង សារី មិនមានវត្តមាននៅពេលសវនាការនោះ និងនៅទីបំផុតគាត់មិនបានអនុវត្តទោសនោះឡើយ[៥៦]។

### ៣.២.៣. *ដើមបណ្តឹងរដ្ឋប្បវេណី*

២២. ដើមបណ្តឹងរដ្ឋប្បវេណីយល់ស្របថា គោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ (Ne bis in idem)* មិនអនុវត្តនៅក្នុងរឿងក្តីនេះទេ ពីព្រោះការជំនុំជម្រះទោសឆ្នាំ ១៩៧៩ មិនត្រូវបានធ្វើឡើងស្របតាមបទដ្ឋានអន្តរជាតិឡើយ។ អង្គបុរេជំនុំជម្រះបានសម្រេចកាលពីលើកមុនថា មិនត្រូវអនុវត្តគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ (Ne bis in idem)* ចំពោះការជំនុំជម្រះនាឆ្នាំ ១៩៧៩ នោះទេ ដូច្នេះហើយ បញ្ហានេះត្រូវដោះស្រាយនៅចំពោះមុខ អ.វ.ត.ក។ ការសន្និដ្ឋានរបស់ អៀង សារី ក៏បានធ្វើឡើងហួសពីវិសាលភាពនៃការណែនាំមុនរបស់អង្គជំនុំជម្រះ ដែលបានណែនាំគាត់ឱ្យកម្រិតការសន្និដ្ឋានត្រឹមទឡ្ហីករណ៍ថ្មីៗពាក់ព័ន្ធនឹងសាលដីការបស់អង្គបុរេជំនុំជម្រះប៉ុណ្ណោះ[៥៧]។

## ៤. សំអាងហេតុ

### ៤.១. សេចក្តីផ្តើម

២៣. ទោះបីជាអង្គជំនុំជម្រះសាលាដំបូងមិនមែនជាស្ថាប័នពិនិត្យមើលឡើងវិញ ឬជាស្ថាប័នដោះស្រាយ

---

[៥៤] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងអញ្ញត្រកម្ម កថាខណ្ឌ ៤៥។ ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ (សហព្រះរាជអាជ្ញា) ទំព័រ ៩៣-៩៤, ៩៧-១០០។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបន្ថែមរបស់ អៀង សារី កថាខណ្ឌ ១៩។

[៥៥] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបន្ថែមរបស់ អៀង សារី កថាខណ្ឌ ៤, ៧, ៨។ ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ (មេធាវីការពារក្តី អៀង សារី) ទំព័រ ៩៤, ១០១ ដល់ ១០៥។

[៥៦] ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ (សហព្រះរាជអាជ្ញា) ទំព័រ ៩១, ១០៥។

[៥៧] ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ (សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី) ទំព័រ ១០៧ ដល់ ១០៩។ ; *"Réponse des Co-avocats des parties civiles au mémoire supplémentaire sur l'exception préliminaire selon la règle 89 (Ne Bis In Idem)"*, ឯកសារ E51/11/1 ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១១ ("ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសារណាបន្ថែមរបស់ អៀង សារី លើអញ្ញត្រកម្មបន្ថែមស្តីពី*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ")* កថាខណ្ឌ ១៣ ដល់ ២៧។

បណ្តឹងឧទ្ធរណ៍ទាក់ទងនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះក៏ដោយ ពេលនេះ អង្គជំនុំជម្រះសាលាដំបូងត្រូវប្រឈមមុខជាមួយនឹងអញ្ញត្រកម្មនានាដែលទាក់ទងនឹងបញ្ហាស្រដៀងគ្នាទៅនឹងបញ្ហាទាំងឡាយដែលត្រូវបានវិនិច្ឆ័យតាមរយៈសាលដីការបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១។ ដើម្បីឲ្យមានការសន្សំសំចៃធនធានតុលាការ អង្គជំនុំជម្រះសាលាដំបូង នឹងមិនចេញសេចក្តីសម្រេចវែងនោះទេ នៅចំណុចណាដែលអង្គជំនុំជម្រះសាលាដំបូងឯកភាពតាម អង្គបុរេជំនុំជម្រះនោះ។ ដោយសារតែអង្គជំនុំជម្រះសាលាដំបូងយល់ស្របតាមការយល់ឃើញ កាលពីមុនរបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងចំណុចខ្វះចន្លោះនៃការជំនុំជម្រះឆ្នាំ ១៩៧៩ (ដូចខាងលើកថាខណ្ឌ ៧) និងការសម្រេចសេចក្តីចុងក្រោយរបស់អង្គបុរេជំនុំជម្រះលើបញ្ហានេះ ជាទូទៅ នោះអង្គជំនុំជម្រះសាលាដំបូងគ្រាន់តែកម្រិតការយល់ឃើញរបស់ខ្លួន ត្រឹមការវិភាគអំពីផលវិបាកនៃវិការៈទាំងនេះមកលើអានុភាពនៃសេចក្តីសម្រេចរបស់តុលាការប្រជាជនបដិវត្តន៍ និងភាពអាចអនុវត្តបាននៃការអនុគ្រោះទោសពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរ ដែលមេធាវីការពារក្តីបានតវ៉ាតែប៉ុណ្ណោះ។

## <u>៤.២. ក្របខណ្ឌគតិយុត្ត</u>

២៤. មាត្រា ១១ នៃកិច្ចព្រមព្រៀងចែងថា៖ *"រហូតមកដល់ពេលនេះ មានតែករណីមួយគត់ទាក់ទងនឹងបញ្ហាដែលគ្របដណ្តប់ដោយច្បាប់នេះនៅថ្ងៃទី ១៤ កញ្ញា ១៩៩៦ ពេលដែលការលើកលែងទោសត្រូវបានផ្តល់ដល់មនុស្សម្នាក់គត់ដែលត្រូវបានផ្តន្ទាទោសនៅឆ្នាំ១៩៧៩ ពីបទប្រល័យពូជសាសន៍។ អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាឯកភាពគ្នាថាវិសាលភាពនៃការលើកលែងទោសនេះគឺត្រូវសម្រេចដោយអង្គជំនុំជម្រះវិសាមញ្ញ"*[៥៨]។ មាត្រា ៤០ ថ្មី នៃច្បាប់ អ.វ.ត.ក ចែងថា វិសាលភាពនៃការលើកលែងទោស ឬអនុគ្រោះទោសដែលអាចត្រូវបានផ្តល់នៅមុនពេលអនុវត្តច្បាប់នេះ គឺជាបញ្ហាដែលត្រូវសម្រេចដោយអង្គជំនុំជម្រះវិសាមញ្ញ។

២៥. អង្គជំនុំជម្រះសម្គាល់ឃើញថាក្រោមច្បាប់កម្ពុជា ការលើកលែងទោសដែលព្រះមហាក្សត្របានផ្តល់ដោយអនុលោមតាមមាត្រា ២៧ នៃរដ្ឋធម្មនុញ្ញ នៅពេលអានរួមជាមួយមាត្រា ១៤៧ នៃក្រម

---

[៥៨] "កិច្ចព្រមព្រៀងរវាង អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជា ពាក់ព័ន្ធនឹងការកាត់សេចក្តីក្រោមច្បាប់កម្ពុជានូវបទឧក្រិដ្ឋដែលបានប្រព្រឹត្តក្នុងអំឡុងរយៈកាលសម័យកម្ពុជាប្រជាធិបតេយ្យ" ចុះហត្ថលេខាកាលពីថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៣ និងបានចូលជាធរមាននៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ("កិច្ចព្រមព្រៀង") , មាត្រា ១១, *សូមមើលផងដែរ* ឯកសារ អ.ស.ប A/RES/57/228B (ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៣) (ដែលបានឯកភាពលើកិច្ចព្រមព្រៀង អ.វ.ត.ក ព្រាង), ឯកសារ អ.ស.ប A/60/565 (ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៥), កថាខណ្ឌ ៤។

ព្រហ្មទណ្ឌឆ្នាំ ២០០៩ គឺគ្រាន់តែបញ្ចៀសទណ្ឌិតពីការទទួលទោសតែប៉ុណ្ណោះ[៥៩] ចំណែកផលវិបាកផ្សេងៗនៃការផ្តន្ទាទោសនៅមានអត្ថិភាព[៦០]។ ជាទម្លាប់ ការលើកលែងទោសអនុវត្តចំពោះតែទោសណាដែលតុលាការបានសម្រេចស្ថាពរហើយតែប៉ុណ្ណោះ[៦១]។

២៦. ផ្ទុយទៅវិញ ការលើកលែងទោសដែលរដ្ឋសភាជាតិបានផ្តល់ដោយអនុលោមតាមមាត្រា ៩០ នៃរដ្ឋធម្មនុញ្ញគឺបញ្ឈប់ការចោទប្រកាន់ ពោលគឺរាំងមិនឱ្យមានការចោទប្រកាន់ពីបទល្មើសនានា ដែលបានកើតឡើងនៅមុនពេលការលើកលែងទោសនេះចូលជាធរមាន[៦២]។

២៧. គោលការណ៍ *គ្មានការកាត់ទោសពីរដង ចំពោះលើបទល្មើសតែមួយ* ធានាថាបុគ្គលដែលធ្លាប់បាន

---

[៥៩] មាត្រា ២៧ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ចែងថា "ព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស និងលើកលែងទោស" (សំណៅបកប្រែក្រៅផ្លូវការកាលពីខែ មីនា ឆ្នាំ ២០១០ ក្រោមការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាធម្មនុញ្ញ), មាត្រា ១៤៧ នៃក្រមព្រហ្មទណ្ឌ ២០០៩ ចែងថា "ការលើកលែងទោស ដោយអនុលោមតាមមាត្រា ២៧ នៃរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា លើកលែងឱ្យទណ្ឌិតរួចផុតពីការអនុវត្តទោសដែលអនុគ្រោះនោះ"។ *សូមមើលផងដែរ* មាត្រា ១៩៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ("ការអនុគ្រោះទោសត្រូវធ្វើឡើងដោយច្បាប់")។

[៦០] *សូមមើល* មាត្រា ១៤៧ និងមាត្រា ១៤៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩, ដែលការលើកលែងទោសដោយព្រះរាជក្រឹត បានបោះបង់ទោស ប៉ុន្តែពុំបានបោះបង់សិទ្ធរបស់ជនរងគ្រោះក្នុងការទទួលសំណងឡើយ, *សូមមើលផងដែរ* "របាយការណ៍របស់អ្នករាយការណ៍ពិសេសនៃអនុគណៈកម្មាធិការស្តីពីការគាំពារការរើសអើង និងការគាំពារជនជាតិភាគតិច, ការសិក្សាស្តីពីច្បាប់អនុគ្រោះទោស និងតួនាទីរបស់ច្បាប់ទាំងនេះក្នុងការគាំពារ និងលើកស្ទួយសិទ្ធិមនុស្ស", E/CN.4/Sub2/1985/16/Rev.1, កថាខណ្ឌ ៥ ("ការលើកលែងទោស បញ្ឈប់ការដាក់ទោស ប៉ុន្តែពុំបានចាត់ទុកការផ្តន្ទា ទោសជាមោឃៈឡើយ")។

[៦១] ចំណុចនេះបណ្តាលមកពីគោលការណ៍បែងចែកអំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ដែលហាមឃាត់ការលើកលែងទោសនៅពេលដែលសេចក្តីសម្រេចរបស់តុលាការកំពុងស្ថិតក្រោមការត្រួតពិនិត្យរបស់ស្ថាប័នតុលាការ។
*សូមមើល* មាត្រា ១៤៧ និងមាត្រា ១៤៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩, ដែលការលើកលែងទោសដោយព្រះរាជក្រឹត បានបោះបង់ទោស ប៉ុន្តែពុំបានបោះបង់សិទ្ធរបស់ជនរងគ្រោះក្នុងការទទួលសំណងឡើយ, *សូមមើលផងដែរ* "របាយការណ៍របស់ អ្នករាយការណ៍ពិសេសនៃអនុគណៈកម្មាធិការស្តីពីការគាំពារការរើសអើង និងការគាំពារជនជាតិភាគតិច, ការសិក្សាស្តីពីច្បាប់ អនុគ្រោះទោស និងតួនាទីរបស់ច្បាប់ទាំងនេះក្នុងការគាំពារ និងលើកស្ទួយសិទ្ធិមនុស្ស", E/CN.4/Sub2/1985/16/Rev.1, កថាខណ្ឌ ៥ ("ការលើកលែងទោស បញ្ឈប់ការដាក់ទោស ប៉ុន្តែពុំបានចាត់ទុកការផ្តន្ទា ទោសជាមោឃៈឡើយ")។

[៦២] ការផ្តន្ទាទោសដែលការអនុគ្រោះទោសបានលប់ចោល ត្រូវបានលុបចេញពីបញ្ជីថ្កោលទោស (*សូមមើល* មាត្រា ១៩៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ("ទណ្ឌកម្មទាំងឡាយពុំត្រូវបានលើកលែងទោស ត្រូវលុបចេញពីបញ្ជីថ្កោលទោស ព្រោះទណ្ឌកម្មនោះមិនត្រូវយកមកគិតក្នុងការសម្រេចពីស្ថានពុំរាងចាលឡើយ" (សំណៅបកប្រែក្រៅផ្លូវការ), មាត្រា ១៤៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ (ដែលបានកត់សម្គាល់ថាក្រោយពេលមានការអនុគ្រោះទោស ទោសមិនអាចយកមកអនុវត្តទេ) និងមាត្រា ១៩៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ (ដែលចែងថា លើកលែងទោសគឺលើកចោលទាំងអស់ ឬលែងឱ្យរងតទៅទៀតនូវទោសជាទណ្ឌកម្មនៃបទល្មើសដែលមានព្រះរាជក្រមលើកលែងទោសឱ្យ)។

ទទួលការជំនុំជម្រះ និងត្រូវបានតុលាការសម្រេចជាស្ថាពរអំពីទោសនឹងពុំត្រូវបានចោទប្រកាន់ ឬវិនិច្ឆ័យជាថ្មីម្តងទៀតលើអង្គហេតុដដែល ឬត្រូវទទួលទោសបន្ថែម ឬធ្ងន់ធ្ងរជាងមុនឡើយ[៦៣]។ ថ្វីបើគ្មានបញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀង ឬច្បាប់ អ.វ.ត.ក បានចែងផ្ទាល់អំពីគោលការណ៍នេះក្តី ក៏ច្បាប់កម្ពុជាបានឆ្លុះបញ្ចាំងគោលការណ៍នេះនៅក្នុងគោលការណ៍ *អាជ្ញាអស់ជំនុំ* ផងដែរ[៦៤]។ គោលការណ៍នេះយកមកអនុវត្តបានតែនៅក្នុងករណីដែលសំណុំរឿងដំបូងបានឈានទៅដល់សេចក្តីសម្រេចស្ថាពរពាក់ព័ន្ធនឹងភាគី និងអង្គហេតុដូចគ្នាប៉ុណ្ណោះ[៦៥]។ តាមរយៈពាក្យពេចន៍នៃមាត្រា ១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ បញ្ជាក់ច្បាស់ថាគោលការណ៍នេះអាចអនុវត្តបានតែចំពោះអំពើតែមួយ គឺពុំមែនបទល្មើសតែមួយឡើយ[៦៦]។

## ៤.៣. ការបកស្រាយព្រះរាជក្រឹត្យឆ្នាំ ១៩៩៦

២៨. ក្នុងន័យច្បាប់ ការបកស្រាយសមស្របបំផុតអំពីព្រះរាជក្រឹត្យឆ្នាំ ១៩៩៦ (ខាងលើត្រង់កថាខណ្ឌ ១១) ដែលជាធាតុផ្សំនៃការលើកលែងទោស និងការអនុគ្រោះទោស គឺថាព្រះរាជក្រឹត្យនេះផ្តល់ការលើកលែងទោសពាក់ព័ន្ធនឹងទោសប្រហារជីវិត និងការរឹបអូសទ្រព្យសម្បត្តិទាំងអស់ដែលតុលាការប្រជាជនបដិវត្តន៍ឆ្នាំ ១៩៧៩ បានប្រកាស និងការអនុគ្រោះទោសពីការចោទប្រកាន់ ឬការផ្តន្ទា

---

[៦៣] សាលដីកា អ.ប.ជ, កថាខណ្ឌ ១៤២។

[៦៤] មាត្រា ៧ និងមាត្រា ១២ នៃក្រមព្រហ្មទណ្ឌកម្ពុជា (ខាងលើ កថាខណ្ឌ ៦)។ អង្គបុរេជំនុំជម្រះបានយល់ថាបញ្ញត្តិដែលមានអត្ថន័យសាមញ្ញងាយយល់នេះ គឺដាក់កំហិតលើការលើកលែងការចោទប្រកាន់ (សាលដីកា អ.ប.ជ, កថាខណ្ឌ ១២៥)។ ទោះជាយ៉ាងណា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថាមាត្រា ១២ នៃក្រមព្រហ្មទណ្ឌកម្ពុជា គ្រាន់តែបញ្ជាក់ឧទាហរណ៍ស្តីពី *អាជ្ញាអស់ជំនុំ* ប៉ុណ្ណោះ ហើយគោលការណ៍នេះទៀតសោតអាចអនុវត្តចំពោះសេចក្តីសម្រេចទាំងអស់ មិនថាជាសេចក្តីសម្រេចលើកលែងការចោទប្រកាន់ ឬសេចក្តីសម្រេចផ្តន្ទាទោសឡើយ, *សូមមើលផងដែរ* មាត្រា ៤៤៣ នៃក្រមព្រហ្មទណ្ឌកម្ពុជា)។

[៦៥] *សូមមើល* មាត្រា ១២ នៃក្រមព្រហ្មទណ្ឌកម្ពុជា (ដោយលើកឡើងថាគោលការណ៍*អាជ្ញាអស់ជំនុំ* អាចអនុវត្តចំពោះការលើកលែងការចោទប្រកាន់ជាស្ថាពរលើជនណាម្នាក់ដោយសារបទល្មើសតែមួយ), មាត្រា ៤៤៣ នៃក្រមព្រហ្មទណ្ឌកម្ពុជា (ពាក់ព័ន្ធនឹងសំណើសុំពិនិត្យមើលឡើងវិញលើ "សាលក្រមស្ថាពរ" ដែលមានអានុភាព *អាជ្ញាអស់ជំនុំ*), សូមមើលផងដែរ French Cour de Cassation, Crim. ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៩០, Bull. Crim. N141: "l"excpetion d"autorite de la chose jugee ne peut etre valablement invoquee que lorsqu"il existe une identite de principe de l"autoite de chose jugee, fut-ce en meconnaissance de la loi, met obstacle a ce que des poursuites soient reprises devant une juridiction qui a precedemment epuise sa saisine par une decision defnitive"។

[៦៦] *សូមមើលផងដែរ* សាលដីកា អ.ប.ជ, កថាខណ្ឌ ១៣០ (ស្តីពីវិសាលភាពនៃ *គោលការណ៍គ្មានការកាត់ទោសពីរដង*)។

ទោសបទល្មើសតាមច្បាប់ឆ្នាំ ១៩៩៤។ ទោះបីយ៉ាងណា អង្គជំនុំជម្រះសម្គាល់ឃើញមានភាពបន្ទិលផ្នែកច្បាប់មួយចំនួនក្នុងការយកព្រះរាជក្រឹត្យនេះមកបកស្រាយ នោះគឺ៖

- យោងទៅលើការខ្វះចន្លោះជាសារវ័ន្តនៃការជំនុំជម្រះកាលពីឆ្នាំ១៩៧៩ (ខាងលើ កថាខណ្ឌ ៧) តើការសម្រេចរបស់តុលាការប្រជាជនបដិវត្តន៍អាចចាត់ទុកថាជាសេចក្តី សម្រេចដែលមានសុពលភាពគតិយុត្ត ដែរ ឬទេ?

- តើសាលក្រមឆ្នាំ ១៩៧៩ ជាសាលក្រមស្ថាពរ ហើយទោសដែលសាលក្រមនោះបានកំណត់ អាចអនុវត្តបាន និងលើកលែងទោសបានដែរ ឬទេ?

- តើការលើកលែងទោសចំពោះទោសដែលបានផ្តន្ទាកាលពីឆ្នាំ ១៩៧៩ មានតម្លៃស្មើទៅនឹងការអនុគ្រោះទោសចំពោះរាល់បទល្មើសទាំងឡាយដែលតុលាការប្រជាជនបដិវត្តន៍បានវិនិច្ឆ័យរួចកាលពីឆ្នាំ ១៩៧៩ ដែរ ឬទេ?

- តើការអនុគ្រោះទោសក្រោមច្បាប់ឆ្នាំ ១៩៩៤ គ្របដណ្តប់បទចោទណាមួយ ឬទាំងអស់ដែលមាននៅក្នុងដីកាដំណោះស្រាយដែរ ឬទេ?

- តើព្រះមហាក្សត្រមានសិទ្ធិអំណាចតាមរដ្ឋធម្មនុញ្ញក្នុងការប្រទានការអនុគ្រោះទោសតាមរយៈព្រះរាជក្រឹត្យដែរ ឬទេ?

២៩. ពាក់ព័ន្ធនឹងចំណុចចុងក្រោយនេះ អង្គជំនុំជម្រះកត់សម្គាល់ឃើញថាខ្លួនពុំមានតួនាទីសម្រេចអំពីសិទ្ធិអំណាចរបស់ព្រះមហាក្សត្រ និងសភាជាតិ ក៏ដូចជាសុពលភាពស្របតាមរដ្ឋធម្មនុញ្ញនៃព្រះ-រាជក្រឹតឆ្នាំ ១៩៩៦ ឡើយ ដោយហេតុថាការសម្រេចលើបញ្ហានេះជាបុព្វសិទ្ធិរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។ ដោយពិនិត្យទៅលើបរិបទទូទៅនៃការឡាយព្រះហស្តលេខារបស់ព្រះមហាក្សត្រលើព្រះរាជក្រឹត្យឆ្នាំ ១៩៩៦ (ខាងក្រោម, កថាខណ្ឌ ៥៤) អង្គជំនុំជម្រះមិនបដិសេធលទ្ធភាពដែលថាព្រះរាជក្រឹត្យនេះអាចមានបំណងលើកលែងទោស អៀង សារី ពីការអនុវត្តទោស និងការចោទប្រកាន់ពីបទល្មើសទាំងឡាយដែលបានប្រព្រឹត្តមុនឆ្នាំ ១៩៩៦ និងក្នុងអំឡុងរបបកម្ពុជាប្រជាធិប-តេយ្យ ដូចដែលមេធាវីការពារក្តីបានលើកឡើង។ ហេតុដូច្នេះ អង្គជំនុំជម្រះពុំចាំបាច់កោះហៅសាក្សីណាម្នាក់មកបញ្ជាក់បំភ្លឺអំពីគោលបំណងនៃព្រះរាជក្រឹត្យឆ្នាំ ១៩៩៦ ឡើយ។

## <u>៤.៤. អានុភាពនៃការខ្វះចន្លោះរបស់សវនាការឆ្នាំ ១៩៧៩ *(ការលើកលែងទោស និងគោលការណ៍គ្មានការកាត់សេចក្តីពីរដងចំពោះបទល្មើសតែមួយ)*</u>

### <u>*៤.៤.១. សម្អាងហេតុពាក់ព័ន្ធនឹងការលើកលែងទោស និងការអនុវត្តគោលការណ៍ អាជ្ញាអស់ជំនុំ*</u>

*តាមច្បាប់កម្ពុជា*

៣០. អង្គជំនុំជម្រះសាលាដំបូងយល់ស្របតាមសំអាងហេតុរបស់អង្គបុរេជំនុំជម្រះដែលថា សវនាការឆ្នាំ១៩៧៩ បាន ប្រព្រឹត្តទៅដោយមិនឯករាជ្យ និង អនាគតិតាមនីតិវិធី។ អង្គជំនុំជម្រះយល់ឃើញថាកិច្ចដំណើរនីតិវិធីតុលាការឆ្នាំ១៩៧៩ មានការខ្វះចន្លោះដែលធ្វើឱ្យអង្គជំនុំជម្រះមិន អាចចាត់ទុកសេចក្តីសម្រេចរបស់តុលាការនោះថាជាសេចក្តីសម្រេចមួយត្រឹមត្រូវតាមច្បាប់។ ហេតុដូច្នេះ សេចក្តីសម្រេចរបស់តុលាការខាងលើពុំមានអានុភាពគតិយុត្តឡើយ។ ក្រោមច្បាប់ កម្ពុជា សាលក្រមនៃសវនាការ*កំបាំងមុខ* អាចប្តឹងទាស់បាន[៦៧] ដែលធ្វើឱ្យជនជាប់ចោទមាន ឱកាសទទួលបានការជំនុំជម្រះថ្មីដោយមានវត្តមានរបស់ខ្លួន និងការការពារខ្លួន[៦៨]។ ជនជាប់ចោទ ពុំដែលបានបោះបង់ដោយផ្ទាល់ ឬដោយប្រយោលនូវសិទ្ធិជំទាស់ទៅនឹងសាលក្រម*កំបាំងមុខ*របស់តុលាការប្រជាជនបដិវត្តន៍ម្តងណាឡើយ។

៣១. អង្គជំនុំជម្រះសន្និដ្ឋានថាការលើកលែងទោសឆ្នាំ ១៩៩៦ និងគោលការណ៍ *អាជ្ញាអស់ជំនុំ* ពុំហាមឃាត់មិនឱ្យអង្គជំនុំជម្រះអនុវត្តយុត្តាធិការរបស់ខ្លួនក្រោមច្បាប់កម្ពុជាឡើយ។

*៤.៤.២. សំអាងហេតុស្តីពីលទ្ធភាពក្នុងការអនុវត្តគោលការណ៍គ្មានការកាត់សេចក្តីពីរដងលើបទល្មើសតែមួយតាមច្បាប់អន្តរជាតិ*

៣២. ក្នុងការពិចារណាថាតើបទដ្ឋានអន្តរជាតិជាធរមានពិតជាបានហាមឃាត់មិនឱ្យ អ.វ.ត.ក កាត់សេចក្តីជនជាប់ចោទដោយសំអាងទៅលើគោលការណ៍*គ្មានការកាត់សេចក្តីពីរដងលើបទល្មើស*

---

[៦៧] *សូមមើល* មាត្រា ៣៦២, ៣៦៥-៣៧០ នៃក្រមព្រហ្មទណ្ឌកម្ពុជា, *សូមមើលផងដែរ* មាត្រា ៣១៤, ៣២១ ដល់ ៣២៥, មាត្រា ៤៨០ និង ៤៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៦៤។ សិទ្ធិជំទាស់សាលក្រមក្រោយការកាត់សេចក្តី *កំបាំងមុខ* មានចែងនៅក្នុងច្បាប់កម្ពុជានៅពេលបន្ទាប់ តាមរយៈក្រឹត/ច្បាប់ ៥៣ក ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៩ ស្តីពីនីតិវិធីនៃការជំនុំជម្រះបទល្មើស (មាត្រា ៣៩, ៦៨-៧១) និងបន្តរក្សាទុកនៅក្នុងច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌនៃរបបរដ្ឋកម្ពុជាឆ្នាំ ១៩៩៣ (មាត្រា ១១១, មាត្រា ១១៤ ដល់មាត្រា ១២៤)។

[៦៨] ត្រង់នេះឆ្លើយតបទៅនឹងការធានអំពីការជំនុំជម្រះដោយយុត្តិធម៌ជាអប្បបរមា ដោយអនុលោមតាមមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលកម្ពុជាបានផ្តល់សច្ចាប័នកាលពីឆ្នាំ ១៩៩២។ លើសពីនេះ មាត្រា ២៩ នៃច្បាប់អ៊ុនតាក់ឆ្នាំ ១៩៩២ បានផ្តល់ឱ្យទណ្ឌិតនូវលទ្ធភាពស្នើសុំពិនិត្យមើលឡើងវិញនូវសាលក្រម ពិសេសនៅពេលសម្រេចផ្អែក លើហេតុផលនយោបាយ។

*តែមួយ*ដែរ ឬយ៉ាងណានោះ[៦៩] អង្គជំនុំជម្រះសាលាដំបូងយល់ស្របជាមួយសំអាងហេតុរបស់អង្គបុរេជំនុំជម្រះស្តីពីអានុភាពនៃមាត្រា ១៤(៧) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលថាមាត្រាខាងលើយកមកអនុវត្តបានតែចំពោះកិច្ចដំណើរការនីតិវិធីតុលាការជាតិប៉ុណ្ណោះ មិនមែនអនុវត្តចំពោះ អ.វ.ត.ក ដែលជាតុលាការអន្តរជាតុបនីយកម្មឡើយ[៧០]។

៣៣. មូលដ្ឋានសម្រាប់ការដាក់កំហិតលើគោលការណ៍ *គ្មានការកាត់សេចក្តីពីរដងចំពោះបទល្មើសតែមួយ* ពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីចំពោះមុខតុលាការអន្តរជាតុបនីយកម្ម (ដែលភាគច្រើនគឺជាវិការៈ មុនពេលនៃការចោទប្រកាន់អំពីបទល្មើសតែមួយ ឬស្រដៀងគ្នា) កើតចេញពីលក្ខណៈពិសេសនៃអន្តរទំនាក់ទំនងរវាងកិច្ចដំណើរការនីតិវិធីតុលាការជាតិ និងអន្តរជាតិនៅក្នុងស្ថានការណ៍ប្រភេទនេះ[៧១]។ ក្នុងករណីដែលតុលាការអន្តរជាតិមានយុត្តាធិការលើបទល្មើសដែលតុលាការជាតិធ្លាប់បានកាត់សេចក្តីម្តងរួចមកហើយដែលមានវិការៈជាក់ស្តែង *គោលការណ៍គ្មានការកាត់សេចក្តីពីរដងលើបទល្មើសតែមួយ* ត្រូវបានថ្លឹងថ្លែងជាមួយផលប្រយោជន៍របស់សហគមន៍អន្តរជាតិ និងជនរងគ្រោះ ដើម្បីធានាបានថាអ្នកទទួលខុសត្រូវចំពោះបទឧក្រិដ្ឋក្រោមច្បាប់អន្តរជាតិ ពិតជាត្រូវបានជំនុំជម្រះដោយត្រឹមត្រូវ[៧២]។ ដូចដែលអគ្គលេខាធិការអង្គការសហប្រជាជាតិបានកត់សម្គាល់នៅក្នុងរបាយការណ៍របស់ខ្លួនជូនក្រុមប្រឹក្សាសន្តិសុខស្តីពីការអនុម័តិលក្ខន្តិកៈ

---

[៦៩] *សូមមើល* មាត្រា ១២ នៃកិច្ចព្រមព្រៀង, មាត្រា ៣៣ ថ្មីនៃច្បាប់ អ.វ.ត.ក ("អង្គជំនុំជម្រះត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនដោយអនុលោមតាមបទដ្ឋានអន្តរជាតិនៃយុត្តិធម៌ ភាពត្រឹមត្រូវ និងនីតិវិធីតាមច្បាប់ ដូចមានបញ្ជាក់ត្រង់មាត្រា ១៤ និងមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឆ្នាំ ១៩៦៦")។

[៧០] សាលដីការបស់អង្គបុរេជំនុំជម្រះ, កថាខណ្ឌ ១២៨-១៣១ ("ដោយពិចារណាទៅលើសំអាងហេតុរបស់ខ្លួនដូចខាងក្រោមដែលថា អ.វ.ត.ក គឺជាតុលាការអន្តរជាតុបនីយកម្មបំពេញមុខងារដាច់ដោយឡែកពីតុលាការជាតិ ទើបអង្គបុរេជំនុំជម្រះយល់ឃើញថា "គោលការណ៍*គ្មានការកាត់សេចក្តីពីរដងចំពោះបទល្មើសតែមួយ*ដែលជាគោលការណ៍ផ្ទៃក្នុង" ដូចមានចែងក្នុងមាត្រា ១៤(៧) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ពុំអាចអនុវត្តចំពោះកិច្ចដំណើរការនីតិវិធីចំពោះមុខ អ.វ.ត.ក" (លុបចោលឯកសារយោង))។ *សូមមើលផងដែរ* សេចក្តីសម្រេចលើសំណើសុំដោះលែង, សំណុំរឿង ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ, ឯកសារ E39/5, ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៩, កថាខណ្ឌ ១០ (ដែលបានលើកសំអាងហេតុថា "អ.វ.ត.ក ដែលត្រូវបានបង្កើតឡើងដោយកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និង អ.ស.ប គឺជាតុលាការអន្តរជាតុបនីយកម្ម ឯករាជ្យ និងបំពេញមុខងារដាច់ដោយឡែក")។

[៧១] *សូមមើល* សាលដីកា អ.ប.ជ, កថាខណ្ឌ ១៣២-១៦០ (ដែលបានបញ្ជាក់ថាតុលាការអន្តរជាតិពុំអាចអនុវត្តយុត្តាធិការលើបុគ្គលណាម្នាក់ដែលធ្លាប់ត្រូវបានតុលាការជាតិកាត់សេចក្តីម្តងរួចមកហើយនោះឡើយ ដោយសំអាងលើគោលការណ៍ *គ្មានការកាត់សេចក្តីពីរដងលើបទល្មើសតែមួយ* លើកលែងតែក្នុងករណីកិច្ចដំណើរការនីតិវិធីតុលាការជាតិបំពេញតាមលក្ខខណ្ឌកំណត់ជាក់លាក់)។

[៧២] សាលដីកា អ.ប.ជ, កថាខណ្ឌ ១៤៣។

តុលាការ ICTY[៧៣]៖

អនុលោមតាមគោលការណ៍*គ្មានការកាត់សេចក្តីពីរដងចំពោះបទល្មើសតែមួយ* គ្មានជនណាម្នាក់ត្រូវបានតុលាការកាត់សេចក្តីពីរដងចំពោះបទល្មើសតែមួយឡើយ។ ដោយសារអធិកភាពនៃតុលាការអន្តរជាតិនាពេលបច្ចុប្បន្ន គោលការណ៍នេះហាមឃាត់ការកាត់សេចក្តីរបស់តុលាការជាតិនៅពេលបន្ទាប់។ ថ្វីបើដូច្នេះក្តីក៏គោលការណ៍នេះពុំគួរហាមឃាត់មិនឱ្យតុលាការអន្តរជាតិកាត់សេចក្តីលើបទល្មើសតែមួយនៅពេលបន្ទាប់ ក្នុងកាលៈទេសៈពីរខាងក្រោម៖

ក) តុលាការជាតិពុំបានអនុវត្តតាមលំនាំរបស់ខ្លួនដូចមានចែងក្នុងលក្ខន្តិកៈ

ខ) តុលាការជាតិពុំធានាបាននូវ ភាពអនាគតិ ឯករាជ្យភាព ឬមធ្យោបាយនៃការវិនិច្ឆ័យសេចក្តីប្រកបដោយប្រសិទ្ធភាព

៣៤. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា យុត្តិសាស្ត្ររបស់ស្ថាប័នសិទ្ធិមនុស្សអន្តរជាតិ បានលើកឡើងអំពីទំនាក់ទំនងរវាងកាតព្វកិច្ចទាំងនេះជាមួយឧក្រិដ្ឋកម្មអន្តរជាតិ (ខាងក្រោម ចំណុច ៤.៥.៤) និង គោលការណ៍ *គ្មានការកាត់សេចក្តីពីរដងលើបទល្មើសតែមួយ*។ តុលាការសិទ្ធិមនុស្សអន្តរអាមេរិកបានផ្តល់សំអាងហេតុថាគោលការណ៍ *គ្មានការកាត់សេចក្តីពីរដងលើបទល្មើសតែមួយ* ពុំមែនជាគោលការណ៍ដាច់ខាតឡើយ ហើយ "រដ្ឋពុំអាចប្រើប្រាស់ [...គោលការណ៍នេះ] ដើម្បីគេចវេសកាតព្វកិច្ចក្នុងការស៊ើបអង្កេត និងផ្តន្ទាទោសអ្នកទទួលខុសត្រូវ" ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិបានឡើយ[៧៤]។ តុលាការខាងលើក៏បានលើកសំអាងហេតុថា "រដ្ឋពុំអាចអនុវត្តសាលក្រមដែលបានចេញ នៅក្នុងកិច្ចដំណើរការនីតិវិធីណាមួយដែលពុំស្របតាមបទដ្ឋាន [នៃការជំនុំជម្រះដោយយុត្តិធម៌] របស់អនុសញ្ញាអាមេរិក ដើម្បីគេចពីកាតព្វកិច្ចក្នុងការស៊ើបអង្កេត និងផ្តន្ទាទោសបានឡើយ" ដោយហេតុថា "សេចក្តីសម្រេចរបស់តុលាការនៅក្នុងកាលៈទេសៈដែលមិនស្របច្បាប់អន្តរជាតិបែបនេះ ពុំអាចជាជំហានដំបូងដែលនាំទៅដល់ការកាត់សេចក្តីពីរដងលើបទល្មើសតែមួយឡើយ"[៧៥]។ តុលាការអន្តរអាមេរិកបានពិចារណាឃើញថា៖

---

[៧៣] របាយការណ៍របស់អគ្គលេខាធិការ អនុលោមតាមកថាខណ្ឌ ២ នៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ៨០៨ (១៩៩៣), ឯកសារ អ.ស.ប S/25704, ចុះថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០០៣, កថាខណ្ឌ ៦៦(ខ)។

[៧៤] សំណុំរឿង Almonacid Arellano et al ទល់នឹង ស៊ីលី, សាលក្រម (អញ្ញត្រកម្ម, អង្គសេចក្តី, សំណង និងសោហ៊ុយ), តុលាការសិទ្ធិមនុស្សអន្តរអាមេរិក, ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០៦, កថាខណ្ឌ ១៥១,១៥៤, *សូមមើលផងដែរ* សាលដីកា អ.ប.ជ, កថាខណ្ឌ ១៥៤។

[៧៥] សំណុំរឿង Carpio-Nicolle et al. ទល់នឹង ក្វាតេម៉ាឡា, សាលក្រម (អង្គសេចក្តី, សំណង និងសោហ៊ុយ), តុលាការសិទ្ធិមនុស្សអន្តរអាមេរិក, ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៥, កថាខណ្ឌ ៨៤។

គោលការណ៍*គ្មានការកាត់សេចក្តីពីរដងលើបទល្មើសតែមួយ* ពុំអាចយកមកអនុវត្តបានឡើយ នៅពេលកិច្ចដំណើរការនីតិវិធីមួយដែលក្នុងនោះសំណុំរឿងត្រូវបានបដិសេធ ឬអ្នកប្រព្រឹត្តអំពើរំលោភបំពានសិទ្ធិមនុស្សត្រូវបានតុលាការលើកលែងការចោទប្រកាន់ ដោយរំលោភបំពានច្បាប់អន្តរជាតិ មានអានុភាពធ្វើឱ្យជនជាប់ចោទរួចខ្លួនពីការទទួលខុសត្រូវព្រហ្មទណ្ឌ ឬនៅពេលកិច្ចដំណើរការនីតិវិធីពុំបានប្រព្រឹត្តទៅដោយឯករាជ្យ ឬអនាគតិ ដោយអនុលោមតាមនីតិវិធីច្បាប់។ សាលក្រម/សាលដីកា ដែលមាននៅក្នុងកាលៈទេសៈទាំងប៉ុន្មានដូចរៀបរាប់ខាងលើគ្រាន់តែជាហេតុផល "ថ្មៃប្រឌិត" ឬ "បំភ័ន្តបន្លំ" ដើម្បីកុំឱ្យមានការកាត់សេចក្តីជាលើកទីពីរប៉ុណ្ណោះ[៧៦]។

៣៥. ថ្វីបើសំណុំរឿងនៅតុលាការអន្តរអាមេរិកខាងលើភាគច្រើនពាក់ព័ន្ធទៅនឹងការលើកលែងការចោទប្រកាន់ក្តី ក៏យុត្តិសាស្ត្ររបស់តុលាការនេះផ្តល់ជាការណែនាំទូទៅមួយក្នុងករណីដែលពុំមានការផ្តន្ទាទោសលើបទល្មើសធ្ងន់ធ្ងរក្រោមច្បាប់អន្តរជាតិ ទោះដោយសារតុលាការលើកលែងការចោទប្រកាន់ក្តី ឬតុលាការពុំបានអនុវត្តទោសក្តី។ ប្រការនេះបានធ្វើឱ្យការការពារមិនឱ្យមានការកាត់សេចក្តីពីរដងលើបទល្មើសតែមួយ ពុំផ្ទុយទៅនឹងកាតព្វកិច្ចទទួលខុសត្រូវជាអន្តរជាតិ របស់រដ្ឋពាក់ព័ន្ធនឹងចារីនៃបទល្មើសប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមឡើយ។ ហេតុដូច្នេះគោលការណ៍ *គ្មានការកាត់សេចក្តីពីរដងលើបទល្មើសតែមួយ* ពុំអាចរារាំងមិនឱ្យអង្គជំនុំជម្រះអនុវត្តសិទ្ធិយុត្តាធិការលើជនជាប់ចោទ អៀង សារី នៅក្នុងសំណុំរឿងនាពេលបច្ចុប្បន្នបានឡើយ។

៣៦. អង្គជំនុំជម្រះកត់សម្គាល់ឃើញទៀតថា អៀង សារី ដែលបានបដិសេធការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអង្គហេតុទាំងឡាយដែលបានវិនិច្ឆ័យកាលពីឆ្នាំ ១៩៧៩ ព្យាយាមលើកយកអានុភាពនៃការជំនុំជម្រះកាលពីពេលនោះ និងការលើកលែងពីការចោទប្រកាន់អំពីបទល្មើសនានាពាក់ព័ន្ធនឹងអង្គហេតុទាំងនេះក្នុងឆ្នាំ១៩៩៦ មកធ្វើជាសំអាង។ ការយកគោលការណ៍ *គ្មានការកាត់សេចក្តីពីរដងលើបទល្មើសតែមួយ* គឺមានតម្លៃស្មើនឹងការអនុគ្រោះទោស*តាមព្រឹត្តិន័យ*ចំពោះអង្គហេតុទាំងប៉ុន្មានដែលបានវិនិច្ឆ័យកាលពីឆ្នាំ ១៩៧៩។

---

[៧៦] សំណុំរឿង La Cantuta ទល់នឹង ប៉េរូ, សាលក្រម (អង្គសេចក្តី, សំណង និងសោហ៊ុយ), តុលាការសិទ្ធិមនុស្សអន្តរអាមេរិក, ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៦, កថាខណ្ឌ ១៥៣, ១៣០(១), *សូមមើលផងដែរ* Almonacid Arellano et al ទល់នឹង ស៊ីលី, សាលក្រម (អញ្ញត្រកម្ម, អង្គសេចក្តី, សំណង និងសោហ៊ុយ), តុលាការសិទ្ធិមនុស្សអន្តរអាមេរិក, ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០៦, កថាខណ្ឌ ១៥៤ (ដែលបានលើកសំអាងហេតុថាគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ពុំអាច អនុវត្តបានឡើយ នៅពេលកិច្ចដំណើរការនីតិវិធីពុំមានឯករាជ្យ និងមិនលម្អៀង ស្របតាមលក្ខខណ្ឌនីតិវិធីត្រឹមត្រូវ) និងសំណុំ រឿង Carpio-Nicolle et al v. ក្វាតេម៉ាឡា, សាលក្រម (អង្គសេចក្តី, សំណង និងសោហ៊ុយ), តុលាការសិទ្ធិមនុស្សអន្តរអា មេរិក, ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៤, កថាខណ្ឌ ១៣១។

<u>៤.៥.ការអនុគ្រោះទោស</u>

៣៧. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា អៀង សារី ត្រូវបានចោទប្រកាន់អំពីបទល្មើសក្រោមច្បាប់ជាតិផង និងច្បាប់អន្តរជាតិផង។ អង្គជំនុំជម្រះ មិនបានទទួលសំណុំរឿងដែលមានសុពលភាពពាក់ព័ន្ធនឹងការចោទប្រកាន់ទាំងឡាយនៅក្នុងដីកាដំណោះស្រាយអំពីបទល្មើសមនុស្សឃាត, ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញខាងសាសនាក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦[៧៧]។ ដូច្នេះ វិសាលភាពនៃការអនុគ្រោះទោសចំពោះបទល្មើសទាំងនេះ គឺពុំយកមកពិភាក្សាទេ។ ទាក់ទិននឹងការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការរំលោភធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវឆ្នាំ ១៩៤៩[៧៨] អង្គជំនុំជម្រះនឹងវាយតម្លៃថាតើបទឧក្រិដ្ឋណាមួយដែលត្រូវដកចេញពីវិសាលភាពនៃព្រះរាជក្រឹតលើកលែងទោសឆ្នាំ ១៩៩៦ ដោយសំអាងទៅលើសន្ធិសញ្ញា ឬវិធានទំនៀមទម្លាប់នៃច្បាប់អន្តរជាតិដែលតម្រូវឲ្យមានការចោទប្រកាន់ ឬការហាមឃាត់ការលើកលែងទោសចំពោះបទឧក្រិដ្ឋទាំងអស់នេះ។

<u>*៤.៥.១.ការរំលោភធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ, អំពើប្រល័យពូជសាសន៍ និង ការធ្វើទារុណកម្ម*</u>

៣៨. សន្ធិសញ្ញាមួយចំនួនដែលប្រទេសកម្ពុជាជាភាគីហត្ថលេខី ដូចជាអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ ចំនួនបួន អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ និងអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណ-កម្មបានដាក់កាតព្វកិច្ចដាច់ខាត ក្នុងការកាត់សេចក្តីលើឧក្រិដ្ឋកម្មអន្តរជាតិមួយចំនួន[៧៩]។អនុសញ្ញា

[៧៧] សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់មេធាវីការពារក្តី (ចិរវេលាអាជ្ញាយុកាលលើបទល្មើសក្រោមច្បាប់ជាតិ), ឯកសារ E122, ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១។

[៧៨] ដីកាដំណោះស្រាយ, ឯកសារ D427, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០, កថាខណ្ឌ ១៦១៣, ដូចការកែប្រែដោយសាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ជំទាស់នឹងដីកាដំណោះស្រាយ, ឯកសារ D427/1/30, ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១។

[៧៩] អនុសញ្ញាទីក្រុងហ្សឺណែវ I សម្រាប់ការធ្វើឲ្យប្រសើរឡើងនៃលក្ខខណ្ឌនៃការរងរបួស និងការមានជម្ងឺនៅក្នុងកងកម្លាំង ប្រដាប់អាវុធនៅសមរភូមិ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ 75 UNTS 31 ("អនុសញ្ញាទីក្រុងហ្សឺណែវ I")។ អនុសញ្ញាទីក្រុងហ្សឺណែវ II សម្រាប់ការធ្វើឲ្យប្រសើរឡើងនៃលក្ខខណ្ឌនៃសមាជិកដែលរងរបួស ដែលមានជម្ងឺ និងលិចនាវានៃកងកម្លាំង ប្រដាប់អាវុធនៅសមុទ្រ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ 75 UNTS 85 ("អនុសញ្ញាទីក្រុងហ្សឺណែវ II")។ អនុសញ្ញាទីក្រុងហ្សឺណែវ III ពាក់ព័ន្ធនឹងការប្រព្រឹត្តរបស់ឈ្លើយសឹក ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ 75 UNTS 135 ("អនុសញ្ញាទីក្រុងហ្សឺណែវ III")។ អនុសញ្ញាទីក្រុង ហ្សឺណែវ IV ពាក់ព័ន្ធនឹងការការពារប្រជាជនស៊ីវិលនៅក្នុងពេលមាន សង្គ្រាម ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ 75 UNTS 287 ("អនុសញ្ញាទីក្រុងហ្សឺណែវ IV") ("អនុសញ្ញាទីក្រុងហ្សឺណែវ"រួម ដែលត្រូវបាន

ទីក្រុងហ្សឺណែវតម្រូវឱ្យប្រទេសហត្ថលេខីដាក់ការបំពានធ្ងន់ធ្ងរលើអនុសញ្ញាទាំងអស់ជាបទឧក្រិដ្ឋ ស្រាវជ្រាវរកចារីទាំងឡាយដែលត្រូវបានចោទប្រកាន់ព្រមទាំងកាត់ទោសពួកគេ ឬធ្វើបត្យាប័នពួកគេ ដើម្បីធ្វើការជំនុំជម្រះទោសនៅក្នុងរដ្ឋជាភាគីហត្ថលេខីមួយទៀត[៨០]។ តាមអនុសញ្ញាទីក្រុងហ្សឺណែវ រដ្ឋជាភាគីហត្ថលេខីត្រូវធ្វើការរារាំងអំពើប្រល័យពូជសាសន៍ និងធ្វើការជំនុំជម្រះ និងដាក់ទោសចារី[៨១]។ អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មតម្រូវឱ្យរដ្ឋជាភាគីហត្ថលេខីដាក់រាល់អំពើទារុណកម្មជាបទឧក្រិដ្ឋនិងដាក់ជូនអាជ្ញាធរមានសមត្ថកិច្ចនូវករណីនៃការធ្វើទារុណកម្មដើម្បី

---

ផ្តល់សច្ចាប័នដោយប្រទេសកម្ពុជានៅឆ្នាំ ១៩៥៨)។ អនុសញ្ញាស្តីពីការការពារ និងការផ្តន្ទាទោសលើឧក្រិដ្ឋកម្ម ប្រល័យពូជសាសន៍ ចុះថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ១៩៤៨ 78 U.N.T.S 277 (“អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍” ដែលត្រូវបាន ផ្តល់សច្ចាប័នដោយ ប្រទេសកម្ពុជានៅឆ្នាំ ១៩៥០)។ អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្តសាហាវព្រៃផ្សៃ អមនុស្សធម៌ និងថោកទាបផ្សេងៗទៀត ឬការផ្តន្ទាទោស ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៨៤ 1465 U.N.T.S. 85 (“អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ដែលត្រូវបានផ្តល់សច្ចាប័នដោយប្រទេសកម្ពុជានៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២)។

[៨០] អនុសញ្ញាទីក្រុងហ្សឺណែវ I មាត្រា ៤៩។ អនុសញ្ញាទីក្រុងហ្សឺណែវ II មាត្រា ៥០។ អនុសញ្ញាទីក្រុងហ្សឺណែវ III មាត្រា ១២៩។ អនុសញ្ញាទីក្រុងហ្សឺណែវ IV មាត្រា ១៤៦ (ដោយបានចែងថា “ភាគីផ្តល់សច្ចាប័ននានាទទួលខុសត្រូវធ្វើការអនុម័តបទបញ្ញត្តិដែលចាំបាច់ដើម្បីចែងពីការផ្តន្ទាទោសព្រហ្មទណ្ឌដ៏មានប្រសិទ្ធភាពសម្រាប់ជនទាំងឡាយណាដែលបានប្រព្រឹត្ត ឬបានបញ្ជាឱ្យមានការប្រព្រឹត្តការបំពានធ្ងន់ធ្ងរលើអនុសញ្ញានេះដែលត្រូវបានកំណត់នៅក្នុងមាត្រាខាងក្រោម។ ភាគីផ្តល់សច្ចាប័ន ត្រូវមានកាតព្វកិច្ចស្រាវជ្រាវរកជនទាំងឡាយណាដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្ត ឬបានបញ្ជាឱ្យមានការប្រព្រឹត្តការបំពានធ្ងន់ធ្ងរបែបនេះ និងត្រូវនាំយកជននេះមកជំនុំជម្រះទោសនៅចំពោះមុខតុលាការរបស់ប្រទេសរបស់ភាគីនោះ ដោយមិនគិតពីសញ្ជាតិរបស់ជននោះឡើយ។ ប្រសិនបើធ្វើការចោទប្រកាន់ និងយោងតាមបទបញ្ញត្តិនានារបស់ខ្លួន ភាគីនោះក៏អាចបញ្ជូនជន នេះទៅជំនុំជម្រះទោសនៅភាគីផ្តល់សច្ចាប័នដែលពាក់ព័ន្ធមួយទៀតបានដែរ ដោយចែងថា ភាគីផ្តល់សច្ចាប័ននេះបានយល់ឃើញអំពីករណីតាមការវិភាគបឋម...”)។ *សូមមើលផងដែរ* វិចារណកថា ICRC ទៅនឹងអនុសញ្ញាទីក្រុងហ្សឺណែវ I មាត្រា ៥១ (ដោយបញ្ជាក់ថា កាតព្វកិច្ចក្នុងការកាត់សេចក្តីការបំពានធ្ងន់ធ្ងរមានលក្ខណៈដាច់ខាត)។

[៨១] អនុសញ្ញាទីក្រុងហ្សឺណែវ មាត្រា ១, ៤ និង ៦ (ចែងថា “ភាគីហត្ថលេខីបញ្ជាក់ថា អំពើប្រល័យពូជសាសន៍ មិនថាត្រូវបានប្រព្រឹត្តនៅក្នុងពេលមានសន្តិភាព ឬនៅក្នុងពេលមានសង្គ្រាមនោះទេ គឺជាបទឧក្រិដ្ឋមួយនៅក្នុងច្បាប់អន្តរជាតិដែលភាគីហត្ថលេខីទទួលខុសត្រូវធ្វើការការពារ និងផ្តន្ទាទោស” និងថា “ជនទាំងឡាយណាដែលប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ឬអំពើទាំងឡាយផ្សេងទៀតដែលមានចែងនៅក្នុងមាត្រា ៣ ត្រូវទទួលការផ្តន្ទាទោស មិនថាពួកគេជាមេដឹកនាំដែលទទួលខុសត្រូវតាមច្បាប់រដ្ឋធម្មនុញ្ញ ជាមន្ត្រីសាធារណៈ ឬជាបុគ្គលឯកជននោះឡើយ”)។ *សូមមើលផងដែរ* *Barcelona Traction, Light and Power* (ប្រទេសប៊ែលហ្ស៊ិក តទល់នឹង ប្រទេសអេស្ប៉ាញ) (ឆ្នាំ ១៩៧០) តុលាការយុត្តិធម៌អន្តរជាតិ ចុះថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ១៩៧០ កថាខណ្ឌ ៣៤ (ដោយសម្រេចថា គ្រប់រដ្ឋទាំងអស់ត្រូវអនុវត្តការហាមឃាត់ប្រឆាំងនឹងអំពើប្រល័យពូជសាសន៍ដែលជាកាតព្វកិច្ចរបស់គ្រប់ភាគីហត្ថលេខីទាំងអស់ (*erga omnes*))។

ធ្វើការស៊ើបអង្កេតកាត់ទោស ឬធ្វើបត្យាប័នចារីដែលត្រូវបានចោទប្រកាន់[៨២]។ តុលាការអន្តរជាតិ និងស្ថាប័នសន្ធិសញ្ញា បានធ្វើការពិចារណាជាច្រើនដងអំពីការអនុគ្រោះទោសចំពោះចារីនៃអំពើការធ្វើទារុណកម្ម ដែលមានវិសមិតភាពទៅនឹងកាតព្វកិច្ចក្នុងការស៊ើបអង្កេត និងក្នុងការចោទប្រកាន់អំពើទាំងអស់នេះ[៨៣]។

---

[៨២] អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម មាត្រា៤, ៥, ៧ និង ១២។ *សូមមើលផងដែរ* "គោលការណ៍ណែនាំ និងវិធានការសម្រាប់ការហាមឃាត់ និងការពារការធ្វើទារុណកម្ម ការប្រព្រឹត្តសាហាវព្រៃផ្សៃ អមនុស្សធម៌ និងថោកទាប ឬការផ្តន្ទាទោសនៅប្រទេសអាហ្វ្រិក (គោលការណ៍ណែនាំស្តីពីកោះរ៉ូបេន) របស់គណៈកម្មការទទួលបន្ទុកសិទ្ធិមនុស្ស និងសិទ្ធិប្រជាជន" ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០២ គោលការណ៍ណែនាំ ១៦ (ដែលបានជម្រុញរដ្ឋនានាឱ្យ "ក. ធានាថាការទទួលខុសត្រូវចំពោះ អំពើនានានៃការធ្វើទារុណកម្ម ឬការប្រព្រឹត្តអាក្រក់ទាំងអស់នោះ គឺត្រូវធ្វើតាមនីតិវិធីច្បាប់។ ខ) ធានាថាពុំមាននិទណ្ឌភាពពីការកាត់សេចក្តីសម្រាប់ប្រជាជាតិណាមួយដែលជាប់សង្ស័យធ្វើទារុណកម្មនោះទេ...")។

[៨៣] *សូមមើលឧទាហរណ៍ O.R., M.M.* និង *M.S.* តទល់នឹង ប្រទេសអាហ្សង់ទីន Comm. 1/1988, 2/1988 និង 3/1988 សេចក្តីសម្រេចលើភាពអាចទទួលយកបាន គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ១៩៨៩ កថាខណ្ឌ ៩ (ដោយលើកឡើងថា "សូម្បីតែនៅមុនពេលអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មចូលជាធរមានក៏ដោយ មានវិធានទូទៅនៃច្បាប់អន្តរជាតិដែលត្រូវចងកាតព្វកិច្ចគ្រប់រដ្ឋទាំងអស់ឱ្យចាត់វិធានការប្រកបដោយប្រសិទ្ធភាពក្នុងការការពារការធ្វើ ទារុណកម្ម និងធ្វើការផ្តន្ទាទោសអំពើនានានៃការធ្វើទារុណកម្ម" និងបានពិចារណាឃើញថា ច្បាប់ the Punto Final and Due Obedience Acts ដែលមានចែងពីការលើកលែងទោសចំពោះការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ នៅក្នុងអំឡុងលទ្ធិផ្តាច់ការយោធាឆ្នាំ ១៩៧៦ ដល់ ១៩៨៣ "មានវិសមិតភាពជាមួយនឹងស្មារតី និងគោលបំណងនៃអនុសញ្ញា")។ យោបល់ទូទៅ លេខ ២ របស់គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្មៈ ការអនុវត្តមាត្រា ២ ធ្វើឡើងដោយរដ្ឋជាភាគីនានា ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០៨ កថាខណ្ឌ ៥។ យោបល់ទូទៅ លេខ ២០ (៤៤) របស់គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ស្តីពីមាត្រា ៧ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ការហាមឃាត់ការធ្វើទារុណកម្ម ឬការប្រព្រឹត្តអំពើសាហាវ ព្រៃផ្សៃ អមនុស្សធម៌ និងថោកទាប ឬការផ្តន្ទាទោស) ចុះថ្ងៃទី ៣ ខែ មេសា ឆ្នាំ ១៩៩២ ("យោបល់ទូទៅ លេខ ២០") កថាខណ្ឌ ១៥ ("ការលើកលែងទោសជាទូទៅមានវិសមិតភាពជាមួយនឹងកាតព្វកិច្ចរបស់រដ្ឋនានាក្នុងការស៊ើបអង្កេត [អំពើនានា នៃការធ្វើទារុណកម្ម]")។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Furundzija* សំណុំរឿង IT-95-17/1-T សាលក្រមអង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTY ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៩៨ កថាខណ្ឌ ១៥១-១៥៧ ("វានឹងគ្មានន័យអ្វីទេក្នុងការលើកឡើង...ថា ចំពោះអង្គហេតុនៃតម្លៃ អាជ្ញាបញ្ញារ នៃការហាមឃាត់ប្រឆាំងនឹងការធ្វើទារុណកម្ម សន្ធិសញ្ញានានា ឬបទដ្ឋានទំនៀមទម្លាប់ ដែលចែងសម្រាប់ការធ្វើទារុណកម្មនឹងត្រូវចាត់ទុកជាមោឃៈ *ចាប់តាំងពីដំបូង* (*ab initio*) រួចហើយជាការធ្វេសប្រហែស របស់រដ្ឋ... ដោយចាត់វិធានការថ្នាក់ជាតិនានាដែលអនុញ្ញាត ឬលើកលែងទោសឱ្យអំពើធ្វើទារុណកម្ម ឬលើកលែងទោសឱ្យចារី ប្រព្រឹត្តអំពើធ្វើទារុណកម្មនានាតាមរយៈច្បាប់អនុគ្រោះទោស")។ រឿងក្តី *Ely Ould Dah តទល់នឹង ប្រទេសបារាំង* សេចក្តីសម្រេចអំពីភាពអាចទទួលយកបាន ECtHR (no. 13113/03) ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩ ទំព័រ ១៧ (ដោយបានពិចារណាឃើញថា ការលើកលែងទោសជាទូទៅមានវិសមិតភាពជាមួយនឹងកាតព្វកិច្ចរបស់រដ្ឋនានា ក្នុងការស៊ើបអង្កេតលើអំពើនានានៃការធ្វើទារុណកម្ម)។

៣៩. ដោយសារតែប្រទេសកម្ពុជាជាប់កាតព្វកិច្ចដាច់ខាតក្នុងការធានាអំពីការចោទប្រកាន់ ឬការផ្តន្ទាទោសចារីនៃអំពើរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ អំពើប្រល័យពូជសាសន៍ និងការធ្វើទារុណកម្ម ព្រះរាជក្រឹត្យឆ្នាំ ១៩៩៦ មិនអាចដកប្រទេសកម្ពុជាពីកាតព្វកិច្ចក្នុងការកាត់ទោសបទឧក្រិដ្ឋទាំងអស់នេះ ឬបង្កើតជាឧបសគ្គចំពោះកាតព្វកិច្ចនេះបានទេ[៨៤]។ ដោយសារតែកាតព្វកិច្ចនៃសន្ធិសញ្ញារបស់ប្រទេសកម្ពុជាពាក់ព័ន្ធនឹងបទឧក្រិដ្ឋទាំងអស់នេះ អង្គជំនុំជម្រះមិនត្រូវធ្វើការបកស្រាយព្រះរាជក្រឹត្យឆ្នាំ ១៩៩៦ ថាជា ការផ្តល់អភ័យឯកសិទ្ធិរួចពីការកាត់ទោសជនជាប់ចោទ អៀង សារី ទាក់ទិននឹងការបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ អំពើប្រល័យពូជសាសន៍ ឬការធ្វើទារុណកម្មនោះបានទេ។

### *៤.៥.២.បទល្មើសប្រឆាំងនឹងមនុស្សជាតិ*

៤០. ដោយហេតុថាពុំមានសន្ធិសញ្ញាអន្តរជាតិណាមួយ ចែងច្បាស់អំពីការហាមឃាត់ការអនុគ្រោះទោសពាក់ព័ន្ធនឹងបទល្មើសក្រោមច្បាប់អន្តរជាតិ ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ ទើបអង្គជំនុំជម្រះសាលាដំបូងបានសិក្សាអំពីទម្លាប់អនុវត្តរបស់រដ្ឋពាក់ព័ន្ធ និងសច្ចធាណ៍ធម្មានុរូប *(opinio juris)* ដើម្បីបញ្ជាក់ថាតើខ្លួនមានភារកិច្ចចោទប្រកាន់ ឬហាមឃាត់អនុវត្តន៍ជាប្រតិសកម្មនូវការអនុគ្រោះទោសចំពោះបទល្មើសទាំងអស់នេះ ដោយសារតែអំណាចនៃនិយាមទំនៀមទម្លាប់ណាមួយដែរឬទេ[៨៥]។

---

[៨៤] បទបញ្ញត្តិនៃច្បាប់ជាតិមិនអាចប្រើប្រាស់ធ្វើជាយុត្តិកម្មសម្រាប់ការខកខានក្នុងការបំពេញកាតព្វកិច្ចតាមសន្ធិសញ្ញាឡើយ (សូមមើលមាត្រា ២៧ នៃអនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៦៩ 1155 U.N.T.S. 331 ដែលត្រូវបានចុះហត្ថលេខាដោយប្រទេសកម្ពុជានៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៦៩)។ *សូមមើលផងដែរ* មាត្រា ៣១ នៃ រដ្ឋធម្មនុញ្ញប្រទេសកម្ពុជា: "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហ ប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ..."។

[៨៥] មាតិកានៃច្បាប់ទំនៀមទម្លាប់អន្តរជាតិមានប្រភពមកពីទម្លាប់អនុវត្តន៍ជាក់ស្តែងរបស់រដ្ឋ និង *ទស្សនៈច្បាប់* , *សូមមើល សំណុំរឿង North Sea Continental Shelf* (ឆ្នាំ ១៩៦៩), សាលក្រម, តុលាការ ICJ, ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៦៩, កថាខណ្ឌ ៤៣-៤៤, កថាខណ្ឌ ៧៤ ("ទម្លាប់អនុវត្តន៍របស់រដ្ឋ, រួមទាំងទម្លាប់អនុវត្តន៍របស់រដ្ឋដែលប្រយោជន៍របស់ផងខ្លួនរងការប៉ះពាល់ គួរមានលក្ខណៈទូលំទូលាយ និងមានភាពរលូននៅក្នុងស្មារតីនៃបញ្ញត្តិដែលបានចែង ហើយទម្លាប់អនុវត្តន៍គួរមានអត្ថិភាពក្នុងកម្រិត មួយ ដែលអាចបញ្ជាក់ឲ្យឃើញនូវការទទួលស្គាល់ជាទូទៅថាមានការពាក់ព័ន្ធនឹងវិធាននៃច្បាប់ ឬកាតព្វកិច្ចគតិយុត្តិ។ [...] ទង្វើពាក់ព័ន្ធពុំត្រឹមតែត្រូវមានតម្លៃស្មើនឹងទម្លាប់អនុវត្តន៍ មិនប្រែប្រួលតែមួយមុខនោះទេ ប៉ុន្តែទង្វើទាំងនោះត្រូវតែមានលក្ខណៈជាភស្តុតាង ដែលបញ្ជាក់ថាទម្លាប់អនុវត្តន៍នេះជាកាតព្វកិច្ចតាមរយៈអត្ថិភាពនៃវិធាននៃច្បាប់ដែលតម្រូវដូច្នោះ [*ទស្សនៈច្បាប់*]"។ ប្រភពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិពាក់ព័ន្ធរួមមាន អនុសញ្ញា និងសន្ធិសញ្ញា, សេចក្តីថ្លែង

៤១. អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា កាលពីពេលដើមដំបូង និយមន័យនៃឧក្រិដ្ឋកម្មប្រ-ឆាំងនឹងមនុស្សជាតិ បានដាក់ការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ "ទោះបីឧក្រិដ្ឋកម្មនេះមិនរំលោភ ឬរំលោភបំពានច្បាប់ជាតិនៃប្រទេសដែលកើតមានឧក្រិដ្ឋកម្មនេះក៏ដោយ"[៨៦]។ ចាប់តាំងពីពេលបង្កើតដំបូងក្នុងឆ្នាំ ១៩៩៨ រដ្ឋចំនួន ១១៦ រួមទាំងកម្ពុជាផង បានបញ្ជាក់អះអាងជាថ្មីអំពីភាពចាំបាច់ ដែលត្រូវជំនុំជម្រះបទល្មើសធ្ងន់ធ្ងរក្រោមច្បាប់អន្តរជាតិ តាមរយៈការផ្តល់សច្ចាប័នលើច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម។ បុព្វកថានៃលក្ខន្តិកៈនេះចែងថា "នេះជាភារកិច្ចរបស់រដ្ឋនីមួយៗក្នុងការអនុវត្តយុត្តាធិការព្រហ្មទណ្ឌរបស់ខ្លួនលើអ្នកទាំងឡាយដែលទទួលខុសត្រូវចំពោះបទល្មើសព្រហ្មទណ្ឌអន្តរជាតិទាំងនោះ"[៨៧]។

៤២. ស្ថាប័នសិទ្ធិមនុស្សអង្គការសហប្រជាជាតិ និងតុលាការសិទ្ធិមនុស្សថ្នាក់តំបន់ ក៏បានលើកឡើងជាច្រើនដងថា ការអនុគ្រោះទោសរបស់តុលាការជាតិ ដែលរារាំងការចោទប្រកាន់បទល្មើសធ្ងន់ធ្ងរក្រោមច្បាប់អន្តរជាតិ ពុំស្របទៅនឹងកាតព្វកិច្ចអន្តរជាតិរបស់រដ្ឋក្នុងការផ្តល់ឲ្យជនរងគ្រោះនៃអំពើរំលោភបំពានទាំងអស់នូវដំណោះស្រាយប្រកបដោយប្រសិទ្ធភាព។ គណៈកម្មាធិការសិទ្ធិមនុស្សដែលមានតួនាទីបកស្រាយ និងត្រួតពិនិត្យការអនុវត្តកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ យល់ឃើញថា កាតព្វកិច្ចនេះរាប់បញ្ចូលទាំងភារកិច្ចស៊ើបអង្កេតការចោទប្រកាន់អំពី

---

ការណ៍របស់គណៈប្រតិភូក្នុងអំឡុងពេលនៃកិច្ចចរចាសន្ធិសញ្ញានិងច្បាប់យុត្តិសាស្ត្រនៃតុលាការអន្តរជាតិ, *សូមមើលឧទាហរណ៍ សំណុំរឿងពាក់ព័ន្ធនឹងសកម្មភាពយោធា និង Paramilitary នៅ Nicaragua និងប្រឆាំងនឹង Nicaragua*, សាលក្រម, តុលាការ ICJ, ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៨៦, កថាខណ្ឌ ៩៨-១០១, កថាខណ្ឌ ១៨៥-១៩១, *សូមមើលផង ដែរ* មាត្រា ៣៨(១)(ខ) នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ (ដែលយោងទៅលើ "ទំនៀមទម្លាប់អន្តរជាតិ ដែលជាភស្តុតាង បញ្ជាក់អំពីទម្លាប់អនុវត្តន៍ជាទូទៅមួយដែលត្រូវបានទទួលស្គាល់ថាជាច្បាប់")។

[៨៦] *សូមមើលឧទាហរណ៍* មាត្រា ៦(គ) នៃធម្មនុញ្ញតុលាការយោធាអន្តរជាតិសម្រាប់ការកាត់សេចក្តីឧក្រិដ្ឋជនសង្គ្រាមធំៗ ដែលជាឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងទីក្រុងឡុងដ៍ ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៩៤៥ (កិច្ចព្រមព្រៀងសម្រាប់ការចោទប្រកាន់ និងការផ្តន្ទាទោសឧក្រិដ្ឋជនសង្គ្រាមធំៗនៃសម្ព័ន្ធមិត្តអឺរ៉ុប និងធម្មនុញ្ញនៃតុលាការយោធាអន្តរជាតិ, ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៩៤៥ (82 UNTS 279)), *សូមមើលផងដែរ* ការយោងស្រដៀងគ្នាទៅនឹងច្បាប់ជាតិនៅត្រង់មាត្រា ៥ (គ) នៃធម្មនុញ្ញតុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៤៦ ដែលជាឧបសម្ព័ន្ធនៃការប្រកាសឲ្យប្រើពិសេសចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៤៦ របស់មេបញ្ជាការកំពូលនៃមហាអំណាចសម្ព័ន្ធមិត្តនៅចុងបូព៌ា និងមាត្រា II នៃច្បាប់លេខ ១០ នៃក្រុមប្រឹក្សាត្រួតពិនិត្យសម្រាប់អាល្លឺម៉ង់ (ឆ្នាំ ១៩៤៥), ដែលបានបោះពុម្ពឡើងវិញនៅក្នុងឯកសារ *ការកាត់សេចក្តីឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា Nuremberg ដោយអនុ លោមតាមច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០*, វ៉ុល ១, កថាខណ្ឌ XVI-XIX។

[៨៧] លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ, ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៨ (បានចូលជាធរមាននៅថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០០២), (2187 UNTS 90, កម្ពុជាបាន ផ្តល់សច្ចាប័ននៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០២)។

ការរំលោភទាំងអស់នេះ និងនាំខ្លួនចារីមកកាត់សេចក្តី ជាពិសេសក្នុងសំណុំរឿងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[៨៨] គណៈកម្មាធិការនេះក៏បានគូសបញ្ជាក់ទៀតថា រដ្ឋភាគីពុំអាចអនុញ្ញាតឲ្យចារីរួចខ្លួនពីការទទួលខុសត្រូវលើបទល្មើសទាំងអស់នេះ តាមរយៈការអនុគ្រោះទោសបានឡើយ ដែលជាទូទៅការអនុគ្រោះទោសនេះពុំស្របទៅនឹងកាតព្វកិច្ចរបស់រដ្ឋក្នុងការស៊ើបអង្កេតលើបទល្មើសទាំងអស់នេះឡើយ[៨៩]។

---

[៨៨] យោបល់ទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ លេខ ៣១(៨០) (ប្រភេទនៃកាតព្វកិច្ចគតិយុត្តិដែលរដ្ឋភាគីត្រូវអនុវត្ត), ឯកសារអង្គការសហប្រជាជាតិ, CCPR/C/21/Rev.1/Add.13, ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៤ ("យោបល់ទូទៅលេខ ៣១"), កថាខណ្ឌ១៥ និង១៨, *សូមមើលផងដែរ Bautista de Arellana ទល់នឹង កូឡុំប៊ី,* យោបល់លេខ ៥៦៣/១៩៩៣, ទស្សនៈ, គណៈកម្មាធិការសិទ្ធិមនុស្ស, ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩៥, កថាខណ្ឌ ៨.២ និង ៨.៦។ ("កតិកាសញ្ញានេះពុំផ្តល់សិទ្ធិដល់បុគ្គលក្នុងការទាមទារឲ្យរដ្ឋចោទប្រកាន់ផ្នែកព្រហ្មទណ្ឌទៅលើជនណាម្នាក់ទៀតឡើយ [...]។ ទោះជាយ៉ាងនេះក្តី គណៈកម្មាធិការនេះយល់ថារដ្ឋភាគីមានភារកិច្ចស៊ើបអង្កេត ឲ្យបានម៉ត់ចត់ទៅលើអំពើរំលោភសិទ្ធិមនុស្សដែលត្រូវបានចោទប្រកាន់ ... និងចោទប្រកាន់ផ្នែកព្រហ្មទណ្ឌ កាត់សេចក្តី និងផ្តន្ទាទោសជនទាំងឡាយណាដែលទទួលខុសត្រូវចំពោះទង្វើល្មើសទាំងអស់នោះ")។

[៨៩] យោបល់ទូទៅលេខ ៣១ ("ហេតុដូច្នេះ ប្រសិនបើមន្ត្រីសាធារណៈ ឬភ្នាក់ងាររដ្ឋ បានប្រព្រឹត្តអំពើល្មើសនឹងសិទ្ធិតាមអនុសញ្ញានេះដូចដែលបានលើកឡើងនៅក្នុងកថាខណ្ឌនេះ រដ្ឋភាគីពាក់ព័ន្ធពុំអាចអនុញ្ញាតឲ្យចារីរួចខ្លួនពីការទទួលខុសត្រូវផ្ទាល់ខ្លួនឡើយ ដូចធ្លាប់បានធ្វើកន្លងមកពាក់ព័ន្ធនឹងការលើកលែងទោសមួយចំនួន... និងអភ័យឯកសិទ្ធិ និងបុព្វសិទ្ធិពីពេលមុន"); យោបល់ទូទៅលេខ ២០, កថាខណ្ឌ ១៥ ("ជាទូទៅ ការលើកលែងទោសពុំស្របទៅនឹងភារកិច្ចរបស់រដ្ឋក្នុងការស៊ើបអង្កេត [អំពើ ទារុណកម្ម] ឡើយ"), *សំណុំរឿង Basilio Laureano Attachahua ទល់នឹង Peru,* យោបល់លេខ ៥៤០/១៩៩៣, ទស្សនៈ, គណៈកម្មាធិការសិទ្ធិមនុស្ស, ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៩៦, កថាខណ្ឌ ១០ ("អនុលោមតាម [មាត្រា ២(៣)] នៃកតិកាសញ្ញានេះ រដ្ឋភាគីមានកាតព្វកិច្ចផ្តល់ឲ្យជនរងគ្រោះនូវសំណងជួសជុលព្យសនកម្មប្រកបដោយប្រសិទ្ធភាព។ គណៈកម្មាធិការបានជំរុញឲ្យរដ្ឋភាគីបើកកិច្ចស៊ើបសួរឲ្យបានត្រឹមត្រូវ..., ដើម្បីផ្តល់សំណងសមស្របដល់ជនរងគ្រោះ និងក្រុមគ្រួសារ និងដើម្បីនាំ ខ្លួនអ្នកទទួលខុសត្រូវចំពោះការបាត់ខ្លួនរបស់ជនរងគ្រោះមកកាត់សេចក្តី ទោះបីពុំមានចែងក្នុងច្បាប់លើកលែងទោសថ្នាក់ជាតិក្តី"), *សំណុំរឿង Hugo Rodriguez ទល់នឹង Uruguay* , យោបល់លេខ ៣២២/១៩៨៨, ទស្សនៈ, គណៈកម្មាធិការសិទ្ធិមនុស្ស, ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤, កថាខណ្ឌ ១២.៤ ("ការលើកលែងទោស ចំពោះការរំលោភសិទ្ធិមនុស្សដ៏កម្រោល ...ពុំស្របទៅនឹងកាតព្វកិច្ចរបស់រដ្ឋភាគីនៃកតិកាសញ្ញានេះឡើយ"), *សូមមើលផងដែរ* សេចក្តីសន្និដ្ឋានបញ្ចប់របស់គណៈកម្មាធិការសិទ្ធិ មនុស្សស្តីពីស៊ីលី (ឯកសារអង្គការសហប្រជាជាតិ, CCPR/C/79/Add.104, ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៩៩, កថាខណ្ឌ ៧), សាធារណរដ្ឋកុងហ្គោ (ឯកសារអង្គការសហប្រជាជាតិ CCPR/C/79/Add.118, ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០០, កថាខណ្ឌ ១២), ប៉េរូ (ឯកសារអង្គការសហប្រជាជាតិ CCPR/C/79/Add.67, ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៩៦, កថាខណ្ឌ ៩ និង CCPR/CO/70/PER, ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០០, កថាខណ្ឌ ៩), លីបង់ (ឯកសារអង្គការសហប្រជាជាតិ CCPR/C/79/Add. 78, ចុះថ្ងៃទី ១ ខែ មេសា ឆ្នាំ ១៩៩៧, កថាខណ្ឌ ១២), អែលសាវ៉ាឌ័រ (ឯកសារអង្គការ សហប្រជាជាតិ CCPR/C/79/Add. 34, ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ

៤៣. មានការបកស្រាយថា អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស ក៏រាប់បញ្ចូលនូវការហាមឃាត់ការអនុគ្រោះទោសចំពោះការរំលោភសិទ្ធិជាសារវ័ន្ត និងកាតព្វកិច្ចក្នុងការស៊ើបអង្កេត និងចោទប្រកាន់អំពើទាំងនោះ និងការផ្តន្ទាទោសចារី[៥០]។ នៅក្នុងសំណុំរឿង *Almonacid-Arellano ទល់នឹង Chile* តុលាការអន្តរអាមេរិកបានយល់ឃើញថា "រដ្ឋទាំងឡាយពុំអាចពុំអើពើបានឡើយចំពោះកាតព្វកិច្ចរបស់ខ្លួនក្នុងការស៊ើបអង្កេត កំណត់អត្តសញ្ញាណ និងផ្តន្ទាទោសជនទាំងឡាយណាដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការអនុវត្តច្បាប់អនុគ្រោះទោស ឬបញ្ញត្តិជាតិផ្សេងៗដែលស្រដៀងនេះ។ ហេតុដូច្នេះ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិគឺជាឧក្រិដ្ឋកម្មដែលពុំអាចអនុគ្រោះទោសបានឡើយ"[៥១]។ តាមរយៈនេះ គណៈកម្មការអន្តរអាមេរិកស្តីពីសិទ្ធិមនុស្ស និងតុលាការអន្តរអាមេរិក បានចាត់ទុកច្បាប់អនុគ្រោះទោសនៅអាហ្សង់ទីន ស៊ីលី អែលសាល់វ៉ាឌ័រ ប៉េរូ អ៊ុយរូហ្គាយ ប្រេស៊ីល ថារំលោភ ឬពុំស្របទៅនឹងអនុសញ្ញាខាងលើ[៥២]។

---

១៩៩៤, កថាខណ្ឌ ៤,៥), ហៃទី (CCPR/C/79/Add. 49, ចុះថ្ងៃទី ៣ ខែ តុលា ឆ្នាំ ១៩៩៥, កថាខណ្ឌ ២៣០-២៣៥) និង អ៊ុយរូហ្គាយ (ឯកសារអង្គការសហប្រជាជាតិ CCPR/C/79/Add.19, ចុះថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ១៩៩៣, កថាខណ្ឌ ៧,១១)។

[៥០] *សូមមើលសំណុំរឿង Velasquez Rodriguez,* សាលក្រម, តុលាការសិទ្ធិមនុស្សអន្តរអាមេរិក ("IACtHR), ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៨៨, ស៊េរី C លេខ ៤, កថាខណ្ឌ១៦៦, ១៧៤,១៧៦, *សំណុំរឿង Barrios Altos (Chumbipuma Aguirre & Ors ទល់នឹង ប៉េរូ),* សាលក្រម, IACtHR, ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០១, ស៊េរី C លេខ ៧៥, កថាខណ្ឌ ៤១, ៤៤ ("បញ្ញត្តិលើកលែងទោសទាំងអស់, បញ្ញត្តិស្តីពីអាជ្ញាយុកាល និងការបង្កើតវិធានការដើម្បីលុបបំបាត់ការទទួលខុសត្រូវ គឺពុំអាចទទួលយកបានឡើយ ពីព្រោះបញ្ញត្តិទាំងអស់នោះមានចេតនារាំងការស៊ើបអង្កេត និងការផ្តន្ទាទោសជនទាំងឡាយណាដែលទទួលខុសត្រូវចំពោះអំពើរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរដូចជា អំពើទារុណកម្ម, ការសម្លាប់ក្រៅប្រព័ន្ធតុលាការ ការសម្លាប់ដោយទាន់ហន់ ឬការសម្លាប់តាមទំនើងចិត្ត និងការបាត់ខ្លួនដោយបង្ខំ។ ទាំងអស់នេះត្រូវបានហាមឃាត់ពីព្រោះវាជាការបំពានទៅលើសិទ្ធិដែលមិនអាចរំលោភបាន ដែលច្បាប់សិទ្ធិមនុស្សអន្តរជាតិបានទទួលស្គាល់"), *សូមមើលផងដែរ សំណុំរឿង La Cantuta ទល់នឹង Peru Case,* សាលក្រម, IAtHR, ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៦, ស៊េរី C, លេខ ១៦២ (២០០៦), កថាខណ្ឌ ១៥២។

[៥១] *សំណុំរឿង Almonacid-Arellano et al. ទល់នឹង ស៊ីលី,* សាលក្រម (អញ្ញត្រកម្ម, អង្គសេចក្តី, សំណង និងសោហ៊ុយ), IACtHR, ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០៦, កថាខណ្ឌ ៩៩, ១១០-១១៤, ១១៩-១២០ ("ការហាមឃាត់ការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិគឺជាវិធាន jus cogens [និង] ការផ្តន្ទាទោសឧក្រិដ្ឋកម្មទាំងនេះគឺជាកាតព្វកិច្ចចាំបាច់ដោយអនុលោមតាមគោលការណ៍ទូទៅនៃច្បាប់អន្តរជាតិ"), *សូមមើលផងដែរ សំណុំរឿង Gomes Lund et al ("Guerrilha do Araguaia") ទល់នឹង Brazil,* សាលក្រម, IACtHR, ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១០, កថាខណ្ឌ ១៧៥ (មានតែជាភាសាអេស្ប៉ាញប៉ុណ្ណោះ) (ការហាមឃាត់ការលើកលែងទោសចំពោះអំពើរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ពុំកំហិតត្រឹមការលើកលែងទោសដោយខ្លួនឯងដែលរបបមួយបានផ្តល់ឲ្យដើម្បីបិទបាំងឧក្រិដ្ឋកម្មរបស់ខ្លួនឡើយ)។

[៥២] *សូមមើលឧទាហរណ៍ Consuelo Herrera et al ទល់នឹង អាហ្សង់ទីន,* IACHR, របាយការណ៍លេខ ២៨/៩២, សំណុំរឿង ១០.១៤៧, ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៩២, កថាខណ្ឌ ៤១, *សំណុំរឿង Garay Hermosilla et al ទល់នឹង ស៊ីលី,* IACHR,

៩៤. សិទ្ធិក្នុងការទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព ក្រោមអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ក៏ត្រូវបានបកស្រាយថាសិទ្ធិនេះបានរាប់បញ្ចូលទាំងការស៊ើបអង្កេតដែលអាចនាំទៅដល់ការកំណត់អត្តសញ្ញាណ និងការផ្តន្ទាទោសអ្នកទទួលខុសត្រូវចំពោះការរំលោភសិទ្ធិមនុស្ស[៩៣] តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចទៀតថា ការអនុគ្រោះទោសមិនត្រូវអនុញ្ញាតចំពោះបទល្មើសដូចជា មនុស្សឃាត និងការធ្វើទារុណកម្ម ឡើយ[៩៤] ហើយតតីយប្រទេស ពុំជាប់កាតព្វកិច្ច ចំពោះខស្តីពីការអនុគ្រោះទោសដែលរំលោភកាតព្វកិច្ចក្នុងការចោទប្រកាន់បទល្មើស *វិធានអាជ្ញាបញ្ញា*[៩៥]។

៩៥. គណៈកម្មការអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាជន ក៏បានយល់ឃើញថា ការអនុគ្រោះទោសឲ្យចារីរួចផុតពីការទទួលខុសត្រូវលើបទល្មើសធ្ងន់ធ្ងរក្រោមច្បាប់អន្តរជាតិ គឺជាការរំលោភសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព និងជាការល្មើសទៅនឹងកាតព្វកិច្ចរបស់រដ្ឋភាគីក្នុងការចោទប្រកាន់ និងផ្តន្ទាទោសចំពោះអំពើបំពារបំពានធ្ងន់ធ្ងរ

---

របាយការណ៍លេខ ៣៦/៩៦, សំណុំរឿង ១០.៨៤៣, ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩៦, កថាខណ្ឌ ១០៥, *សំណុំរឿង Almonacid-Arellano et al. ទល់នឹង ស៊ីលី,* សាលក្រម (អញ្ញត្រកម្ម, អង្គសេចក្តី, សំណង និងសោហ៊ុយ), IACtHR, ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០៦, *សំណុំរឿង Lucio Parada Cea et al ទល់នឹង Elsavador,* IACtHR, របាយការណ៍លេខ ១/៩៩, សំណុំរឿង ១០.៤៨០, ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៩, កថាខណ្ឌ ១០៧ និង ១២៣, *សំណុំរឿង Rodolfo Roble Espinoza and Sons ទល់នឹង ប៉េរូ,* IACHR, របាយការណ៍លេខ ២០/៩៩, សំណុំរឿង ១១.៣១៧, ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៩, កថាខណ្ឌ ១៥៩-១៦០, *សំណុំរឿង Barrios Altos (Chumbipuma Aguirre & Ors ទល់នឹង ប៉េរូ),* សាលក្រម, IACtHR, ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០១, ស៊េរី C, លេខ ៧៥, *សំណុំរឿង Mendoza et al ទល់នឹង Uruguay,* IACHR, របាយការណ៍លេខ ២៩/៩២, សំណុំរឿង ១០.០២៩, ចុះថ្ងៃទី ២ ខែ តុលា ឆ្នាំ ១៩៩២, កថាខណ្ឌ ៥០-៥១, *សំណុំរឿង Gelman ទល់នឹង Uruguay,* IACtHR, ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១, ស៊េរី C, លេខ ២២១, កថាខណ្ឌ ២៤១, *សំណុំរឿង Gomes Lund et al ("Guerrilha do Araguaia") ទល់នឹង ប្រេស៊ីល,* សាលក្រម, IACtHR, ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១០, កថាខណ្ឌ ១៧២ (មានតែជា ភាសាអេស្ប៉ាញប៉ុណ្ណោះ) (ដែលបានយល់ថាការបកស្រាយនិងការអនុវត្តច្បាប់លើកលែងទោសរបស់ប្រេស៊ីលប៉ះពាល់ទៅដល់ភារកិច្ចជាអន្តរជាតិរបស់រដ្ឋនេះក្នុងការស៊ើបអង្កេត និងផ្តន្ទាទោសការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ និងជាការរំលោភលើអនុសញ្ញានេះ)។

[៩៣] *សូមមើលឧទាហរណ៍ សំណុំរឿង Aksoy ទល់នឹង ទួរគី,* លេខបណ្តឹង ២១៩៨៧/៩៣, សាលក្រម, តុលាការសិទ្ធិមនុស្សអឺរ៉ុប ECHR, ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩៦។

[៩៤] *សំណុំរឿង Abdulsamet Yaman ទល់នឹង ទួរគី,* សាលក្រម, តុលាការ ECHR, បណ្តឹងលេខ ៣២៤៤៦/៩៦, ចុះថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០០៤, កថាខណ្ឌ ៥៣,៥៥, *សំណុំរឿង Tuna ទល់នឹង ទួរគី,* សាលក្រម, តុលាការ ECHR, បណ្តឹងលេខ ២២៣៣៩/០៣, ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១០, កថាខណ្ឌ ៧១។

[៩៥] *សំណុំរឿង Ould Dah c. France,* បណ្តឹងលេខ ១៣១១៣/០៣, តុលាការ ECHR, ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩, ត្រង់ទំព័រ ១៦-១៧ (សំណៅជាភាសាបារាំង)។

00751131



ទៅលើសិទ្ធិមួយចំនួនដែលមានចែងក្នុងធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាជន[៥៦]។

៤៦. តុលាការពិសេសសម្រាប់សៀរ៉ាឡេអូនបានទទួលស្គាល់ "និយាមអន្តរជាតិច្បាស់លាស់ដែលមិនអនុញ្ញាតឱ្យរដ្ឋាភិបាលផ្តល់ការអនុគ្រោះទោស" ចំពោះបទល្មើសក្រោមច្បាប់អន្តរជាតិ ដោយសម្រេចថា ច្បាប់អន្តរជាតិពុំអនុញ្ញាតឱ្យមានការអនុគ្រោះទោស ឡើយ[៥៧]។ នៅក្នុងការប្រកាសថាខ្លួនពុំជាប់កាតព្វកិច្ចចំពោះការអនុគ្រោះទោសនោះ តុលាការពិសេសសម្រាប់ សៀរ៉ាឡេអូន បានកត់សម្គាល់ឃើញថា រដ្ឋមានកាតព្វកិច្ចចោទប្រកាន់បទល្មើស *វិធានអាជ្ញាបញ្ញា* ហើយការ

---

[៥៦] *សំណុំរឿង* Mouvement Ivorien de Droits Humains (MIDH) *ទល់នឹង* Cote dIvoire, យោបល់លេខ ២៤៦/២០០២, សេចក្តីសម្រេច, ACHPR, ខែ កក្កដា ឆ្នាំ ២០០៨, កថាខណ្ឌ ៩៧-៩៨, *សំណុំរឿង* Malawi African Association and Others *ទល់នឹង* Mauritania, យោបល់លេខ ៥៤/៩១, ៦១/៩១, ៩៨/៩៣, ១៦៤/៩៧-១៩៦/៩៧ និង ២១០/៩៨, សេចក្តីសម្រេច, ACHPR, ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០០, កថាខណ្ឌ ៨២-៨៣, *សូមមើលផងដែរ* ACHPR *សំណុំរឿង* Zimbabwe Human Rights NGO Forum *ទល់នឹង* Zimbabwe, យោបល់លេខ ២៤៥/០២, សេចក្តីសម្រេច, ACHPR, ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦, កថាខណ្ឌ ២១១ និង ២១៥។

[៥៧] *សំណុំរឿង រដ្ឋអាជ្ញា ទល់នឹង* Kallon and Kamara, សាលដីកាលើការជំទាស់ទៅនឹងយុត្តាធិការ៖ Lomé Accord Amnesty, សំណុំរឿងលេខ SCSL-04-15-AR72(E), និងសំណុំរឿង លេខ SCSL-04-16-AR72(E), អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ SCSL, ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៤ ("សាលដីកា *Kallon*"), កថាខណ្ឌ ៨២, *សូមមើលផងដែរសំណុំរឿង រដ្ឋអាជ្ញា ទល់នឹង* Gbao, សាលដីកាលើបណ្តឹងបឋមស្តីពីអសុពលភាពនៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលសៀរ៉ាឡេអូនស្តីពីការបង្កើតតុលាការពិសេស សំណុំរឿងលេខ SCSL-04-15-PT, អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ SCSL, ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៤, កថាខណ្ឌ ៨-១០ (ដែល បានយល់ថា "រដ្ឋទាំងឡាយមានភារកិច្ចចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មដែលការហាមឃាត់មិនឱ្យមានការចោទប្រកាន់គឺជា *វិធានអាជ្ញាបញ្ញា*' ហើយ "មានមូលដ្ឋានបង្អែក [...] ចំពោះការលើកឡើងថាមាននិយាមអន្តរជាតិច្បាស់លាស់ជាធរមានដែលចែងថារដ្ឋាភិបាល ពុំអាចលើកលែងទោសចំពោះបទល្មើសធ្ងន់ធ្ងរក្រោមច្បាប់អន្តរជាតិ"), *សំណុំរឿង រដ្ឋអាជ្ញា ទល់នឹង* Norman, Fofana *និង* Kondewa, សាលដីកាលើបញ្ហាការខ្វះយុត្តាធិការ/ការរំលោភបំពានដំណើរការ៖ ការលើកលែងទោសដែលកិច្ចព្រមព្រៀង Lome បានផ្តល់, សំណុំរឿង SCSL-04-14-AR72(E), អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ SCSL, ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៤ ("សាលដីកា *Kondewa*") (ដែលយល់ថាការលើក លែងទោសទាំងស្រុងពុំអាចធ្វើទៅបានចំពោះបទល្មើសក្រោមច្បាប់អន្តរជាតិ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះបទល្មើសទាំងនេះ។ ការលើកលែងទោសជាការរំលោភកាតព្វកិច្ច*សម្រាប់ទាំងអស់គ្នា* ក្រោមច្បាប់អន្តរជាតិ ហើយមាននិយាមអន្តរជាតិដែលចែងច្បាស់ថារដ្ឋាភិបាលពុំអាចលើកលែងទោសចំពោះបទល្មើសធ្ងន់ធ្ងរក្រោមច្បាប់អន្តរជាតិបានឡើយ), *សូមមើលផងដែរ* នូវយោបល់ដោយឡែករបស់ចៅក្រម Robertson ក្នុងសំណុំរឿងនេះ (ដែលបានយល់ឃើញថាវិធានប្រឆាំងនឹងនិទ្ទណ្ឌភាពដែលមាននៅក្នុងច្បាប់អន្តរជាតិគឺជានិយាមមួយដែលបដិសេធលទ្ធភាពគតិយុត្តិ ក្នុងការអនុគ្រោះទោសដល់ជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមធ្ងន់ធ្ងរដែលកើតឡើងជាទូទៅ ហើយច្បាប់ព្រហ្មទណ្ឌអន្តរជាតិពុំបានផ្តល់សុពលភាពដល់ការលើកលែងទោស ដែលបានធ្វើឡើងទោះក្រោមកាលៈទេសៈណាក៏ដោយដល់អ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (កថាខណ្ឌ ៤៩,៥១)។

អនុគ្រោះទោសរបស់ប្រទេសសៀរ៉ាឡេអូន ពុំអាចគ្របដណ្តប់លើបទល្មើសនានាក្រោមច្បាប់ អន្តរជាតិដែលជាកម្មវត្ថុនៃយុត្តាធិការសកលបានឡើយ[៩៨]។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី (ICTY) ក៏បានសម្រេចដែរថា "[ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ] គឺជាអំពើអមនុស្សធម៌ ដែលសហគមន៍អន្តរជាតិមិនអាចអត់ឱនបានដោយហេតុតែឧក្រិដ្ឋកម្មនេះ មានទំហំធំធេង និងមានភាពធ្ងន់ធ្ងរដែលត្រូវផ្តន្ទាទោសជាចាំបាច់"[៩៩]។

៤៧. ការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការព្រហ្មទណ្ឌកូនកាត់មួយចំនួននៅក្នុងរយៈកាល ២ ទសវត្សរ៍កន្លងមក ដែលក្នុងនោះមាន អ.វ.ត.ក ផងដែរ គឺជាភស្តុតាងមួយទៀតដែលបញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់រដ្ឋនានាក្នុងការធានាថា បទល្មើសក្រោមច្បាប់អន្តរជាតិពិតជាពុំអាចលើកលែងទោសបានឡើយ[១០០]។ច្បាប់លក្ខន្តិកៈតុលាការ ICTY និងតុលាការ ICTR ដែលក្រុមប្រឹក្សាសន្តិសុខបានអនុម័តជាឯកច្ឆ័ន្ទ បានបញ្ជាក់យ៉ាងច្បាស់នូវប្រភេទនៃបទល្មើសដែលត្រូវចោទប្រកាន់ និងផ្តន្ទាទោសជាចាំបាច់ ហើយលក្ខន្តិកៈតុលាការពិសេសសម្រាប់សៀរ៉ាឡេអូន និងតុលាការពិសេសសម្រាប់លីបង់ បានចែងថា ការអនុគ្រោះទោសដល់បុគ្គលទាំងឡាយដែលស្ថិតក្រោមយុត្តា

---

[៩៨] សាលដីកា *Kallon,* កថាខណ្ឌ ៧១,៨២,៨៤ ("តុលាការនេះអាចអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការពុំពិចារណាទៅលើការលើកលែងទោសទាំងអស់នោះដែលផ្ទុយពីដំណើរវិវឌ្ឍន៍នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក៏ដូចជាកាតព្វកិច្ចនានាដែលមានចែងក្នុងសន្ធិសញ្ញា និងអនុសញ្ញាមួយចំនួនដែលមានគោលដៅការពារមនុស្សជាតិ")។

[៩៩] សំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង Erdemovic,* សំណុំរឿងលេខ IT-96-22-T, សាលក្រមផ្តន្ទាទោស, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦, កថាខណ្ឌ ២៨, *សូមមើលផងដែរសំណុំរឿង រដ្ឋអាជ្ញា ទល់នឹង Furundzija,* សំណុំរឿងលេខ IT-95-17/1-T, សាលក្រម, អង្គជំនុំជម្រះតុលាការសាលាដំបូង ICTY, ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៩៨, កថាខណ្ឌ ១៥៥-១៥៦ (នៅក្នុងការវិភាគរបស់ខ្លួនអំពីអំពើទារុណកម្ម អង្គជំនុំជម្រះតុលាការសាលាដំបូងបានចាត់ទុកអំពើទារុណកម្មថាជាឧក្រិដ្ឋកម្ម *វិធានអាជ្ញាបញ្ញា* ដែលក្នុងនោះ "ចារីដែលបានប្រព្រឹត្តតាម ឬបានផលប្រយោជន៍ពី [វិធានការថ្នាក់ជាតិដែលអនុញ្ញាត ឬបណ្តែតបណ្តោយឲ្យមានអំពើទារុណកម្ម ឬលើកលែងទោសចារីតាមរយៈច្បាប់លើកលែងទោស] ក៏នៅតែអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះអំពើទារុណកម្មដោយរបបដែលបានឡើងកាន់អំណាចនាពេលបន្ទាប់ ទោះបីចារីនោះស្ថិតនៅក្នុងប្រទេស ឬក្រៅប្រទេសក្តី")។

[១០០] *សូមមើល ឧទាហរណ៍* តុលាការ ICTY (ឆ្នាំ ១៩៩៣), តុលាការ ICTR (ឆ្នាំ ១៩៩៤), តុលាការ SCSL (២០០២), តុលាការកូនកាត់នៅកូសូវ៉ូ (ឆ្នាំ ១៩៩៩), តុលាការពិសេសសម្រាប់កាត់ សេចក្តីឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅទីម័រខាងកើត (ឆ្នាំ ១៩៩៩), តុលាការពិសេសសម្រាប់លីបង់ (ឆ្នាំ ២០០៧), តុលាការឧក្រិដ្ឋកម្មសង្គ្រាមបូស្នី និងហឺហ្សេហ្គោវីណានៅឆ្នាំ ២០០៥ និង អ.វ.ត.ក (ឆ្នាំ ២០០៣)។

ធិការតុលាការជាតិនីមួយៗ ពុំត្រូវរាំងរាំងដល់ការចោទប្រកាន់ណាមួយឡើយ[១០១]។

៤៨. ប្រភពបន្ទាប់បន្សំផ្សេងៗនៃច្បាប់អន្តរជាតិ ដូចជាសេចក្តីសម្រេចជាច្រើនរបស់មហាសន្និបាតអង្គការសហប្រជាជាតិ[១០២] របាយការណ៍របស់អគ្គលេខាធិការអង្គសហប្រជាជាតិ[១០៣] របាយការណ៍

---

[១០១] *សូមមើល* សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ៨២៧ (ឆ្នាំ ១៩៩៣) ដែលបានបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី, ឯកសារ អ.ស.ប S/RES/827 (ឆ្នាំ ១៩៩៣), ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៩៣, សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ៩៥៥ (ឆ្នាំ ១៩៩៤) ដែលបានបង្កើតតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រវ៉ាន់ដា, ឯកសារ អ.ស.ប S/RES/955 (ឆ្នាំ ១៩៩៤), ចុះថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤, *សូមមើលផងដែរ* មាត្រា ១០ នៃច្បាប់លក្ខន្តិកៈឆ្នាំ ២០០២ របស់តុលាការពិសេសសម្រាប់សៀរ៉ាឡេអូន, មាត្រា ១៦ នៃកិច្ចព្រមព្រៀងឆ្នាំ ២០០៧ រវាង អ.ស.ប និងសាធារណរដ្ឋលីបង់ស្តីពីការបង្កើតតុលាការពិសេសសម្រាប់លីបង់ និងមាត្រា ៦ នៃលក្ខន្តិកៈតុលាការពិសេសសម្រាប់លីបង់ (ដែលបានចែងថាការលើកលែងទោសដែលបានផ្តល់ឱ្យជនទាំងឡាយណាដែលស្ថិតក្រោមយុត្តាធិការតុលាការនីមួយៗនេះ ពុំអាចរាំងការចោទប្រកាន់បានឡើយ)។

[១០២] *សូមមើលឧទាហរណ៍* សេចក្តីសម្រេចរបស់មហាសន្និបាតស្តីពីបញ្ហាផ្តន្ទាទោសឧក្រិដ្ឋជនសង្គ្រាម និងជនដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, មហាសន្និបាត, សេចក្តីសម្រេចលេខ ២៨៤០ (XXVI), អ.ស.ប, ឯកសារផ្លូវការបន្ថែមរបស់ អ.ស.ប (លេខ ២៩) ត្រង់ទំព័រ ៨៨, ឯកសារ អ.ស.ប លេខ A/៨៤២៩ (ឆ្នាំ ១៩៧១) (ដែលបានជំរុញឱ្យរដ្ឋ "ធានាឱ្យមានការផ្តន្ទាទោសជនទាំងឡាយណាដែលមានទោសពីបទ [ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ]"), គោលការណ៍សហប្រតិបត្តិការអន្តរជាតិឆ្នាំ១៩៧៣ក្នុងការស្វែងរកចាប់ខ្លួន និងបញ្ជូនខ្លួនយកមកផ្តន្ទាទោសជនទាំងឡាយណាដែលជាប់ទោសពីបទឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (សេចក្តីសម្រេចរបស់មហាសន្និបាតលេខ ៣០៧៤ (XXVIII), ឯកសារផ្លូវការបន្ថែមរបស់មហាសន្និបាតអង្គការសហប្រជាជាតិ (លេខ ៣០) ត្រង់ទំព័រ ៧៩, ឯកសារ អ.ស.ប A/9030 (ឆ្នាំ ១៩៧៣), គោលការណ៍ទី១ ("នៅពេលមានការប្រព្រឹត្តិឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវមានការស៊ើបអង្កេត ហើយត្រូវស្វែងរកចាប់ខ្លួនមកជំនុំជម្រះ និងផ្តន្ទាទោសប្រសិនបើរកឃើញថាមានទោសចំពោះជនទាំងឡាយណាដែលមានភស្តុតាងថាបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ") និងសេចក្តីសម្រេចរបស់មហាសន្និបាតស្តីពីបញ្ហាផ្តន្ទាទោសឧក្រិដ្ឋជនសង្គ្រាម និងជនទាំងឡាយណាដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, សេចក្តីសម្រេចរបស់ អ.ស.ប លេខ ២៥៨៣ (XXIV), ឯកសារផ្លូវការបន្ថែមរបស់មហាសន្និបាតអង្គការសហប្រជាជាតិ (លេខ ៣០) ត្រង់ទំព័រ ៥៨, ឯកសារ អ.ស.ប A/7630 (ឆ្នាំ ១៩៦៩),កថាខណ្ឌ១ (ដែលបានស្នើឱ្យរដ្ឋ "ចាត់វិធានការចាំបាច់ដើម្បីស៊ើបអង្កេតឱ្យបានល្អិតល្អន់អំពីឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ... និងដើម្បីស្វែងរកចាប់ខ្លួនបញ្ជូនខ្លួនមកផ្តន្ទាទោសចំពោះឧក្រិដ្ឋជនសង្គ្រាមទាំងអស់ និងជនទាំងឡាយណាដែលមានទោសពីបទឧក្រិដ្ឋកម្ម ប្រឆាំងនឹងមនុស្សជាតិ")។

[១០៣] *សូមមើលឧទាហរណ៍* របាយការណ៍របស់អគ្គលេខាធិការ អ.ស.ប ដែលមានចំណងជើងថា "វិធាននៃច្បាប់ និងយុត្តិធម៌អន្តរកាលនៅក្នុងសង្គមពេលមានជម្លោះ និងក្រោយជម្លោះ", ឯកសារ អ.ស.ប S/2004/616, ចុះថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០០៤, កថាខណ្ឌ ១០ និង កថាខណ្ឌ ២២ (ដោយបានណែនាំឱ្យក្រុមប្រឹក្សាសន្តិសុខធានាថាកិច្ចព្រមព្រៀងសន្តិភាព និងសេចក្តីសម្រេចក៏ដូចជាអាណត្តិរបស់ខ្លួន "ពុំបានគាំទ្រដល់ការលើកលែងទោសចំពោះអំពើប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មសង្គ្រាម, ឬឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ,[...ហើយ] ការលើកលែងទោសនាពេលកន្លងមកពុំអាចរាំងការចោទប្រកាន់ចំពោះមុខតុលាការដែល

របស់អ្នករាយការណ៍ពិសេសនានា[១០៤] ក៏បានទទួលស្គាល់កាតព្វកិច្ចក្នុងការចោទប្រកាន់បទល្មើសធ្ងន់ធ្ងរក្រោមច្បាប់អន្តរជាតិ និងវិសមិតភាពនៃការអនុគ្រោះទោសចំពោះបទល្មើសទាំងនេះជាមួយនឹងគោលបំណងនៃកាតព្វកិច្ចទាំងអស់នេះ ហើយថែមទាំងបានឆ្លុះបញ្ចាំងអំពីទស្សនៈភាគច្រើននៃបណ្តារដ្ឋក្នុងសហគមន៍អន្តរជាតិ។

៤៩. តាមច្បាប់ការសន្និដ្ឋានខាងលើផ្អែកលើការពិនិត្យមើលទៅលើការអនុម័តវិសាលភាព និងការអនុវត្តការអនុគ្រោះទោសនៅក្នុងប្រទេសដែលកំពុងមានជម្លោះ ឬក្រោយពេលមានជម្លោះនៅក្នុងរយៈកាលពាទសវត្សរ៍ចុងក្រោយនេះ[១០៥]។ នៅក្នុងការពិនិត្យមើលបរិបទជុំវិញការអនុគ្រោះទោស

---

អង្គការសហប្រជាជាតិបានជួយជ្រោមជ្រែង ឬបានបង្កើតឡើងឡើយ" និងគូសបញ្ជាក់ថាការលើកលែងទោសពុំអាចធ្វើទៅបានឡើយចំពោះបទល្មើសក្រោមច្បាប់អន្តរជាតិនានា ដូចជាបទល្មើសប្រល័យពូជសាសន៍, បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬបទបំពារបំពានធ្ងន់ធ្ងរផ្សេងៗទៅលើច្បាប់មនុស្សធម៌អន្តរជាតិ), *សូមមើលបន្ថែមទៀត* នូវរបាយការណ៍របស់អគ្គលេខាធិការស្តីពីការបង្កើតតុលាការពិសេសសម្រាប់សៀរ៉ាឡេអូន, S/2000/915, ចុះថ្ងៃទី ៤ ខែ តុលា ឆ្នាំ ២០០០, កថាខណ្ឌ ២២ (ដោយបានកត់សម្គាល់ថា "ទោះបីអង្គការសហប្រជាជាតិបានទទួលស្គាល់ថាការលើកលែងទោសគឺជាទស្សនាទានគតិយុត្តិ ដែលបានការទទួលស្គាល់ និងជាកាយវិការដើម្បីសន្តិភាព និងការផ្សះផ្សានៅពេលចប់សង្គ្រាមស៊ីវិល ឬជម្លោះប្រដាប់អាវុធផ្ទៃក្នុងក្តី ក៏អង្គការសហប្រជាជាតិនៅតែប្រកាន់ជំហរថាការលើកលែងទោសពុំអាចធ្វើទៅបានឡើយចំពោះឧក្រិដ្ឋកម្មក្រោមច្បាប់អន្តរជាតិ, ដូចជាបទល្មើសប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬអំពើរំលោភបំពានធ្ងន់ធ្ងរផ្សេងៗទៅលើច្បាប់មនុស្សធម៌អន្តរជាតិ")។

[១០៤] *សូមមើលឧទាហរណ៍* របាយការណ៍ស្ថាពររបស់អ្នករាយការណ៍ពិសេសលោក Cherif Bassiouni, ដែលបានដាក់អនុលោមតាមសេចក្តីសម្រេចរបស់គណៈកម្មការ ឆ្នាំ ១៩៩៩/៣៣ (សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ រួមទាំងបញ្ហា...និទ្ទណ្ឌភាព), ឯកសារ អ.ស.ប, E/CN.4/2000/62, ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០០, គោលការណ៍ ៣, របាយការណ៍របស់ Diane Orentlicher, អ្នកជំនាញឯករាជ្យក្នុងការធ្វើបច្ចុប្បន្នភាពទៅលើបណ្តុំគោលការណ៍ទាំងនេះដើម្បីលុបបំបាត់និទ្ទណ្ឌភាព, ឯកសារ អ.ស.ប E/CN.4 /2005/102/Add. 1, ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០០៥, គោលការណ៍១។ ក្នុងពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀង Lomé តំណាងពិសេសរបស់អគ្គលេខាធិការ អ.ស.ប ទទួលបន្ទុកបញ្ហាសៀរ៉ាឡេអូន, បានដាក់បន្ថែមនូវលក្ខខណ្ឌមួយដែលចែងថាបញ្ញត្តិលើកលែងទោសដែលមាននៅក្នុងកិច្ចព្រមព្រៀងនេះពុំអាចយកមកអនុវត្តចំពោះបទល្មើសក្រោមច្បាប់អន្តរជាតិបានឡើយ រួមមានឧក្រិដ្ឋកម្មប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, ឧក្រិដ្ឋកម្មសង្គ្រាម និងអំពើបំពារបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ (*សូមមើល* របាយការណ៍របស់អគ្គលេខាធិការ អ.ស.ប ស្តីពីការបង្កើតតុលាការពិសេសសម្រាប់សៀរ៉ាឡេអូន, S/2000/915, ចុះថ្ងៃទី ៤ ខែ តុលា ឆ្នាំ ២០០០, កថាខណ្ឌ ២៣, *ដែលបានលើកយកមកធ្វើជាសំអាងនៅក្នុងសំណុំរឿង រដ្ឋអាជ្ញាទល់នឹង Kondewa,* កថាខណ្ឌ ៨)។

[១០៥] អង្គជំនុំជម្រះបានពិនិត្យឡើងវិញនូវទម្លាប់អនុវត្តន៍ជុំវិញការលើកលែងទោសនៅស៊ីលី (ក្រឹត្យច្បាប់ឆ្នាំ ១៩៧៨ ស្តីពីការលើកលែងទោស ដែលរាប់បញ្ចូលនូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅចន្លោះពីឆ្នាំ១៩៦១ ដល់ឆ្នាំ ១៩៧៤), អាហ្សង់ទីន (ច្បាប់ Full Stop Law ឆ្នាំ ១៩៨៦ និង ច្បាប់ Due Obedience ឆ្នាំ ១៩៨៧, ដែលគ្របដណ្តប់លើឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រព្រឹត្តនៅមុនខែ ធ្នូ

នានា (ពិសេសការមិនរាប់បញ្ចូលនូវបទល្មើសមួយចំនួន, អ្នកដែលត្រូវទទួលការអនុគ្រោះទោស, លក្ខខណ្ឌ និងការបកស្រាយ និងអនុវត្តការអនុគ្រោះទោសរបស់តុលាការ) អង្គជំនុំជម្រះ សន្និដ្ឋានថា ទម្លាប់អនុវត្តន៍បានចាត់ទុកការអនុគ្រោះទោសទាំងស្រុងចំពោះបទល្មើសធ្ងន់ធ្ងរ ក្រោមច្បាប់អន្តរជាតិ ថាជាការរំលោភបំពានលើនិយាមអន្តរជាតិ។ ជាងនេះទៅទៀត តុលាការប្រទេសស៊ីលី[១០៦] អាហ្សង់ទីន[១០៧] អ៊ុយរូហ្គាយ[១០៨] ហុងឌូរ៉ាស[១០៩] ប៉េរូ[១១០] និងកូឡុំប៊ី[១១១] សុទ្ធតែបានចាត់ទុកជា

---

ឆ្នាំ ១៩៨៣), អ៊ុយរូហ្គាយ (ច្បាប់មោឃភាព ឆ្នាំ ១៩៨៦), ហុងឌូរ៉ាស (ក្រឹត្យលេខ ៨៧-៩១ ឆ្នាំ ១៩៩១), សូរីណាម (ច្បាប់ឆ្នាំ ១៩៩២ ដែលចែងអំពីការផ្តល់ការលើកលែងទោស, ក្រឹត្យលេខ ៥៥៤៤), អែលសាវ៉ាឌ័រ (ច្បាប់ផ្សះផ្សាជាតិឆ្នាំ ១៩៩២, ក្រឹត្យច្បាប់លេខ ១៤៧) និងច្បាប់លើកលែងទោសទូទៅឆ្នាំ ១៩៩៣ ដើម្បីសន្តិភាព, ក្រឹត្យច្បាប់លេខ ៤៨៦), នីការ៉ាហ្គា (ច្បាប់លើកលែងទោសឆ្នាំ ១៩៩៣), ម៉ូរីតានី (ច្បាប់លើកលែងទោសឆ្នាំ ១៩៩៣), កម្ពុជា (ឆ្នាំ ១៩៩៤), ហៃទី (ច្បាប់ឆ្នាំ ១៩៩៤ ពាក់ព័ន្ធនឹងការលើកលែងទោស), ប៉េរូ (ច្បាប់លើកលែងទោសឆ្នាំ ១៩៩៥ លេខ ២៦៤៧៩), អាហ្វ្រិកខាងត្បូង (ការលើកកម្ពស់ឯកភាពជាតិឆ្នាំ ១៩៩៥ និងការផ្សះផ្សា), ក្វាតេម៉ាឡា (ច្បាប់ផ្សះផ្សាជាតិឆ្នាំ ១៩៩៦), ប៉ូឡូញ (ច្បាប់ឆ្នាំ ១៩៩៨ ស្តីពី Institute of National Rememrance), សហព័ន្ធបូស្នី និងហឺហ្សេហ្គោវីណា (ច្បាប់លើកលែងទោសឆ្នាំ ១៩៩៦ និងច្បាប់ស្តីពីការលើកលែងទោសឆ្នាំ ១៩៩៩), Republika Srpska (ច្បាប់លើកលែងទោសឆ្នាំ ១៩៩៦ និងឆ្នាំ ១៩៩៩ ស្តីពីការចោទប្រកាន់ និងវិសោធនកម្មច្បាប់លើកលែងទោស), សៀរ៉ាឡេអូន (កិច្ចព្រមព្រៀងសន្តិភាព Lomé ឆ្នាំ ១៩៩៩), វ៉េណេស៊ុយអេឡា (ច្បាប់ឆ្នាំ ២០០០ ស្តីពីការលើកលែងទោសនយោបាយទូទៅ), កូតឌីវ័រ (ច្បាប់លើកលែងទោសឆ្នាំ ២០០៣ និងបញ្ញត្តិលើកលែងទោសឆ្នាំ ២០០៧), អង់ហ្គោឡា (អនុស្សរណៈយោគយល់ឆ្នាំ ២០០៦ ដើម្បីសន្តិភាព និងការផ្សះផ្សានៅខេត្ត Cabinda ដែលត្រូវបានអនុវត្តនៅក្នុងច្បាប់លើកលែងទោសថ្នាក់ជាតិ), កូឡុំប៊ី (ច្បាប់យុត្តិធម៌ និងសន្តិភាព ២០០៥), អាល់ហ្សេរី (ធម្មនុញ្ញឆ្នាំ ២០០៥ សម្រាប់សន្តិភាព និងការផ្សះផ្សាជាតិ), ហ្វីលីពីន (ក្រឹត្យឆ្នាំ ២០០៧ លេខ ១៣៧៧), សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ (ច្បាប់លើកលែងទោសឆ្នាំ ២០០៩), ហុងឌុយរ៉ាស់ (ក្រឹត្យលើកលែងទោសឆ្នាំ ២០១០), និង ទុយនេស៊ី (ក្រឹត្យច្បាប់ឆ្នាំ ២០១១ លេខ ២០១១-១ ស្តីពីការលើកលែងទោស)។

[១០៦] តុលាការកំពូលស៊ីលី, *សំណុំរឿង Claudio Lecaros Carrasco,* ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១០, Rol. លេខ ៤៧. ២០៥, Recurso លេខ ៣៣០២/២០០៩ (ដែលចែងថាដោយហេតុតែអំពើចាប់បង្ខាំងមនុស្សដោយខុសច្បាប់គឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ទើបពុំអាចលើកលែងទោសឱ្យអំពើនេះបាន និងដែលបានយល់ថាការលើកលែងទោសដោយខ្លួនឯងគឺជាការរំលោភលើកាតព្វកិច្ចជាអន្តរជាតិរបស់ស៊ីលី)។

[១០៧] តុលាការកំពូលអាហ្សង់ទីន, *Simon, Julio Hector y otros s/privacion ilegitima de la libertad,* ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៥, Causa លេខ ១៧.៧៦៨ (ដែលបានយល់ថា Full Stop Law ឆ្នាំ ១៩៨៦ និង Due Obedience Law ឆ្នាំ ១៩៨៧ ជាច្បាប់មិនមានធម្មនុញ្ញភាព និងចាត់ទុកជាមោឃៈដោយសារច្បាប់ទាំងនេះបានរំលោភកាតព្វកិច្ចជាអន្តរជាតិរបស់អាហ្សង់ទីន និងភារកិច្ចក្នុងការចោទប្រកាន់ដែលត្រូវបានចាត់ទុកថាជានិយាម *វិធានអាជ្ញាបញ្ញា*។ តុលាការកំពូលក៏បានយល់ថាទោះបីអនុសញ្ញាស្តីពីការពុំដាក់អាជ្ញាយុកាលលើឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងអនុសញ្ញាអន្តរអាមេរិកស្តីពីការបាត់ខ្លួនដោយបង្ខំ ត្រូវបានអាហ្សង់ទីនផ្តល់សច្ចាប័នក្រោយការអនុម័តច្បាប់លើកលែងទោសក្តី ក៏អនុសញ្ញាទាំង

មោឃៈនូវច្បាប់អនុគ្រោះទោសទាំងស្រុង ឬបានកំហិតវិសាលភាពនៃការអនុវត្តច្បាប់ទាំងអស់នោះ។

៥០. ដោយផ្អែកលើគោលការណ៍យុត្តាធិការសកល រដ្ឋតតីយលោក និងតុលាការអន្តរជាតិមួយចំនួន បានចាត់ទុកថាការអនុគ្រោះទោសលើបទល្មើសធ្ងន់ធ្ងរក្រោមច្បាប់អន្តរជាតិ ពុំស្របទៅនឹងបទដ្ឋានអន្តរជាតិ ហើយដូច្នេះពុំចងកាតព្វកិច្ចឡើយ។ ក្នុងសំណុំរឿង *Ely Ould Dah* តុលាការកំពូលបារាំងបានបដិសេធពុំអនុវត្តច្បាប់ដែលអនុគ្រោះទោស Mauritanian ដោយសំអាងថា គោលការណ៍

---

នេះពុំត្រូវបានយកមកអនុវត្តជាប្រតិសកម្មឡើយ ដោយហេតុថាអនុសញ្ញាទាំងនេះបានត្រឹមតែយកច្បាប់ទំនៀមទម្លាប់ដែលមានពីមុនស្រាប់មកចងក្រងតែប៉ុណ្ណោះ)។

[១០៨] តុលាការកំពូល Uruguay, *Nibia Sabalsagary Curutchet,* ចុះថ្ងៃទី១៩ ខែ តុលា ឆ្នាំ ២០០៩, សំណុំរឿងលេខ ៣៦៥/០៩ (ដែលបានយល់ថា “Ley de Caducidad” ឆ្នាំ ១៩៨៦ ពុំមានធម្មនុញ្ញភាព)។ នៅខែ មេសា ឆ្នាំ ២០១១, ព្រឹទ្ធសភាអ៊ុយរូហ្គាយបានបោះឆ្នោតមោឃភាពនូវច្បាប់ឆ្នាំ ១៩៨៦ នេះ ប៉ុន្តែនៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១១ សភាអ៊ុយរូហ្គាយពុំបានចាត់ទុកច្បាប់នេះជាមោឃៈឡើយ។ ទោះយ៉ាងនេះក្តី ប្រធានាធិបតីប្រទេសនេះបានចាត់ទុកជាមោឃៈនូវរាល់វិធានការរដ្ឋបាលទាំងអស់ក្នុងការអនុវត្តច្បាប់ឆ្នាំ ១៩៨៦ ដោយបានដកការហាមឃាត់ការស៊ើបអង្កេត និងការចោទប្រកាន់នានាក្នុងសំណុំរឿងពាក់ព័ន្ធនឹងអំពើរំលោភសិទ្ធិមនុស្សដែលត្រូវបានប្រព្រឹត្តនៅចន្លោះពីឆ្នាំ ១៩៧៣ ដល់ឆ្នាំ ១៩៨៥ (សេចក្តីសម្រេចលេខ ៣២២/០១១, ប្រធានាធិបតីអ៊ុយរូហ្គាយ, ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១)។

[១០៩] តុលាការកំពូលហុងឌូរ៉ាស, *សំណុំរឿង Hernandez Santos* (Recurso de Amparo en Revision), ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ១៩៩៦, លេខ៦០-៩៦ (ដែលបានយល់ថាច្បាប់លើកលែងទោសនេះពុំអាចយកមកអនុវត្តបានឡើយចំពោះការឃុំខ្លួនដោយខុសច្បាប់ និងមនុស្សឃាតដោយចេតនាដែលកងកម្លាំងសន្តិសុខបានប្រព្រឹត្តក្នុងរង្វង់បរិបទនៃការបាត់ខ្លួនដោយបង្ខំ និងឃាតកម្មមួយចំនួន)។

[១១០] តុលាការធម្មនុញ្ញប៉េរូ, *Santiago Martin Rivas,* EXP. កំណត់ពន្យល់ លេខ ៤៥៨៧-២០០៤-AA/TC, ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៥ (ដែលបានចាត់ទុកច្បាប់លើកលែងទោសជាមោឃៈ)។ ការចោទប្រកាន់ និងការជំនុំជម្រះត្រូវបានធ្វើនៅប៉េរូ (*សូមមើលឧទាហរណ៍* ការជំនុំជម្រះអតីតប្រធានាធិបតីប៉េរូ Alberto Fujimori, ដែលតុលាការយុត្តិធម៌កំពូលបានផ្តន្ទាទោសពីបទរំលោភសិទ្ធិមនុស្ស។ បទល្មើសនេះមានតម្លៃស្មើនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលត្រូវបានប្រព្រឹត្តនៅឆ្នាំ ១៩៩១ និង ១៩៩២, *សំណុំរឿង Barrios Altos, La Cantuta y sotanos SIE,* Sentencia de la Sala Penal Especial en el Expediente លេខ AV 19-2001 (acumulado), ចុះថ្ងៃទី ៧ ខែ មេសា ឆ្នាំ ២០០៩)។

[១១១] តុលាការធម្មនុញ្ញកូឡុំប៊ី, Revisions Ley 742, ចុះថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០០២ (ដែលបានយល់ថាការលើកលែងទោសទាំងស្រុង, ការលើកលែងទោសដោយស្វ័យប្រវត្ត ឬវិធានការផ្សេងៗដែលដកហូតសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានសំណងជួសជុលព្យសនកម្មដោយប្រសិទ្ធភាព ជាការរំលោភលើភារកិច្ចរបស់រដ្ឋក្នុងការផ្តល់សំណងផ្លូវតុលាការដើម្បីការពារសិទ្ធិមនុស្ស), តុលាការកំពូលកូឡុំប៊ី, *Caso de Masacre de Segovia,* ខែ ឧសភា ឆ្នាំ ២០១០ (ដែលបានលើកយកមកធ្វើជាសំអាងនូវយុត្តិសាស្ត្ររបស់ IACtHR ស្តីពីការពុំទទួលស្គាល់បញ្ញត្តិលើកលែងទោសចំពោះអំពើរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ)។

យុត្តាធិការសកលនឹងគ្មានអនុភាព ប្រសិនបើខ្លួនត្រូវអនុវត្តការអនុគ្រោះទោសនេះ[១១២]។ ក្នុងសំណុំរឿង *Pinochet* តុលាការអេស្ប៉ាញបានសន្និដ្ឋានថាក្រឹត្យច្បាប់ឆ្នាំ ១៩៧៨ របស់ប្រទេសស៊ីលីស្តីពីការអនុគ្រោះទោសទូទៅ ពុំបានរារាំងតុលាការនៅអេស្ប៉ាញមិនឱ្យអនុវត្តយុត្តាធិការសកលរបស់ខ្លួនឡើយ[១១៣]។ តុលាការពិសេសសម្រាប់សៀរ៉ាឡេអូនក៏បានសន្និដ្ឋានដូចគ្នាទៅនឹងតុលាការអេស្ប៉ាញដែរ[១១៤]។

៥១. ថ្វីត្បិតការផ្តល់ការអនុគ្រោះទោសនៅតែជាទម្លាប់អនុវត្តជាប់ជាហូរហែរក្តី ប៉ុន្តែក៏មាននិន្នាការក្នុងការកំហិតវិសាលភាពនៃការអនុគ្រោះទោសនេះដែរ[១១៥]។ ទោះបីនាពេលកន្លងមក ការអនុគ្រោះ

---

[១១២] ច្បាប់លើកលែងទោស, ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៩៣, *សូមមើល* បារាំង, តុលាការកំពូល, ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០២, Bull. Civ. 2002, No 195, ទំព័រ ៧២៥ ("l'exercise par une jurisdiction française de la compétence universelle emporte la competence de la loi francaise, même en présence d'une loi étrangère portent amnistie")។ នៅពេលក្រោយមកទៀត តុលាការសិទ្ធិមនុស្សអឺរ៉ុបបានឯកភាពទៅនឹងសំអាងហេតុនេះក្នុងសំណុំរឿង *Ould Dah ទល់នឹង France,* សេចក្តីសម្រេចស្តីពីការទទួលយកសំណើ (លេខ ១៣១១៣/០៣), តុលាការសិទ្ធិមនុស្សអឺរ៉ុប, ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩ (ដោយយល់ឃើញថាជាទូទៅច្បាប់លើកលែងទោសពុំស្របទៅនឹងភារកិច្ចរបស់រដ្ឋក្នុងការស៊ើបអង្កេតអំពើទារុណកម្ម។ តុលាការសិទ្ធិមនុស្ស អឺរ៉ុបក៏បានចាត់ទុកថាច្បាប់លើកលែងទោស Mauritanian ពុំអាចរារាំងការយកច្បាប់បារាំងមកអនុវត្តនៅចំពោះមុខតុលាការនានានៅបារាំងដែលបានទទួលសំណុំរឿងនេះបានឡើយ ដោយសារយុត្តាធិការសកល)។

[១១៣] អេស្ប៉ាញ, *សំណុំរឿង* Pinochet, សាលក្រម, Sala de lo Penal de la Audiencia Nacional, ចុះថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨, *សូមមើល ផងដែរ* ហូឡង់, *សំណុំរឿងរដ្ឋអាជ្ញា ទល់នឹង F,* LJN: BA9575, District Court នៅក្រុងឡាអេ, 09/75000 1-06, ILDC 797 25 ខែ មិថុនា ឆ្នាំ ២០០៧ (ដែលបានឯកភាពទៅនឹងការអនុវត្តយុត្តាធិការសកលលើឧក្រិដ្ឋកម្មសង្គ្រាម ទោះបីគេជឿថានៅអាហ្វហ្គានីស្ថាន មានការលើកលែងទោសក្តី), អេស្ប៉ាញ, *សំណុំរឿង Galtieri* , .Orden de prison provisional incondicional de Leopoldo Fortunato Galtieri por delitos de asesinato, desaparicion forzosa y genocidio, por el Magistrado-Juez del Juzgado Numero cino de la Audiencia Nacional Espanola, ខែ មីនា ឆ្នាំ ១៩៩៧ (ដោយបានគូសបញ្ជាក់ថាច្បាប់លើកលែងទោសរបស់អាហ្សង់ទីន ផ្ទុយទៅនឹងកាតព្វកិច្ចតាមសន្ធិសញ្ញាអន្តរជាតិរបស់អាហ្សង់ទីន)។

[១១៤] សេចក្តីសម្រេច *Kallon,* កថាខណ្ឌ ៧១, ៨៥។

[១១៥] *សូមមើលឧទាហរណ៍* ក្រឹត្យច្បាប់លេខ ២០១១-១ របស់ទុយនេស៊ី ឆ្នាំ ២០១១ ដែលបានផ្តល់ការលើកលែងទោស, *សកម្មភាពមិនអនុលោមតាមគោលការណ៍ជាសារវ័ន្ត លេខ ១៥៣,* តុលាការកំពូលសហព័ន្ធប្រេស៊ីល, ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១០ (ដោយតម្កល់ច្បាប់លើកលែងទោសឆ្នាំ១៩៧៩ ដោយសំអាងថាកាលពីពេលនោះច្បាប់នេះជាវិធានការចាំបាច់ដើម្បីការផ្សះផ្សានិងប្រជាធិបតេយ្យភាវូបនីយកម្ម និងដោយហេតុថាច្បាប់នេះពុំមែនជាការលើកលែងទោសដោយខ្លួនឯងឡើយ។ សេចក្តីសម្រេចនេះបានទទួលការរិះគន់ជាទូទៅ រួមទាំងពីសំណាក់គណៈកម្មាធិការអង្គការសហប្រជាជាតិប្រឆាំងនឹងការធ្វើទារុណកម្មផង);*សូមមើលផងដែរសំណុំរឿង* Gomes Lund et al ("Guerrilha do Araguaia") *ទល់នឹង ប្រេស៊ីល,* សាលក្រម, IACtHR, ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១០, កថាខណ្ឌ ១៧៥ (ដោយផ្តល់សុពលភាពគតិយុត្តដល់ការលើកលែងទោសនៅប្រេស៊ីល) (មានតែសំណៅជាភាសាអេស្ប៉ាញប៉ុណ្ណោះ)។

ទោសគឺជានិយាមមួយក្តី ក៏ការអនុគ្រោះទោសជាច្រើនពុំបានគ្របដណ្តប់លើបទល្មើសធ្ងន់ធ្ងរមួយចំនួនក្រោមច្បាប់អន្តរជាតិឡើយ ដូចជាករណីនៅប្រទេសសូរីណាម[១១៦] នីការ៉ាហ្គា[១១៧] ក្វាតេម៉ាឡា[១១៨] សហព័ន្ធបូស្នី និងហឺហ្សេហ្គោវីណា[១១៩] វ៉េណេស៊ុយអេឡា[១២០] កូតឌីវ័រ[១២១] កូឡុំប៊ី[១២២] ហ្វីលីពីន[១២៣] សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ[១២៤] ទុយនេស៊ី[១២៥] និងប៉ូឡូញ[១២៦] ។ រដ្ឋធម្មនុញ្ញនៃ

---

[១១៦] ច្បាប់ឆ្នាំ ១៩៩២ របស់ប្រទេសសូរីណាម ដែលចែងអំពីការលើកលែងទោស, ក្រឹត្យលេខ ៥៥៤៤ (ដោយពុំបានដាក់បញ្ចូលឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទៅក្នុងវិសាលភាពនៃការលើកលែងទោសឡើយ)។

[១១៧] ច្បាប់លើកលែងទោសរបស់នីការ៉ាហ្គា, ឆ្នាំ១៩៩៣ (ដោយពុំដាក់បញ្ចូលឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទៅក្នុងវិសាលភាពនៃច្បាប់នេះទេ)។

[១១៨] ច្បាប់ផ្សះផ្សារជាតិរបស់ក្វាតេម៉ាឡា, ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩៦ (ដោយពុំដាក់បញ្ចូលការលើកលែងទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍, អំពើទារុណកម្ម, ការបាត់ខ្លួនដោយបង្ខំ, និងបទល្មើសដែលគ្មានអាជ្ញាយុកាល ឬដែលពុំអនុញ្ញាតឲ្យចារីរួចខ្លួនពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដោយអនុលោមតាមច្បាប់ផ្ទៃក្នុង ឬសន្ធិសញ្ញាអន្តរជាតិដែលក្វាតាម៉ាឡាបានផ្តល់សច្ចាប័ន)។ តុលាការនៅក្វាតេម៉ាឡាបានអនុវត្តការលើកលែងទោសនេះទៅតាមករណីនីមួយៗ។

[១១៩] ច្បាប់ស្តីពីការលើកលែងទោសឆ្នាំ ១៩៩៩ របស់សហព័ន្ធបូស្នី និងហឺហ្សេហ្គោវីណា (ដោយការលើកលែងទោសនេះពុំបានរាប់បញ្ចូល "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងប្រឆាំងនឹងច្បាប់អន្តរជាតិដូចមានចែងក្នុងចំណុច XVI នៃ [ក្រមព្រហ្មទណ្ឌ SFRY]")។

[១២០] ច្បាប់ស្តីពីការលើកលែងទោសនយោបាយទូទៅឆ្នាំ២០០០ របស់វ៉េណេស៊ុយអេឡា (ដោយមិនរាប់បញ្ចូលនូវឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មធ្ងន់ធ្ងរប្រឆាំងនឹងសិទ្ធិមនុស្ស និងឧក្រិដ្ឋកម្មសង្គ្រាម)។

[១២១] ច្បាប់លើកលែងទោសឆ្នាំ ២០០៣ របស់កូតឌីវ័រ (ដោយពុំរាប់បញ្ចូលឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ) និងច្បាប់លើកលែងទោសឆ្នាំ ២០០៧ (ដោយការលើកលែងទោសនោះពុំបានរាប់បញ្ចូល "ឧក្រិដ្ឋកម្ម និងបទល្មើសប្រឆាំងនឹងច្បាប់អន្តរជាតិ")។

[១២២] ច្បាប់យុត្តិធម៌ និងសន្តិភាពឆ្នាំ ២០០៥ របស់កូឡុំប៊ី (ដោយពុំបានលើកលែងទោសចំពោះយុទ្ធជនដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរមួយចំនួន ដែលមានចែងក្នុងច្បាប់អន្តរជាតិ ប៉ុន្តែបានកំហិតទោសពួកគេមកនៅត្រឹម ៥-៨ ឆ្នាំវិញ។

[១២៣] សេចក្តីប្រកាសលេខ ១៣៧៧ ក្នុងឆ្នាំ ២០០៧ របស់ហ្វីលីពីន (ដែលការលើកលែងទោសនោះពុំបានរាប់បញ្ចូលនូវ "ឧក្រិដ្ឋកម្មប្រឆាំងនឹងភាពបរិសុទ្ធស្អាតស្អំ, បទរំលោភសេពសន្ថវៈ, ការធ្វើទារុណកម្ម, ការចាប់ជំរិតទារប្រាក់ ការប្រើប្រាស់ និងការជួញដូរគ្រឿងញៀន និងបទល្មើសផ្សេងៗសម្រាប់ប្រយោជន៍ផ្ទាល់ខ្លួន និងអំពើបំពារបំពានច្បាប់អន្តរជាតិ" (ទោះបីគេបានចោទថាបទល្មើសទាំងនោះត្រូវបានប្រព្រឹត្តតាមជំនឿនយោបាយក្តី))។

[១២៤] ច្បាប់លើកលែងទោសឆ្នាំ ២០០៩ របស់សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ (ដោយពុំបានរាប់បញ្ចូលនូវឧក្រិដ្ឋកម្មប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ)។

[១២៥] ក្រឹត្យច្បាប់លេខ ២០១១-១ ដែលអនុញ្ញាតឲ្យមានការលើកលែងទោស, ឆ្នាំ ២០១១ (ដោយពុំបានរាប់បញ្ចូលនូវបទល្មើសក្រោមច្បាប់អន្តរជាតិ)។

បណ្ដាប្រទេសកាន់តែច្រើនឡើង មានចែងអំពីការហាមឃាត់ការអនុគ្រោះទោសចំពោះបទល្មើសក្រោមច្បាប់អន្តរជាតិ[១២៧]។

៥២. ផ្ទុយទៅវិញ ការអនុគ្រោះទោសដើម្បីដោះលែងអ្នកទោសនយោបាយនៃរបបមុន ឬដើម្បីសម្របសម្រួលឱ្យមានការប្រគល់ជនភៀសខ្លួនត្រូវបានទទួលស្គាល់ឬលើកទឹកចិត្តជាបន្តបន្ទាប់[១២៨]។ ការអនុគ្រោះទោសទាំងឡាយដែលមានលក្ខខណ្ឌ ដូចជាការអនុគ្រោះទោសដោយមានការទទួលខុសត្រូវមួយចំនួនក៏បានការទទួលស្គាល់យ៉ាងទូលំទូលាយផងដែរ។ ជាក់ស្ដែងនៅអាហ្វ្រិកខាងត្បូង ការអនុគ្រោះទោសត្រូវបានធ្វើឡើងដើម្បីរួមចំណែកដល់ដំណើរការផ្សះផ្សា[១២៩]។ ដើម្បីបានទទួលការអនុគ្រោះទោស អ្នកស្នើសុំត្រូវលាតត្រដាងរាល់អង្គហេតុពាក់ព័ន្ធទាំងអស់ឱ្យបានលម្អិត ដែលធានាយ៉ាងហោចណាស់ឱ្យមានការទទួលខុសត្រូវមួយចំនួន និងឱ្យជនរងគ្រោះបានដឹងការពិត[១៣០]។ ការអនុគ្រោះទោសផ្សេងៗទៀតមានដាក់លក្ខខណ្ឌ ដូចជាការចុះចូលទៅនឹងអាជ្ញាធរ ការ

---

[១២៦] Poland's 1998 Act on the Institute of National Remembrance (ដោយពុំរាប់បញ្ចូលនូវឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្នុងការលើកលែងទោសមុនៗ)។

[១២៧] *សូមមើល* មាត្រា ២៨(១) នៃរដ្ឋធម្មនុញ្ញអេត្យូពី (ឆ្នាំ១៩៩៤) (ដែលចែងថា "[ស្ថាប័ននីតិបញ្ញត្តិ ឬស្ថាប័នរដ្ឋ គ្មានសិទ្ធិអំណាចផ្តល់ការអនុគ្រោះទោស ឬការលើកលែងទោសចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ]"), មាត្រា ៨០ នៃរដ្ឋធម្មនុញ្ញអេក្វាឌ័រ (២០០៨) (ដែលចែងថា "កិច្ចដំណើរការនីតិវិធី និងការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មសង្គ្រាម, ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, ការបាត់ខ្លួនដោយបង្ខំ ឬឧក្រិដ្ឋកម្មឈ្លានពានមកលើរដ្ឋណាមួយ ពុំមានអាជ្ញាយុកាលឡើយ។ បទល្មើសខាងលើពុំអាចទទួលការលើកលែងទោសបានឡើយ" (សំណៅបកប្រែក្រៅផ្លូវការ)), មាត្រា ២៩ នៃរដ្ឋធម្មនុញ្ញវេណេស៊ុយអេឡា (ឆ្នាំ ១៩៩៩, វិសោធនកម្ម) (ដែលចែងថា [អំពើរំលោភសិទ្ធិមនុស្ស និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ] ពុំអាចរួចផុតពីនិទ្ទណ្ឌភាពបានឡើយ រួមទាំងការអនុគ្រោះទោស ឬការលើកលែងទោសផង" (សំណៅបកប្រែក្រៅផ្លូវការ)។

[១២៨] *សូមមើលឧទាហរណ៍* ច្បាប់លើកលែងទោសឆ្នាំ ១៩៩៦ និងច្បាប់លើកលែងទោសឆ្នាំ ១៩៩៩ របស់សហព័ន្ធបូស្នី និងហឺហ្សេហ្គោវីណា និងច្បាប់លើកលែងទោសឆ្នាំ១៩៩៦របស់សាធារណរដ្ឋ Srpska និងច្បាប់ស្តីពីការចោទប្រកាន់ និងវិសោធនកម្មច្បាប់លើកលែងទោសឆ្នាំ ១៩៩៦, *សូមមើលផងដែរ* ការលើកលែងទោសនៅអេស្ប៉ាញពីសំណាក់ព្រះមហាក្សត្រ Juan Carlos នៅឆ្នាំ ១៩៧៦ ចំពោះអ្នកទោសនយោបាយក្នុងអំឡុងរបបឧត្តមសេនីយ៍ Francisco Franco។

[១២៩] ច្បាប់ស្តីពីការលើកកម្ពស់ឯកភាពជាតិ និងការផ្សះផ្សាជាតិ ឆ្នាំ១៩៩៥។ នៅឆ្នាំ ១៩៩៦ តុលាការធម្មនុញ្ញអាហ្វ្រិកខាងត្បូងបានតម្កល់ច្បាប់ឆ្នាំ១៩៩៥ត្រង់ផ្នែកពាក់ព័ន្ធនឹងការលើកលែងទោស ដោយសំអាងថាករណីលើកលែងចំពោះវិធានដាច់ខាតដែលហាមឃាត់ការលើកលែងទោសចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលមានចែងនៅក្នុងពិធីសារបន្ថែមទីពីរនៃអនុសញ្ញាក្រុងហ្សឺណែវឆ្នាំ ១៩៤៩ (ដែលយកមកអនុវត្តចំពោះជម្លោះផ្ទៃក្នុង) ((*សំណុំរឿង AZAPO ទល់នឹង ប្រធានាធិបតីសាធារណរដ្ឋអាហ្វ្រិកខាងត្បូង, ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៩៦, សំណុំរឿង CCT 17/96*))។

[១៣០] *សូមមើលឧទាហរណ៍* ច្បាប់យុត្តិធម៌ និងសន្តិភាពឆ្នាំ២០០៥ របស់កូឡុំប៊ី (ច្បាប់ ៩៧៥) (ដែលអនុញ្ញាតឱ្យមានការបន្ធូរបន្ថយទោសចំពោះបទល្មើសធ្ងន់ធ្ងរតាមច្បាប់អន្តរជាតិ)។ ដោយអនុលោមតាមសាលក្រមរបស់តុលាការរដ្ឋធម្មនុញ្ញកូឡុំប៊ីចុះថ្ងៃ

បញ្ឈប់សកម្មភាពប្រដាប់អាវុធ ឬការប្រគល់អាវុធ[១៣១]។ ជាទូទៅ ការអនុគ្រោះទោសទាំងអស់នេះពុំត្រូវបានចាត់ទុកជាមោឃៈឡើយ ប៉ុន្តែត្រូវយកមកអនុវត្តទៅតាមករណីនីមួយៗអាស្រ័យទៅលើកត្តាមួយចំនួន រួមទាំងដំណើរការកំណត់ការអនុគ្រោះទោស ខ្លឹមសារ និងវិសាលភាពនៃការអនុគ្រោះទោស និងថាតើការអនុគ្រោះទោសនោះមានចែងពីការទទួលខុសត្រូវក្នុងទម្រង់ផ្សេងណាមួយដែរឬទេ[១៣២]។

*<u>៤.៥.៣.សេចក្តីសន្និដ្ឋានអំពីវិសាលភាពនៃការអនុគ្រោះទោស ឆ្នាំ ១៩៩៦</u>*

៩៣. ផ្អែកតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះសន្និដ្ឋានថា មានការឯកភាពគ្នាថ្មីៗចំពោះការហាមឃាត់ការអនុគ្រោះទោសចំពោះបទល្មើសធ្ងន់ធ្ងរ ក្រោមច្បាប់អន្តរជាតិដោយផ្អែកលើកាតព្វកិច្ចក្នុងការស៊ើបអង្កេត និងចោទប្រកាន់អំពីបទល្មើសទាំងអស់នេះនិងផ្តន្ទាទោសចារី។ ដូចបញ្ជាក់ពីខាងដើម ការហាមឃាត់នេះគឺជាការហាមឃាត់ដាច់ខាតពាក់ព័ន្ធនឹងបទល្មើសប្រល័យពូជសាសន៍ ការធ្វើទារុណកម្ម និងការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៤៩ (ចំណុច

---

ទី ១៨ ខែ ឧសភា ឆ្នាំ ២០០៦ (C.370/2006) យុទ្ធជនត្រូវលាតត្រដាងការពិតឲ្យបានពេញលេញអំពីបទល្មើសដែលខ្លួនបានប្រព្រឹត្តដើម្បីទទួលប្រយោជន៍ពីច្បាប់នេះ។

[១៣១] សៀរ៉ាឡេអូន (សន្ធិសញ្ញាសន្តិភាព Lomé ឆ្នាំ ១៩៩៩), កម្ពុជា (ច្បាប់ឆ្នាំ ១៩៩៤), អាល់ហ្សេរី (ឆ្នាំ ១៩៩៩-ច្បាប់ស្តីពីការផ្សះផ្សាជាតិ និងធម្មនុញ្ញសម្រាប់សន្តិភាព និងការផ្សះផ្សាជាតិឆ្នាំ ២០០៥), អង់ហ្គោឡា (អនុស្សរណៈយោគយល់សម្រាប់សន្តិភាព និងការផ្សះផ្សានៅខេត្ត Cabinda ឆ្នាំ ២០០៦ ដែលបានអនុវត្តនៅក្នុងច្បាប់លើកលែងទោសថ្នាក់ជាតិ), *សូមមើលផងដែរ* ច្បាប់ស្តីពីការផ្សះផ្សារជាតិរបស់អាល់ហ្សេរី (ឬហៅថា ច្បាប់ស្តីពីកិច្ចព្រមព្រៀងជាសាធារណៈ), ឆ្នាំ ១៩៩៩ (លក្ខខណ្ឌស្តីពីការជូនដំណឹងអំពីការបញ្ឈប់ "សកម្មភាពភេរវកម្ម ឬវិទ្ធង្សនា" ក្នុងរយៈពេល៦ខែនៃការប្រកាសឲ្យប្រើច្បាប់នេះ និងការប្រគល់ខ្លួនឲ្យអាជ្ញាធរមានសមត្ថកិច្ច)។ ច្បាប់លើកលែងទោសនេះពុំមានវិសាលភាពលើ "សកម្មភាពភេរវកម្ម ឬវិទ្ធង្សនា, អំពើដែលបណ្តាលឲ្យមានការបាត់បង់ជីវិត ឬពិការភាពជាអចិន្ត្រៃយ៍, អំពើរំលោភសេពសន្ថវៈ, ការបំផ្ទុះគ្រាប់បែកតាមទីសាធារណៈ", ធម្មនុញ្ញសម្រាប់សន្តិភាព និងការផ្សះផ្សាជាតិឆ្នាំ២០០៥របស់អាល់ហ្សេរីដែលត្រូវបានបំពេញបន្ថែមដោយច្បាប់ និងក្រឹត្យមួយចំនួន (ដែលតម្រូវឲ្យសាមីខ្លួនត្រូវប្រគល់ខ្លួនឲ្យសមត្ថកិច្ចនៅក្នុងអំឡុងរយៈពេលកំណត់ណាមួយ និងផ្តល់ព័ត៌មានអំពីបទល្មើសដែលខ្លួនបានប្រព្រឹត្ត និងការបញ្ឈប់សកម្មភាពប្រដាប់អាវុធ) និងច្បាប់ពាក់ព័ន្ធនឹងការលើកលែងទោសឆ្នាំ ១៩៩៤ របស់ហៃទីដែលត្រូវបានអនុវត្តដោយអនុលោមតាមកិច្ចព្រមព្រៀង Port-au-Prince រវាងសហរដ្ឋអាមេរិក និងហៃទី (ឆ្នាំ ១៩៩៤) ។ តាមរយៈកិច្ចព្រមព្រៀងនេះ មន្ត្រីយោធាមួយចំនួននៃកងកម្លាំងប្រដាប់អាវុធហៃទីបានយល់ព្រម "ចូលនិវត្តន៍ដោយកិត្តិយសមុនពេលកំណត់" ជាថ្នូរនឹងការលើកលែងទោសដែលអនុញ្ញាតឲ្យប្រធានាធិបតី Aristide វិលត្រឡប់ចូលប្រទេសវិញ និងបញ្ចប់ជម្លោះ។

[១៣២] *សូមមើល ឧទាហរណ៍* សេចក្តីសម្រេចរបស់តុលាការធម្មនុញ្ញអ៊ូហ្គាន់ដាលើសំណើលេខ ០៣៦/១១, សំណុំរឿង *Thomas Kwoyelo ហៅ Latoni ទល់នឹង អ៊ូហ្គាន់ដា*, ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១, បន្ទាត់ទី៥៣១-៥៨២ (ដែលវិភាគអំពីស្ថានភាពរបស់អ្នកដាក់ពាក្យសុំ និងបរិបទទូទៅនៃប្រទេសនោះ និងការលើកសំអាងហេតុថាអ្នកដាក់ពាក្យសុំគួរត្រូវបានលើកលែងទោសក្រោមច្បាប់លើកលែងទោសឆ្នាំ ២០០០ ដែលពុំមែនជាការលើកលែងទោសទាំងស្រុង)។

៤.២.១)។ បើទោះជាថាទម្លាប់អនុវត្តន៍របស់រដ្ឋពាក់ព័ន្ធនឹងបទល្មើសធ្ងន់ធ្ងរផ្សេងៗក្រោមច្បាប់អន្តរជាតិ ពុំទាន់មានការស្របគ្នាទាំងស្រុងក្នុងការកំណត់អំពីការហាមឃាត់ដាច់ខាតមិនឲ្យអនុគ្រោះទោសពាក់ព័ន្ធនឹងបទល្មើសទាំងនោះក្តី ក៏ទម្លាប់អនុវត្តនេះបង្ហាញជាអប្បបរមាអំពីសិទ្ធិជាប្រតិសកម្មរបស់រដ្ឋ និងតុលាការជាតិ និងតុលាការអន្តរជាតុបនីយកម្មពាក់ព័ន្ធក្នុងការវាយតម្លៃទៅលើការអនុគ្រោះទោស និងទុកការលើកលែងទោសដោយឡែក ឬកំហិតវិសាលភាពនៃការអនុគ្រោះទោស ប្រសិនបើការអនុគ្រោះទោសនោះពុំស្របទៅនឹងនិយាមអន្តរជាតិ។ និយាមទាំងអស់នេះក៏បញ្ជាក់អំពីកាតព្វកិច្ចច្បាស់លាស់របស់រដ្ឋក្នុងការដាក់ឲ្យចារីទទួលខុសត្រូវចំពោះបទល្មើសធ្ងន់ធ្ងរក្រោមច្បាប់អន្តរជាតិ និងផ្តល់ឲ្យជនរងគ្រោះនូវដំណោះស្រាយប្រកបដោយប្រសិទ្ធភាព ហើយគាំទ្រដល់ការសន្និដ្ឋានថា ការអនុគ្រោះទោសលើបទល្មើសទាំងអស់នេះ (ពិសេសនៅពេលពុំមានភ្ជាប់មកជាមួយនូវទម្រង់នៃការទទួលខុសត្រូវណាមួយ) គឺពុំស្របទៅនឹងទិសដៅនៃកាតព្វកិច្ចទាំងនេះឡើយ។

៥៤. អាស្រ័យហេតុនេះ អង្គជំនុំជម្រះអាចអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនដោយមិនពិចារណាទៅលើការអនុគ្រោះទោសនេះ ដែលខ្លួនយល់ថាផ្ទុយទៅនឹងដំណើរវិវឌ្ឍន៍នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងកាតព្វកិច្ចអន្តរជាតិរបស់កម្ពុជា។ អង្គជំនុំជម្រះកត់សម្គាល់ឃើញទៀតថា ព្រះរាជក្រឹត្យឆ្នាំ១៩៩៦ ពុំបានដាក់លក្ខខណ្ឌទៅលើការអនុគ្រោះទោស ឬចែងអំពីទម្រង់នៃការទទួលខុសត្រូវណាមួយចំពោះបទល្មើសដែលត្រូវបានប្រព្រឹត្តកាលអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យឡើយ។ ជាការពិតណាស់ អៀង សារី និងយុទ្ធជនមួយចំនួនធំបានវិលត្រឡប់មករួមរស់ជាមួយរដ្ឋាភិបាលវិញ ដោយសារអនុភាពនៃព្រះរាជក្រឹត្យនេះ ហើយការធ្វើបែបនេះអាចបានរួមចំណែកដល់ការនាំសន្តិភាពមកឲ្យកម្ពុជា។ ទោះបីការអនុគ្រោះទោសឆ្នាំ ១៩៩៦ អាចជាមធ្យោបាយនាំទៅរកការចរចាដ៏មានសារៈសំខាន់ក្នុងការបញ្ចប់ជម្លោះក្តី ក៏អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ការអនុគ្រោះទោសនេះពុំបានភ្ជាប់ជាមួយនូវដំណើរការស្វែងរកការពិត ឬការផ្សះផ្សាដែលអាចលាតត្រដាងព័ត៌មានពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់មកលើជនជាប់ចោទ អៀង សារី ឬ មានការទទួលស្គាល់សិទ្ធិជាសាកលរបស់ជនរងគ្រោះក្នុងការទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាពឡើយ[១៣៣]។

[១៣៣] ការលើកលែងទោសគឺព្រះមហាក្សត្រជាអ្នកប្រទាន ក៏ប៉ុន្តែពុំមានការពិភាក្សាដេញដោល ការបោះឆ្នោត ឬការឯកភាពជាផ្លូវការណាមួយពីសំណាក់សភាជាតិឡើយ។ *សូមមើល* "សេចក្តីបញ្ជាក់របស់សម្តេចនរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា", ឯកសារ D427/1/6.1.3, ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ១៩៩៦ (ដែលបញ្ជាក់ថាការលើកលែងទោសត្រូវបានធ្វើជាសាធារណៈ ហើយអនុវត្តបានដោយពុំចាំបាច់ទទួលសំឡេង ២ ភាគ ៣ ពីសភាជាតិ ដូចដែលទ្រង់ធ្លាប់បានត្រាស់បង្គាប់ឡើយ)។

00751142



៩៥. ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា វិសាលភាពនៃការអនុវត្តការអនុគ្រោះទោសឆ្នាំ ១៩៩៦ ពុំបញ្ចូលនូវបទល្មើសប្រល័យពូជសាសន៍ អំពើទារុណកម្ម និងអំពើបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវឆ្នាំ ១៩៤៩ ឡើយ។ ផ្អែកតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះ បដិសេធមិនដាក់បញ្ចូលបទល្មើសធ្ងន់ធ្ងរតាមច្បាប់អន្តរជាតិដែលនៅសេសសល់ ដែលត្រូវបានចោទប្រកាន់មកលើជនជាប់ចោទទៅក្នុងវិសាលភាពនៃព្រះរាជក្រឹត្យឆ្នាំ១៩៩៦ឡើយ។ អាស្រ័យហេតុនេះ ព្រះរាជក្រឹត្យឆ្នាំ ១៩៩៦ ពុំបានហាមឃាត់មិនឱ្យអង្គជំនុំជម្រះសាលាដំបូងអនុវត្តយុត្តាធិការរបស់ខ្លួនលើជនជាប់ចោទ អៀង សារី ឡើយ។

## តាមសំអាងហេតុខាងលើ អង្គជំនុំជម្រះ÷

**បដិសេធ** អញ្ញត្រកម្មរបស់មេធាវីការពារក្ដី អៀង សារី ដែលសំអាងទៅលើគោលការណ៍*គ្មានការកាត់ទោសពីរដង លើបទល្មើសតែមួយ*។

**បដិសេធ** អញ្ញត្រកម្មរបស់មេធាវីការពារក្ដី អៀង សារី ដែលសំអាងលើព្រះរាជក្រឹត្យឆ្នាំ ១៩៩៦ ចាត់ទុកថាទោសដែលតុលាការប្រជាជនបដិវត្តន៍ឆ្នាំ ១៩៧៩ បានសម្រេច ពុំអាចលើកលែងទោសបាន និងប្រកាសថាការអនុគ្រោះទោសដែលមានចែងនៅក្នុងព្រះរាជក្រឹត្យនេះ ពុំអាចយកមកអនុវត្តបានឡើយចំពោះការចោទប្រកាន់ពីបទរំលោភធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវឆ្នាំ ១៩៤៩ បទឧក្រិដ្ឋប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលមាននៅក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២។

**បដិសេធ** សំណើរបស់មេធាវីការពារក្ដីរបស់ អៀង សារី ដែលបានស្នើសុំឱ្យស្ដាប់ចម្លើយសាក្សី ដើម្បីសម្រេចលើវិសាលភាពនៃព្រះរាជក្រឹត្យឆ្នាំ ១៩៩៦។

**ប្រកាសថា** ពុំចាំបាច់ត្រូវដោះស្រាយបញ្ហានៃការអនុវត្តព្រះរាជក្រឹត្យឆ្នាំ ១៩៩៦ ចំពោះបទល្មើស តាមច្បាប់ជាតិ បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានសម្រេចកាលពីថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ (ឯកសារ E122) ថា បទល្មើសតាមច្បាប់ជាតិពុំមានមូលដ្ឋានសម្រាប់កិច្ចដំណើរការនីតិវិធីជំនុំជម្រះលើសំណុំរឿង ០០២ ឡើយ។

ភ្នំពេញ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១១

ប្រធានអង្គជំនុំជម្រះសាលាដំបូង

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

E C C C

និល ណុន